កម្ពុជាក្រោម
Kampuchea Krom

ព្រឹត្តិបត្រចេញផ្សាយជារៀងរាល់ខែដោយសហព័ន្ធខ្មែរកម្ពុជាក្រោម KKF's Monthly Newsletter

ឆ្នាំទី ២២ លេខ ៩៥ - ខែកញ្ញា ព. ស. ២៥៧០ គ. ស. ២០២៦ Vol. 22 No. 95 - September 2026

មហាសន្និបាតពិភពលោក លើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម

សហព័ន្ធខ្មែរកម្ពុជាក្រោម ធ្វើមហាសន្និបាតពិភពលោក លើកទី ១២ នៅទីស្នាក់ការរបស់ខ្លួន នារដ្ឋធានី Washington ឌីស៊ី សហរដ្ឋអាមេរិក រយៈពេល ៣ ថ្ងៃ គឺ ថ្ងៃសុក្រ សៅរ៍ និងអាទិត្យ ទី ១៧ - ១៨ និង ១៩ ខែកក្កដា ឆ្នាំ ២០២៦ ក្រោមប្រធានបទ “សាមគ្គីដើម្បីអនាគតរបស់យើង ផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋខ្មែរក្រោមគ្រប់រូប ធ្វើការតស៊ូមតិ ដើម្បីសិទ្ធិនៃប្រជាជនរបស់យើង” និងបាវចនា “សំឡេងនីមួយៗ សុទ្ធតែសំខាន់ ។ សកម្មភាពនីមួយៗ សុទ្ធតែមានតម្លៃ” ។

អានទៅទំព័រ ១៦



ថ្នាក់ដឹកនាំ សមាជិក និងអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលរួម មហាសន្និបាត លើកទី ១២ ។



តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម នៅក្នុងវេទិកាជនជាតិដើម (UNPFII) ឆ្នាំ ២០២៦ ។

តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលថ្លែងការណ៍នៅក្នុងអង្គការសហប្រជាជាតិ ស្តីពីបញ្ហាជនជាតិដើម (UNPFII)

តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ដឹកនាំដោយ លោក ម៉ៅ មុនី ជាអនុប្រធានទីមួយ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលរួមប្រជុំ ដាក់របាយការណ៍ និងថ្លែងការណ៍នៅក្នុងវេទិការអចិន្ត្រៃយ៍ នៃ អ.ស.ប. ស្តីពីបញ្ហាជនជាតិដើម (UNPFII) លើកទី ២៥ ចាប់ពីថ្ងៃទី ២០ ខែមេសា ដល់ ១ ខែឧសភា ឆ្នាំ ២០២៦ នៅទីស្នាក់ការកណ្តាល អ.ស.ប. នាបុរី New York សហរដ្ឋអាមេរិក ក្រោមប្រធានបទ «ធានាសុខភាពជនជាតិដើម រួមទាំងនៅក្នុងបរិបទនៃជម្លោះ» ។

អានទៅទំព័រ ៩

២៥ ឆ្នាំ នៃការចូលជាសមាជិក UNPO របស់ សហព័ន្ធខ្មែរកម្ពុជាក្រោម

អានទៅទំព័រ ១១



ខួប ២៥ ឆ្នាំ សហព័ន្ធខ្មែរកម្ពុជាក្រោម បានចូលជាសមាជិក UNPO ដែលរៀបចំដោយ សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំរដ្ឋ Washington State ថ្ងៃទី ១ ខែសីហា ឆ្នាំ ២០២៦

ទីស្នាក់ការ 4953 E Capitol Street SE, Washington, D.C., USA 20019 +1 (202) 280-7362 vokk2001@gmail.com

គណៈកម្មការព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម

ឧត្តមក្រុមប្រឹក្សា

លោក **សឺង សម្រេច**

ព្រះតេជព្រះគុណ **សឺង ប៉ុច រតនា** (សុវណ្ណប្បញ្ញោ)

លោក **តាំង សារៈ**

ប្រធាន និង អនុប្រធាន

លោក **ថាច់ ប្រ៊ីជា គ្រឿន** ប្រធាន

លោក **ថាច់ ភ្រឿង** អនុប្រធានទី ១

លោក **សឺន ថាយ ឆន** អនុប្រធានទី ២

សហការី

អ្នកស្រី **ថាច់ សុជាតា** ប្រទេសកាណាដា

អ្នកស្រី **ឆាង ណារី** សហរដ្ឋអាមេរិក

លោក **ថាច់ វាសនា** ប្រទេសបារាំង

លោក **ស៊ឺន ចែងចើន** ព្រះរាជាណាចក្រកម្ពុជា

លោក **គឹម សាវតារ** ព្រះរាជាណាចក្រកម្ពុជា

លោក **សឺន ជយវច្ឆ** ព្រះរាជាណាចក្រកម្ពុជា

នាង **ថាច់ ភើឌីញ៉ា** សហរដ្ឋអាមេរិក

ប្រព័ន្ធផ្សព្វផ្សាយជាផ្លូវការ

សំឡេងកម្ពុជាក្រោម-VOKK

www.vokk.net

www.facebook.com/vokk.net

សហព័ន្ធខ្មែរកម្ពុជាក្រោម

www.khmerkrom.org

ទូរទស្សន៍កម្ពុជាក្រោម- Kampuchea Krom TV (KKtv)

www.facebook.com/kampucheakromtv

ទំនាក់ទំនង

ទីស្នាក់ការ 4953 E Capitol Street SE, Washington, D.C., 20019, USA

vokk2001@gmail.com

+1 (202) 280-7362

មាតិកា

ព្រឹត្តិបត្រ កម្ពុជាក្រោម

ឆ្នាំទី ២២ លេខ ៩៥ ខែកញ្ញា ព.ស. ២៥៧០ - គ.ស. ២០២៦

ទំព័របណ្ណាធិការ

- សារស្វាគមន៍ ក្នុងការផ្សាយឡើងវិញនូវព្រឹត្តិបត្រ «កម្ពុជាក្រោម» របស់ប្រធានគណៈកម្មការព័ត៌មាន នៃ ស.ខ.ក. |ទំព័រ ៤-៥|

សកម្មភាពសហព័ន្ធខ្មែរកម្ពុជាក្រោម

- សហព័ន្ធខ្មែរកម្ពុជាក្រោម នឹងរៀបចំសន្និបាតជំណាប់ឆ្នាំ ២០២៦ នៅរដ្ឋធានីវ៉ាស៊ីនតោន ពីថ្ងៃទី ១១ ដល់ ១៣ ខែធ្នូ |ទំព័រ ៦|
- សហព័ន្ធខ្មែរកម្ពុជាក្រោម រដ្ឋវ៉ាស៊ីងតោន ប្រារព្ធពិធីរំឭកខួប ២៥ ឆ្នាំ នៃ ស.ខ.ក. ចូលជាសមាជិក UNPO |ទំព័រ ១១-១២|
- មហាសន្និបាតពិភពលោក លើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម |ទំព័រ ១៦-២២|
- សមាសភាពគណៈកម្មការសាខា និងតំបន់ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅតាមរដ្ឋ និងប្រទេសនានា |ទំព័រ ២៣-២៤|
- របាយការណ៍សកម្មភាពរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម តំបន់ប្រទេសកម្ពុជា រយៈពេល ៣០ ឆ្នាំ៖ ១៩៩៦-២០២៦ |ទំព័រ ៣៥-៣៩|
- សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំតំបន់ និងសាខានៅកម្ពុជា ប្រកាសសមាសភាពថ្មី សម្រាប់អាណត្តិ ២០២៦-២០៣០ |ទំព័រ ៤០-៤១|
- UNPO ធ្វើមហាសន្និបាតលើកទី ២១ នៅទីក្រុងឡាអេ បញ្ជាក់ជាថ្មីអំពីជំហរ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» |ទំព័រ ៧-៨|
- តំណាងសហព័ន្ធខ្មែរកម្ពុជាក្រោម ថ្លែងអំពីបញ្ហាសិទ្ធិមនុស្ស និងវប្បធម៌របស់ខ្មែរក្រោម នៅវេទិកាជនជាតិដើម UNPFII |ទំព័រ ៩-១០|
- សហព័ន្ធខ្មែរកម្ពុជាក្រោម ប្តោលទោសតុលាការយួន ប្រកាសផ្តន្ទាទោសខ្មែរក្រោម ៣ រូប |ទំព័រ ១៤|
- សហព័ន្ធខ្មែរកម្ពុជាក្រោម និង GHRD ជាក់ញត្តិជូនសភាហុល្លង់ អំពីសិទ្ធិមនុស្ស និងយុត្តិធម៌អាកាសធាតុនៅកម្ពុជាក្រោម |ទំព័រ ១៤-១៥|
- លេខាធិការដ្ឋានអង្គការសមាគម ខ.ក. នៅកម្ពុជា ធ្វើសិក្ខាសាលាស្តីពី «សិទ្ធិស្វ័យសម្រេចរបស់ជនជាតិដើមខ្មែរក្រោម» |ទំព័រ ៤២-៤៣|

ឯកសារ និងគោលការណ៍តស៊ូមតិ

- គោលការណ៍ ១០ ចំណុច នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម |ទំព័រ ៣២-៣៤|
- សេចក្តីថ្លែងការណ៍៖ ៧៧ ឆ្នាំ នៅក្រោមរបបអាណានិគមយួន – ភាពគង់វង្ស និងការតស៊ូមតិដើម្បីសិទ្ធិនៃប្រជាជាតិខ្មែរក្រោម |ទំព័រ ៤៤-៤៦ |

ប្រវត្តិសាស្ត្រ បុគ្គល និងសមិទ្ធផល

- ប្រវត្តិនៃការបង្កើតទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក |ទំព័រ ២៤-២៦ |
- ប្រវត្តិរូបសំណាកវីរបុរសជាតិនៅដៃនដីកម្ពុជាក្រោម ឯកញ៉ា សឺន គុយ |ទំព័រ ២៨-៣១ |
- ជីវប្រវត្តិសង្ខេប ព្រឹទ្ធាចារ្យ បៅ រៀប អតីតប្រធានសភាព្រឹទ្ធាចារ្យ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម |ទំព័រ ៤៧-៤៨|
- ប្រវត្តិ ទិដ្ឋភាព និងព្រឹត្តិការណ៍សំខាន់ៗ នៃទឹកដីខេត្តឃ្លាំង កម្ពុជាក្រោម |ទំព័រ ៤៩-៥៣|

ភាសា វប្បធម៌ និងអត្តសញ្ញាណ

- ឈ្មោះដើមរបស់ខ្មែរចារលើទឹកដី យួនប្តូរឈ្មោះថ្មីចារលើក្រដាស (រូបភាព) |ទំព័រ ១៥|
- សម្រង់ពាក្យខ្មែរនិយមប្រើនៅដៃនដីកម្ពុជាក្រោម |ទំព័រ ៥៨-៥៩|

សួនកំណាព្យ និងកវីនិពន្ធ

- ប្រលោមលោកបែបបទោសញ្ចោតនាៈ រឿង «វាសនាបុប្ផាខ្មែរក្រោម» – វគ្គ ១៖ ផ្ទៃបគ្រាដំបូង |ទំព័រ ៥៤-៥៨|
- គុណបំណាច់បាយបាត្រ |ទំព័រ ៤១|

កថាស្វាគមន៍
របស់ប្រធាន គណៈកម្មការព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម
ក្នុងការផ្សាយឡើងវិញនូវព្រឹត្តិបត្រ កម្ពុជាក្រោម

សូមស្វាគមន៍ការវិលត្រឡប់មកវិញ នៃ ព្រឹត្តិបត្រ «កម្ពុជាក្រោម» ។

សូមថ្វាយបង្គំបំពោះព្រះសង្ឃជាទីគោរព និងសូមស្វាគមន៍ប្រិយមិត្តអ្នកអាន សមាជិក សមាជិកា និងអ្នកគាំទ្រទាំងអស់ដោយមេត្រីភាព ។ នេះជាការផ្សាយឡើងវិញ នៃព្រឹត្តិបត្រ **«កម្ពុជាក្រោម»** បេញផ្សាយជារៀងរាល់ខែ ដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម ។ ការវិលត្រឡប់មកវិញ នៃ ព្រឹត្តិបត្រនេះ មិនមែនគ្រាន់តែជាការបន្តការផ្សព្វផ្សាយសារព័ត៌មានមួយប៉ុណ្ណោះទេ ប៉ុន្តែជាការបើកទំព័រថ្មីមួយសម្រាប់ការកត់ត្រាប្រវត្តិសាស្ត្រ ផ្សព្វផ្សាយព័ត៌មាន បែករំលែកបំណេះដឹង និងបន្តស្មារតីនៃការតស៊ូមតិរបស់ពលរដ្ឋខ្មែរក្រោមជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម ដែលកំពុងតែបិតនៅក្រោមនឹមអាណានិគមយួន សព្វថ្ងៃ ។

ព្រឹត្តិបត្រ **«កម្ពុជាក្រោម»** ត្រូវបានបង្កើតឡើងដោយ **សហព័ន្ធខ្មែរកម្ពុជាក្រោម** តាំងពីខែមករា ឆ្នាំ ២០០៤ ដើម្បីធ្វើជាវេទិកាព័ត៌មាន និងជាឯកសារសម្រាប់ផ្សព្វផ្សាយអំពីប្រវត្តិសាស្ត្រ វប្បធម៌ អត្តសញ្ញាណ ជីវភាព បញ្ហាសិទ្ធិមនុស្ស និងសេចក្តីប្រាថ្នារបស់ប្រជាជនខ្មែរក្រោម ។ បន្ទាប់ពីបានផ្អាកការផ្សាយតាំងពីឆ្នាំ ២០១៥ មកព្រឹត្តិបត្រនេះបានវិលត្រឡប់មកបម្រើអ្នកអានជាថ្មី ដោយចាប់ផ្តើមពីឆ្នាំទី **២២ លេខ ៩៥ ខែកញ្ញា ព.ស. ២៥៧០ - គ.ស. ២០២៦** ។

ការបេញផ្សាយជាថ្មីនេះ កើតឡើងនៅក្នុងបរិបទដែលព័ត៌មានការអប់រំ និងការកត់ត្រាប្រវត្តិសាស្ត្រកាន់តែមានសារៈសំខាន់បំពេញការការពារអត្តសញ្ញាណជាតិ និងការយល់ដឹងរបស់ប្រជាជនខ្មែរក្រោម ។ គណៈកម្មការព្រឹត្តិបត្រ «កម្ពុជាក្រោម» នឹងទិតទំប្រមូលបងក្រង និងផ្សព្វផ្សាយព័ត៌មាន ព្រឹត្តិការណ៍ ឯកសារ និងអត្ថបទស្រាវជ្រាវ ដែលមានប្រយោជន៍ដល់អ្នកអាន ជាពិសេស មនុស្សជំនាន់ក្រោយ ដែលត្រូវការយល់ដឹងអំពីអតីតកាល ដើម្បីយល់ពីបច្ចុប្បន្ន និងគិតគូរអំពីអនាគត ។



លោក **ថាច់ ប្រីជា គឿន** ប្រធាន គណៈកម្មការព័ត៌មាន នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ។

លេខនេះ ប្រិយមិត្តនឹងបានអានអត្ថបទ និងឯកសារសំខាន់ៗជាច្រើន រួមមាន **សេចក្តីថ្លែងការណ៍ ៣៣ ឆ្នាំ** ស្តីពីស្ថានភាពរបស់ពលរដ្ឋខ្មែរក្រោម ចាប់ពីថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ ដល់ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០២៦ ព្រមទាំងអត្ថបទស្តីពី **មហាសន្និបាតលើកទី ២១ របស់ UNPO នៅទីក្រុងឡាអេ** ដែលបានលើកឡើងជាថ្មីអំពីគោលការណ៍ **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ។

ជាមួយគ្នានេះដែរ ព្រឹត្តិបត្រនឹងបង្ហាញអំពី **កំណត់ហេតុមហាសន្និបាតលើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម** និង **គោលការណ៍ ១០ បំណុច** ដែលបានសម្រេចដោយប្រតិភូចូលរួមមហាសន្និបាត ។

ឯកសារទាំងនេះ មានសារៈសំខាន់សម្រាប់ការកត់ត្រាដំណើរការតស៊ូរបស់សហព័ន្ធ និងជាឯកសារយោងសម្រាប់សមាជិក សមាជិកា និងអ្នកសិក្សាអំពីបលង្គតស៊ូរបស់ប្រជាជាតិខ្មែរក្រោម ។

បំណុចសំខាន់មួយទៀតនោះ យើងក៏នឹងនាំប្រិយមិត្តបានទៅស្គាល់ប្រវត្តិរបស់លោកព្រឹទ្ធាចារ្យ **បៅ រៀប** ជាអតីតប្រធានសភាព្រឹទ្ធាចារ្យ និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោត នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រវត្តិ **ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក** និងប្រវត្តិ**រូបសំណាក ឧកញ៉ា សឺន គុយ** ដែលជាស្នាដៃមួយសម្រាប់រំឭកដល់ប្រវត្តិសាស្ត្រ និងវីរភាពរបស់វីរបុរសជាតិនៅដែនដីកម្ពុជាក្រោម ។ ក្រៅពីនេះ យើងក៏មានបុះផ្សាយអត្ថបទផ្សេងៗទៀតស្តីពីប្រវត្តិសាស្ត្រ វប្បធម៌ និងភូមិសាស្ត្រទឹកដីកម្ពុជាក្រោម ដូចជា **ខេត្តឃ្លាំង** ជាដើម ។

សមត្ថភាពរបស់ពលរដ្ឋ ក្នុងការចូលរួមកំណត់អនាគតរបស់ខ្លួន តាមរយៈមធ្យោបាយសន្តិវិធី និងស្របតាមគោលការណ៍ច្បាប់អន្តរជាតិ ។

យើងសង្ឃឹមថា ការវិលត្រឡប់មកវិញ នៃ ព្រឹត្តិបត្រ **«កម្ពុជាក្រោម»** នឹងក្លាយជាស្ពានសំរាប់ភ្ជាប់រវាងអតីតកាល បច្ចុប្បន្ន និងអនាគតកាល ។ **អតីតកាល**ត្រូវបានកត់ត្រា ដើម្បីកុំឱ្យការបាត់បង់របស់ជាតិត្រូវបាត់បង់ ។ **បច្ចុប្បន្ន**ត្រូវបានផ្សព្វ ផ្សាយដើម្បីបង្កើនការយល់ដឹង ។ ព្រឹត្តិបត្រ **«កម្ពុជាក្រោម» វិលត្រឡប់មកវិញ ដើម្បីកត់ត្រាអតីតកាល បំភ្លឺបច្ចុប្បន្ន និងចែករំលែកចំណេះដឹងសម្រាប់អនាគត** ។ **អនាគត**ត្រូវបានគិតគូរតាមរយៈការអប់រំ និងចែករំលែកចំណេះដឹងដល់មនុស្សជំនាន់ក្រោយ ។

យើងសូមអរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រ និងការរង់ចាំរបស់ប្រិយមិត្តអ្នកអានទាំងអស់ ក្នុងអំឡុងពេលដែលព្រឹត្តិបត្រ

> ព្រឹត្តិបត្រ «**កម្ពុជាក្រោម**» វិលត្រឡប់មកវិញ ដើម្បីកត់ត្រាអតីតកាល បំភ្លឺបច្ចុប្បន្ន និងចែករំលែកចំណេះដឹងសម្រាប់អនាគត ។
> **ចាច ច្រីជា គឿន**

ដូច្នេះ ក្នុងនាម **គណៈកម្មការព័ត៌មាន នៃ ស.ខ.ក.** យើងយល់ថា សារព័ត៌មានមិនមែនមានតួនាទីត្រឹមតែប្រាប់ថា **«មានព្រឹត្តិការណ៍អ្វីកើតឡើង»** ប៉ុណ្ណោះទេ ។ សារព័ត៌មានក៏មានតួនាទីក្នុងការការពារទុកការចងចាំរបស់សង្គមជាតិ បង្កើតការយល់ដឹង និងបើកលំហសម្រាប់ការពិភាក្សាអំពីបញ្ហា ដែលប៉ះពាល់ដល់អនាគតរបស់ជាតិយើងទៀតផង ។ អាស្រ័យហេតុនេះ ព្រឹត្តិបត្ររបស់យើង នឹងព្យាយាមធ្វើជាប្រភពព័ត៌មាន និងឯកសារ ដែលអាចធ្វើឱ្យអ្នកអានធ្វើការសិក្សាពិចារណា និងយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្រ សិទ្ធិសេរីភាព និងបញ្ហាប្រឈមរបស់ពលរដ្ឋនៅដែនដីកម្ពុជាក្រោម ។

ជាពិសេស ព្រឹត្តិបត្រ **«កម្ពុជាក្រោម»** នឹងចូលរួមបំណែកក្នុង**ការតស៊ូមតិបែបព័ត៌មាន** តាមរយៈការផ្សព្វផ្សាយបំណោះដឹង និងព័ត៌មានដែលអាចជួយឱ្យពលរដ្ឋនៅដែនដីកម្ពុជាក្រោម យល់ដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន និងគោលការណ៍ **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ។ ការយល់ដឹងអំពីសិទ្ធិ គឺជាជំហានមួយនៃការពង្រឹង

«កម្ពុជាក្រោម» បានផ្អាកការផ្សាយនាពេលកន្លងមក ។ បាប់ពីលេខនេះតទៅ យើងសូមនមស្ការព្រះគេជព្រះគុណ និងអញ្ជើញប្រិយមិត្តបន្តចូលរួមជាមួយយើង តាមរយៈការអាន ចែករំលែក ផ្តល់ជាមតិយោបល់ និងផ្តល់ជាឯកសារ ឬបំណោះដឹងដែលមានតម្លៃ ដើម្បីរួមគ្នាថែរក្សាប្រវត្តិសាស្ត្រ ភាសា វប្បធម៌ អត្តសញ្ញាណ និងសេចក្តីចងចាំរបស់ប្រជាជាតិខ្មែរក្រោម ។

ព្រឹត្តិបត្រ **«កម្ពុជាក្រោម» វិលត្រឡប់មកវិញ ដើម្បីកត់ត្រាអតីតកាល បំភ្លឺបច្ចុប្បន្ន និងចែករំលែកចំណេះដឹងសម្រាប់អនាគត** ។

ដោយក្តីគោរព និងសេចក្តីស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅបំផុតបំពេញអ្នកអានទាំងអស់ ។

រដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក

ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២៦

ប្រធាន គណៈកម្មការព័ត៌មាន សហព័ន្ធខ្មែរកម្ពុជាក្រោម

ចាច ច្រីជា គឿន

សហព័ន្ធខ្មែរកម្ពុជាក្រោម នឹងរៀបចំ សន្និបាតដំណាច់ឆ្នាំ ២០២៦ នៅរដ្ឋធានីវ៉ាស៊ីនតោន ពីថ្ងៃទី ១១ ដល់ ១៣ ខែធ្នូ

សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) នឹងរៀបចំ សន្និបាតដំណាច់ឆ្នាំ ២០២៦ រយៈពេលបីថ្ងៃ ចាប់ពីថ្ងៃទី ១១ ដល់ថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០២៦ នៅរដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិក ដើម្បីបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ កំណត់ទិសដៅសកម្មភាពសម្រាប់ឆ្នាំ ២០២៧ និងពិភាក្សាអំពីការតស៊ូមតិលើឆាកអន្តរជាតិ ដើម្បីលើកកម្ពស់សិទ្ធិជនជាតិដើមខ្មែរក្រោម ។

ដោយ **ថាប់ ប្រជា គឿន**

យោងតាមលិខិតនិមន្ត និងអញ្ជើញ លេខ ២០២៦-១០-០៦/៥៤ ចុះថ្ងៃទី ៦ ខែតុលា ឆ្នាំ ២០២៦ ចុះហត្ថលេខាដោយលោក សឺន ហួរ ជាអធិបតីនៃ សហព័ន្ធខ្មែរកម្ពុជាក្រោម សន្និបាតដំណាច់ឆ្នាំនេះ នឹងប្រព្រឹត្តទៅនៅទីស្នាក់ការរបស់សហព័ន្ធ ដែលមាន អាសយដ្ឋានលេខ 4953 E. Capitol Street SE, Washington, D.C. 20019 សហរដ្ឋអាមេរិក ។



មហាសន្និបាត ស.ខ.ក. កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ ។

សន្និបាតនេះ នឹងមានការនិមន្ត និងអញ្ជើញចូលរួមពីព្រះសង្ឃខ្មែរក្រោម គណៈកម្មការនាយក ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកឧបត្ថម្ភគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម មកពីបណ្តាប្រទេសនានាជុំវិញពិភពលោក ។

តាមរបៀបវារៈដែលបានគ្រោងទុក សន្និបាតនឹងផ្តោតលើប្រធានបទសំខាន់ៗមួយចំនួន រួមមាន រាយការណ៍សកម្មភាព និងបូកសរុបសមិទ្ធផលរបស់សហព័ន្ធ ដែលបានធ្វើនៅក្នុងឆ្នាំ ២០២៦ រៀបចំសន្និសីទព្រះសង្ឃខ្មែរក្រោម ចេញផែនការសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៧ និងពិភាក្សាអំពីទស្សនវិស័យនៃការតស៊ូមតិដើម្បី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ជនជាតិដើមខ្មែរក្រោមតាមរយៈសកម្មភាពនៅលើឆាកអន្តរជាតិ ។

នៅក្នុងលិខិតអញ្ជើញនោះ លោក សឺន ហួរ បានបញ្ជាក់ថា ការរៀបចំសន្និបាតដំណាច់ឆ្នាំ ២០២៦ នៅរដ្ឋធានីវ៉ាស៊ីនតោន គឺជាការពង្រឹងនូវគោលជំហរតស៊ូមតិផ្នែកការទូតរបស់សហព័ន្ធ ដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរ ការការពារអត្តសញ្ញាណជាតិ វប្បធម៌ និង «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» របស់ពលរដ្ឋខ្មែរក្រោម នៅដែនដីកម្ពុជាក្រោម នាពេលបច្ចុប្បន្ន ។

សហព័ន្ធយោងទៅលើសេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម (UNDRIP) និងលិខិតុបករណ៍ច្បាប់អន្តរជាតិនានា ធ្វើជាមូលដ្ឋានសម្រាប់ការតស៊ូមតិដោយអហិង្សា និងសន្តិវិធី ។

លោក សឺន ហួរ ក៏បានសម្តែងជំនឿថា សន្និបាតដ៏សំខាន់នេះ នឹងរួមចំណែកពង្រឹងសាមគ្គីភាព និងបង្កើនប្រសិទ្ធភាព នៃការតស៊ូមតិរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម ឱ្យកាន់តែមានឥទ្ធិពលនៅលើឆាកអន្តរជាតិ ។

ជាមួយគ្នានេះដែរ លោកក៏បានអារាធនានិមន្តព្រះសង្ឃ និងអញ្ជើញថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រមទាំងអ្នកគាំទ្រ ស.ខ.ក. នៅជុំវិញពិភពលោកឱ្យចូលរួមសន្និបាតនេះឱ្យបានប្រើនកុះករ ដើម្បីបង្ហាញពីសាមគ្គីភាព និងការគាំទ្រចំពោះបេសកកម្មរបស់សហព័ន្ធ និងការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ។

សូមបញ្ជាក់ថា សន្និបាតដំណាច់ឆ្នាំ ២០២៦ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម នឹងប្រព្រឹត្តទៅនៅថ្ងៃទី ១១, ១២ និង ១៣ ខែធ្នូ ឆ្នាំ ២០២៦ នៅទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក ។

UNPO ធ្វើមហាសន្និបាត លើកទី ២១ នៅទីក្រុងឡាអេ បញ្ជាក់ជាថ្មីអំពីជំហរ សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង

អង្គការប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង (UNPO) បានរៀបចំមហាសន្និបាតលើកទី ២១ នៅទីក្រុងឡាអេ ប្រទេសហុល្លង់ កាលពីថ្ងៃទី ២៩ និង ៣០ ខែសីហា ឆ្នាំ ២០២៦ ដោយមានការចូលរួមពីតំណាងប្រជាជាតិ និងប្រជាជនជាសមាជិក ដើម្បីពិភាក្សាអំពីសិទ្ធិមនុស្ស ការតំណាង និង «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ព្រមទាំងអនុម័តសេចក្តីសម្រេច និងជ្រើសរើសថ្នាក់ដឹកនាំអាណត្តិថ្មី សម្រាប់អាណត្តិ ២០២៦ - ២០៣០ ។ ក្នុងឱកាសនេះ តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ក៏បានចូលរួម និងលើកឡើងអំពីស្ថានភាព និងបញ្ហារបស់ខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម រាយការណ៍ដល់អង្គមហាសន្និបាត ផងដែរ ។ មហាសន្និបាតបានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់ UNPO ក្នុងការលើកកម្ពស់សិទ្ធិរបស់ប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង និងបន្តជំរុញឲ្យមានការចូលរួម តស៊ូដោយសន្តិវិធី ដើម្បីសមភាព សេចក្តីថ្លៃថ្នូរ និង "សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង" នៅក្នុងប្រព័ន្ធអន្តរជាតិ ។

ដោយ **ថាប់ ប្រឹងា គឿន**

ទីក្រុងឡាអេ ប្រទេសហុល្លង់ - អង្គការប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង (Unrepresented Nations and Peoples Organization — UNPO) បានរៀបចំមហា សន្និបាតលើកទី ២១ នៅទីក្រុងឡាអេ ប្រទេសហុល្លង់ កាលពីថ្ងៃទី ២៩ និង ៣០ ខែសីហា ឆ្នាំ ២០២៦ ដោយ មានការចូលរួមពីតំណាងប្រជាជាតិ និងប្រជាជនជាសមាជិករបស់ UNPO ដើម្បីពិនិត្យស្រាវជ្រាវកម្មភាពការងារ ពិភាក្សាពីបញ្ហាដែលប៉ះពាល់ដល់សហគមន៍នានា អនុម័តសេចក្តីសម្រេច និងជ្រើសរើសថ្នាក់ដឹកនាំអាណត្តិថ្មី ។ មហាសន្និបាតលើកនេះ បានប្រព្រឹត្តទៅក្នុងបរិបទដែល UNPO ពិពណ៌នាថា ពិភពលោកកំពុងប្រឈមនឹងការផ្លាស់ប្តូរភូមិសាស្ត្រនយោបាយយ៉ាងឆាប់រហ័ស សម្ពាធកាន់តែខ្លាំងលើប្រព័ន្ធហិរញ្ញវត្ថុ និងបញ្ហាហិរញ្ញប្បទានសម្រាប់អង្គការដែលធ្វើការលើសិទ្ធិមនុស្ស និងសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ ក្នុងឱកាសនេះ សមាជិកបានបញ្ជាក់ជាថ្មីថា ប្រជាជនគ្រប់រូបមានសិទ្ធិកំណត់អនាគតនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ខ្លួន ។



មហាសន្និបាតលើក ២១ នៃ អង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (UNPO) ។ រូបថត៖ ម៉ៅ មុនី

លោក **ម៉ៅ មុនី** ជាប្រធានប្រតិបត្តិ និង លោក **ត្រឹង សារ៉ុង** ជាប្រធានសភាព្រឹទ្ធាចារ្យ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងនាមជាសមាជិក គណៈកម្មការនាយក នៃ UNPO ក៏ត្រូវបានអញ្ជើញឱ្យចូលរួមប្រជុំនៅក្នុងមហាសន្និបាតនេះ ផងដែរ ដើម្បីរាយការណ៍អំពីស្ថានភាពរបស់ខ្មែរក្រោម នៅដែនដីកម្ពុជាក្រោម និងពិភាក្សាលើកិច្ចការរបស់ UNPO ។ សហព័ន្ធខ្មែរកម្ពុជាក្រោម បានចូលជាសមាជិក UNPO នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ និងនៅក្នុងមហាសន្និបាតពិភពលោក លើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលបានរៀបចំនៅរដ្ឋធានី Washington ឌី.ស៊ី. សហរដ្ឋអាមេរិក កាលពីខែកក្កដា ឆ្នាំ ២០២៦ កន្លងទៅនេះ ក៏បានរំឭកដល់ខួប ២៥ ឆ្នាំ ដែលខ្លួនបានចូលជាសមាជិក UNPO ផងដែរ ។

ថ្នាក់ដឹកនាំថ្មី អាណត្តិ ២០២៦-២០២៨ របស់ UNPO៖

មហាសន្និបាតបានបោះឆ្នោតជ្រើសរើសអ្នកស្រី **Rubina Greenwood** មកពី **Sindh** ជាប្រធាន UNPO សម្រាប់អាណត្តិ ២០២៦-២០២៨ ។ លោក **Abdirahman Mahdi** មកពី **Ogaden** និង លោកស្រី **Sofia Amini** មកពី **Iranian Kurdistan** ត្រូវបានជ្រើសរើសជាអនុប្រធាន ខណៈលោកស្រី **Tammy Breedt** មកពី **Afrikaners** ត្រូវបានជ្រើសរើសជាហេរញ្ញិក ។

សមាជិកនៃគណៈនាយកផ្សេងទៀត រួមមាន លោកសមាជិកព្រឹទ្ធសភា **Paul Strauss** មកពី **District ofColumbia** សហរដ្ឋអាមេរិក លោក Mourad Amellal មកពី Kabylia អ្នកស្រីសមាជិកព្រឹទ្ធសភា Tina MunaBarnes មកពីកោះ Guam សហរដ្ឋអាមេរិក នាង **Zumretay Arkin** មកពី **East Turkestan** អ្នកស្រី **Nancy** Sinay មកពី South Moluccas និង Deedagh Jamalzhi មកពី West Balochistan និងអ្នកស្រី **Ariadna Heinz** មកពី **Catalonia** ។

យោងតាម UNPO គណៈកម្មការនាយកថ្មីនឹងបន្តយកប្រធានបទ **"សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង"** ជាចំណុចស្នូលនៃការងារ និងបន្តការតស៊ូមតិដោយសន្តិវិធី ដើម្បីលើកយកបញ្ហា និងបំណងប្រាថ្នារបស់ ប្រជាជាតិ និងប្រជាជនដែលគ្មានតំណាងជូនទៅអ្នកធ្វើសេចក្តីសម្រេចចិត្ត និងស្ថាប័នអន្តរជាតិ ។

ជំរុញការពិភាក្សាអំពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»៖

មហាសន្និបាតនេះ បានធ្វើឡើងបន្ទាប់ពីសន្និសីទក្រោមប្រធានបទ «បញ្ជាក់ឡើងវិញអំពីសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» (**Re-Imagining Self-Determination**) លើកទី ២ ដែលប្រព្រឹត្តទៅ នៅទីក្រុងឡាអេ នាថ្ងៃទី ២៧ និង ២៨ ខែសីហា ក្នុងឱកាសគម្រប់ខួប ៣៥ ឆ្នាំរបស់ **UNPO** ។ សន្និសីទបានផ្តោតលើបញ្ហាតំណាង និងការរួបរួមសាមគ្គីភាពរបស់ប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង ។ ក្នុងសេចក្តីប្រកាសរបស់សន្និសីទ **UNPO** បានបញ្ជាក់ឡើងវិញអំពីសិទ្ធិស្មើគ្នារបស់ប្រជាជនគ្រប់រូបក្នុងការ «សម្រេចវាសនាខ្លួន» និងសិទ្ធិកំណត់អនាគត នៃនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ។ ការពិភាក្សាក៏បានលើកឡើងពីសារៈសំខាន់នៃការចូលរួម និងការតំណាងប្រកបដោយអត្ថន័យ ការការពារប្រវត្តិសាស្ត្រ អត្តសញ្ញាណ និងវប្បធម៌ ព្រមទាំងការរួបរួមគ្នារវាងប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង ។

ជាមួយគ្នានេះ **UNPO** ក៏បានកត់សម្គាល់ពីទាំងឱកាស និងហានិភ័យដែលបច្ចេកវិទ្យាឌីជីថលបង្កើតឡើង សម្រាប់ការតស៊ូមតិដោយរួមមានការឃ្លាំមើល ការបំភិតបំភ័យ និងព័ត៌មានមិនពិត ។

បន្តការងាររួម ដើម្បីពង្រឹងសំឡេងរបស់ប្រជាជាតិគ្មានតំណាង៖

មហាសន្និបាតលើកទី ២១ បានបញ្ចប់ដោយការបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តរបស់ **UNPO**បំពេះ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» និងសិទ្ធិរបស់ប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង ។

UNPO បានអំពាវនាវឱ្យអង្គការក្នុងតំបន់នានា នៅអាហ្វ្រិក អាស៊ី អឺរ៉ុប អាមេរិក មជ្ឈិមបូព៌ា និងតំបន់ប៉ាស៊ីហ្វិក បង្កើតយន្តការ និងវេទិកាអចិន្ត្រៃយ៍ដែលមានអត្ថន័យ ដើម្បីឱ្យប្រជាជាតិ និងប្រជាជនដែលគ្មានតំណាង អាចលើកឡើងពីបញ្ហារបស់ខ្លួនដោយសន្តិវិធី ការពារសិទ្ធិ និងចូលរួមក្នុងការសម្រេចចិត្តដែលប៉ះពាល់ ដល់អនាគតរបស់ពួកគេ ស្របតាមគោលការណ៍សិទ្ធិមនុស្ស សមភាព សេចក្តីថ្លៃថ្នូរ និង «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។

ជាមួយគ្នានេះ មហាសន្និបាតក៏បានថ្លែងអំណរគុណដល់ **លោកស្រី Mercè Monje Cano** សម្រាប់ការបម្រើការងារជាមួយ **UNPO** អស់រយៈពេល ៧ ឆ្នាំ ក្នុងនោះជិត ៤ ឆ្នាំក្នុងតួនាទីអគ្គលេខាធិការ និងបានជូនពរឱ្យលោកស្រីទទួលបានជោគជ័យក្នុងដំណើរ បន្ទាប់របស់ខ្លួន ។

ការប្រជុំនៅទីក្រុងឡាអេបានក្លាយជាចំណុចសំខាន់មួយសម្រាប់ **UNPO** ក្នុងឆ្នាំដែលអង្គការនេះ ប្រារព្ធខួប ៣៥ ឆ្នាំ ដោយបន្តផ្តោតលើការលើកកម្ពស់ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ការតំណាង និងសាមគ្គីភាពរបស់ប្រជាជាតិ និងប្រជាជនដែលមិនទទួលបានតំណាងពេញលេញនៅក្នុងប្រព័ន្ធអន្តរជាតិ ។



លោក ម៉ៅ មុនី ជាប្រធានប្រតិបត្តិ និង លោក ត្រឹង សារ៉ុង ជាប្រធានព្រឹទ្ធាចារ្យ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលរួមប្រជុំនៅក្នុងមហាសន្និបាតលើកទី ២១ នៃ UNPO ។ រូបថត៖ ម៉ៅ មុនី

តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ថ្លែងអំពីបញ្ហាសិទ្ធិមនុស្ស ភាសា និងវប្បធម៌របស់ខ្មែរក្រោមនៅវេទិកាជនជាតិដើម (UNPFII)

ដោយ **ថាប់ ប្រ៊ីជា គឿន**

ញូវយ៉ក សហរដ្ឋអាមេរិក – តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម បានចូលរួម និងថ្លែងការណ៍ជាបន្តបន្ទាប់ នៅក្នុងវេទិកាអចិន្ត្រៃយ៍ អ.ស.ប.ស្តីពីបញ្ហាជនជាតិដើម ឬ **UNPFII** ដែលប្រព្រឹត្តទៅនៅទីស្នាក់ការកណ្តាល អ.ស.ប. នាទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី ២០ ខែមេសា ដល់ថ្ងៃទី ១ ខែឧសភា ឆ្នាំ ២០២៦ ។ វេទិកាឆ្នាំនេះ ផ្តោតលើប្រធានបទ **«ការធានាសុខភាពរបស់ជនជាតិដើម និងបញ្ហាជម្លោះ»** ។



តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ថ្លែងការណ៍នៅក្នុងវេទិកាអចិន្ត្រៃយ៍នៃ អ.ស.ប. ស្តីពីបញ្ហាជនជាតិដើម (UNPFII) ពីថ្ងៃទី ២០ ខែមេសា ដល់ ១ ខែឧសភា ឆ្នាំ ២០២៦ ។ រូបថត៖ UN.tv

នៅព្រឹកថ្ងៃទី ២០ ខែមេសា តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលដឹកនាំដោយលោក **ម៉ៅ មុនី** អនុប្រធានទីមួយនៃសហព័ន្ធ បានចាប់ផ្តើមចូលរួមក្នុងវេទិកា ដើម្បីសង្កេតការណ៍ រាយការណ៍ និងលើកពីបញ្ហាកង្វល់របស់ជនជាតិដើមខ្មែរក្រោមនៅកម្ពុជាក្រោម ជូនដល់វេទិកា អ.ស.ប. ។

នៅថ្ងៃដដែល លោក **Kennedy Son** ជាតំណាង **ស.ខ.ក.** បានថ្លែងការណ៍នៅក្នុងវេទិកា ដោយលើកឡើងពីបញ្ហារបស់ខ្មែរក្រោម និងស្ថានភាពសិទ្ធិមនុស្សនៅដែនដីកម្ពុជាក្រោម ។ ការចូលរួមនេះត្រូវបានសហព័ន្ធចាត់ទុកថា ជាឱកាសមួយសម្រាប់នាំយកបញ្ហារបស់ពលរដ្ឋខ្មែរក្រោមទៅកាន់វេទិកាអន្តរជាតិ ។

បន្ទាប់មក នៅថ្ងៃទី ២១ ខែមេសា នាង **Emily Hang** ជាតំណាង **ស.ខ.ក.** បានឡើងថ្លែងការណ៍នៅក្នុង UNPFII ដោយលើកឡើងពីបញ្ហារបស់ខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ។ ការថ្លែងការណ៍របស់នាងស្ថិតក្នុងបរិបទនៃការពិភាក្សាអំពីសិទ្ធិ និងបញ្ហាប្រឈមរបស់ជនជាតិដើមនៅក្នុងវេទិកា អ.ស.ប. ។

នៅព្រឹកថ្ងៃទី២២ ខែមេសា នាង **Mary Son** ជាតំណាង **ស.ខ.ក.** បានថ្លែងការណ៍ដោយលើកឡើងអំពីអ្វីដែលនាងបានពិពណ៌នាថា ជាការរឹតត្បិត និងការរំលោភសិទ្ធិរបស់ពលរដ្ឋខ្មែរក្រោម ។ ក្នុងនោះមានការលើកឡើងពីករណីចាប់ខ្លួន និងចាត់វិធានការលើព្រះសង្ឃ និងសកម្មជនសិទ្ធិមនុស្ស ព្រមទាំងករណីថ្មីបំផុត ដែលតុលាការរបបយួនថ្ងៃទី ២២ ខែមេសា ត្រូវបំពង់ដែលតំណាងសហព័ន្ធឡើងថ្លែងការណ៍តែម្តង បានប្រកាសផ្តន្ទាទោសសកម្មជនខ្មែរក្រោមម្នាក់ គឺអ្នកស្រី **រដ្ឋ វ៉ាំរី** អាយុ ៥៥ ឆ្នាំនៅស្រុកកំពង់ស្ពាន ខេត្តព្រះត្រពាំង ឱ្យជាប់ពន្ធនាគារ **៣ ឆ្នាំ ៦ ខែ** ពីបទ «កេងបំណោញលើសិទ្ធិសេរីភាព និងលទ្ធិប្រជាធិបតេយ្យ» តាមមាត្រា ៣៣១ នៃក្រមព្រហ្មទណ្ឌវៀតណាម ។ ករណីនេះត្រូវបានតំណាង **ស.ខ.ក.** លើកឡើងជាបញ្ហាសិទ្ធិមនុស្សដែលគួរឱ្យយកចិត្តទុកដាក់ ។

នៅថ្ងៃទី ២៧ ខែមេសា លោក **Kennedy Son** បានថ្លែងការណ៍ជាថ្មី ដោយផ្តោតលើបញ្ហាភាសា វប្បធម៌ និងហានៈរបស់ជនជាតិដើមខ្មែរក្រោម ។ លោកបានស្នើឱ្យស្ថាប័នពាក់ព័ន្ធរបស់ អ.ស.ប. រួមមាន **UNESCO** ចូលរួមជួយការពារ និងលើកកម្ពស់ភាសា និងវប្បធម៌របស់ខ្មែរក្រោម ។ លោកក៏បានស្នើឱ្យ **UNDP** ជួយផ្សព្វផ្សាយ និងបកប្រែសេចក្តីប្រកាស អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម (**UNDRIP**) ឱ្យកាន់តែងាយស្រួលដល់ពលរដ្ឋខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ។

នៅក្នុងសេចក្តីថ្លែងការណ៍ លោក Kennedy Son ក៏បានលើកឡើងពីការកំណត់អត្តសញ្ញាណជាតិរបស់ខ្មែរក្រោម ដោយបង្ហាញគោលជំហររបស់ **ស.ខ.ក.** ថា ខ្មែរក្រោមគួរត្រូវបានទទួលស្គាល់ក្នុងនាមជា **«ជនជាតិដើម»** ហើយមិនគួរត្រូវបានកំណត់ត្រឹមតែជាក្រុម



តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម ថតរូបជុំគ្នានៅក្នុងវេទិកាអចិន្ត្រៃយ៍នៃ អ.ស.ប. ស្តីពីបញ្ហាជនជាតិដើម (UNPFII) ថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០២៦ ។ រូបថត៖ ម៉ៅ មុនី

«ជនជាតិភាគតិច» នោះទេ ។

នៅថ្ងៃទី ២៩ ខែមេសា តំណាងសហព័ន្ធពីររូបបានថ្លែងការណ៍នៅក្នុងវេទិកា ។ នាង **Emily Hang** ក្នុងនាមជាតំណាងយុវជនខ្មែរក្រោម បានលើកឡើងពីបញ្ហារបស់ជនជាតិដើមនៅអាស៊ី និងបានផ្តល់អនុសាសន៍ដល់អង្គការសហប្រជាជាតិ ឱ្យយកចិត្តទុកដាក់បំពេញផលប្រយោជន៍ និងសិទ្ធិរបស់ជនជាតិដើមនៅក្នុងតំបន់ ។

នៅថ្ងៃដដែល នាង **Connie Hang** ជាតំណាង **ស.ខ.ក.** បានថ្លែងការណ៍លើវិស័យអប់រំ និងការរក្សាភាសាខ្មែរ ។ នាងបានស្នើឱ្យអ្នកជំនាញ និងស្ថាប័នពាក់ព័ន្ធរបស់ អ.ស.ប. ជំរុញឱ្យមានការផ្តល់លទ្ធភាពសិក្សាភាសាខ្មែរនៅក្នុងប្រព័ន្ធសាលារៀនសាធារណៈសម្រាប់កុមារ និងយុវជនខ្មែរក្រោមនៅជៃនដីកម្ពុជាក្រោម ។

ជារួម ការចូលរួមរបស់តំណាង ស.ខ.ក. នៅក្នុង UNPFII ឆ្នាំ ២០២៦ បានផ្តោតលើប្រធានបទសំខាន់ៗជាច្រើន រួមមាន **សិទ្ធិមនុស្ស សិទ្ធិជនជាតិដើម សេរីភាពសាសនា ភាសា វប្បធម៌ ការអប់រំ និងការអនុវត្តសិទ្ធិតាម សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម (UNDRIP)** ។ សហព័ន្ធខ្មែរកម្ពុជាក្រោម បានបញ្ជូនតំណាងរបស់ខ្លួនចូលរួមប្រជុំនៅក្នុងវេទិកានេះជារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៤ ដើម្បីរាយការណ៍ សង្កេតការណ៍ និងថ្លែងការណ៍អំពីបញ្ហាកង្វល់របស់ខ្មែរក្រោមទៅកាន់សហគមន៍អន្តរជាតិ ។

វេទិកាជនជាតិដើម UNPFII ជាស្ថាប័នប្រឹក្សាជាន់ខ្ពស់របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម (ECOSOC) ដែលបានបង្កើតឡើងនៅថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០០ ។ វេទិកានេះធ្វើការលើវិស័យសំខាន់ៗបំនួនប្រាំមួយ គឺការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម វប្បធម៌ បរិស្ថាន ការអប់រំ សុខភាព និងសិទ្ធិមនុស្ស ។ តាមរយៈការផ្តល់យោបល់ និងអនុសាសន៍ដល់ប្រព័ន្ធអង្គការសហប្រជាជាតិ (UNPFII) ជំរុញការយល់ដឹងអំពីបញ្ហារបស់ជនជាតិដើម និងការអនុវត្តសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើម (UNDRIP) ឱ្យបានពេញលេញ ។

សម្រាប់ឆ្នាំ ២០២៦ ជាសម័យប្រជុំលើកទី ២៥ របស់ UNPFII ផ្តោតលើប្រធានបទ «ការធានាសុខភាពរបស់ជនជាតិដើម និងបញ្ហាជម្លោះ» ។ ក្នុងបរិបទនេះ ការចូលរួមរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម មានសារៈសំខាន់ក្នុងការតាំសំឡេង និងកង្វល់របស់ជនជាតិដើមខ្មែរក្រោមទៅកាន់វេទិកាអន្តរជាតិ ព្រមទាំងភ្ជាប់បញ្ហារបស់ពលរដ្ឋទៅនឹងក្របខ័ណ្ឌសិទ្ធិជនជាតិដើមរបស់អង្គការសហប្រជាជាតិ ។ វេទិកានេះផ្តល់ឱកាសសម្រាប់ការតស៊ូមតិ ការកសាងកិច្ចសហការ និងការជំរុញឱ្យអនុសាសន៍អន្តរជាតិក្លាយជាការអនុវត្តជាក់ស្តែង ដើម្បីឱ្យខ្មែរក្រោមអាចរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ រក្សាអត្តសញ្ញាណ និងចូលរួមសម្រេចចិត្តលើអនាគតរបស់ខ្លួន ៕

សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម រដ្ឋវ៉ាស៊ីនតោន ប្រារព្ធពិធីរំឭកខួប ២៥ ឆ្នាំ ថ្ងៃ ស.ខ.ក. ចូលជាសមាជិក UNPO



ថ្នាក់ដឹកនាំ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ចូលរួមពិធីអបអរសាទរ ខួប ២៥ ឆ្នាំ ដែល ស.ខ.ក. បានចូលជាសមាជិកអង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង (UNPO) ប្រារព្ធដោយ សាខា ស.ខ.ក. នៅរដ្ឋ Washington State ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០២៦ ។
រូបថត៖ KKFWA

ដោយ **តាំង សារៈ**

សាខា **ស.ខ.ក.** នៃរដ្ឋ Washington បានប្រារព្ធពិធីរំឭកខួប ២៥ ឆ្នាំ នៃ **ស.ខ.ក.** ត្រូវបាន**អង្គការប្រជាជាតិ និងប្រជាជនគ្មានតំណាង** ដែលហៅកាត់ថា UNPO ទទួលស្គាល់ជាសមាជិកពេញសិទ្ធិ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០១ ។

ពិធីនេះប្រារព្ធធ្វើឡើងនៅអគារ AMVET POST # ONE នាទីក្រុង TACOMA រដ្ឋ Washington សហរដ្ឋអាមេរិក កាលពីថ្ងៃទី ១ ខែសីហា ឆ្នាំ ២០២៦ ក្រោមការផ្តើមរៀបចំដោយលោកព្រឹទ្ធាចារ្យ **បៅ រៀប** ជាអតីតប្រធានសភាព្រឹទ្ធាចារ្យ នៃ **ស.ខ.ក.** លោក **ឡឹម តែម** ជាប្រធានសាខា **ស.ខ.ក.** រដ្ឋវ៉ាស៊ីនតោន និងលោក **បៅ សេរី** ជាឧបការីលោកអធិបតីសហព័ន្ធ ដោយមានអ្នកគាំទ្រចូលរួមប្រមាណជាជាង ២០០ នាក់ ។

អង្គពិធីនេះ ក៏មានការអញ្ជើញចូលរួមជាគណៈអធិតីពីសំណាក់លោក Harry van Bommel ជាអតីតសមាជិករដ្ឋសភា នៃប្រទេសហុល្លង់ លោក សឺន ហួរ ជាអធិបតី លោក ត្រឹង សារ៉ុង ជាប្រធានសភាព្រឹទ្ធាចារ្យ អញ្ជើញមកពីប្រទេសអ៊ីតាលី លោក ម៉ៅ មុនី ជាប្រធានប្រតិបត្តិ លោកស្រី កៀង សុធី ជាអនុប្រធានប្រតិបត្តិ នៃ **ស.ខ.ក.** លោក តាំង សារៈ ជាប្រធាន សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំតំបន់កម្ពុជា មកពីព្រះរាជាណាចក្រកម្ពុជា និង លោក ថាប់ សាម៉ន ជាហេរញ្ញិក នៃ **ស.ខ.ក.** ផងដែរ ។

ក្រោយការគោរពទង់ជាតិ គោរពវិញ្ញាណក្ខន្ធ និងព្រះសង្ឃ ៤ ព្រះអង្គស្ងួត្រស្ងាធ្យាយជ័យបរិត្ត (ជ័យន្តោ) ប្រសិទ្ធពរជ័យជូនអង្គពិធីរួបមក លោក សឺន ហួរ ជាអធិបតីសហព័ន្ធ បានថ្លែងសុន្ទរកថាបើកអង្គពិធីដោយបានប្រគេន និងជម្រាបព្រះសង្ឃ និងប្រាប់ពលរដ្ឋដែលវត្តមានក្នុងអង្គពិធីជាអាទិ៍ថា ចាប់តាំងពី **ស.ខ.ក.** បានចូលជាសមាជិក UNPO មក អង្គការនេះបានជួយធ្វើកិច្ចអន្តរាគមន៍អំពីបញ្ហាខ្មែរក្រោម



លោក ម៉ៅ មុនី ជាប្រធានប្រតិបត្តិ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ថ្លែងនៅក្នុងអង្គពិធី នារាត្រីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០២៦ ។ រូបថត៖ KKFWA

លើរាល់បញ្ហាជាប្រើនៅលើឆាកអន្តរជាតិ រហូតដល់ទទួលបានបទពិសោធន៍ដើម្បីទំនាក់ទំនងជាមួយអន្តរជាតិ ធ្វើឱ្យអង្គការរដ្ឋាភិបាលនិងជនជាតិជាប្រើនៅលើពិភពលោកបានស្គាល់ខ្មែរក្រោម និងជួយលើកិច្ចការជាប្រើនរបស់ខ្មែរក្រោម ។

ក្នុងឱកាសនោះដែរ លោក **ម៉ៅ មុនី** ប្រធានប្រតិបត្តិ និងអ្នកស្រី កៀង សុធី អនុប្រធានប្រតិបត្តិ **ស.ខ.ក.** បានជម្រាបជូនអង្គពិធីនូវសកម្មភាពដែលសហព័ន្ធបានធ្វើក្នុងអាណត្តិកន្លងមក ជាពិសេស គឺជាវិបានទីស្នាក់ការ **ស.ខ.ក.** នៅរដ្ឋធានី Washington ឌីស៊ី ដែលធ្វើឱ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម មានលំនឹងកាន់តែរឹងមាំ ដើម្បីធ្វើការបម្រើដល់ពលរដ្ឋខ្មែរក្រោម ដែលកំពុងរស់នៅក្នុងទឹកដីកម្ពុជាក្រោម និងនៅលើពិភពលោក ។ មួយវិញទៀត ទីស្នាក់ការរបស់ **ស.ខ.ក.** បានប្រតិស្ថាននៅបំកណ្តាលបេះដូង នៃប្រទេសមហាអំណាចពិភពលោកយ៉ាងនេះ ធ្វើឱ្យខ្មែរក្រោមមានកិត្តិយស និងកិត្តិស័ព្ទល្បីរន្ធឹទូទាំងពិភពលោកទាំងមូលដែលគេកាន់តែដឹង កាន់តែស្គាល់ថា ខ្មែរក្រោមជាអ្នកណា? រស់នៅទីណា? និងបានស្គាល់កាន់តែប្បាស់ នូវវីរបុរសខ្មែរក្រោម គឺ ឧកញ៉ា សឺន គុយ ទៀតផង ។

នៅក្នុងឱកាសនោះ ក៏មានការប្រគល់នូវលិខិតតែងតាំងព្រឹទ្ធបារ្យ **ចៅ រៀប** អតីតប្រធានសភាព្រឹទ្ធបារ្យ នៃ **ស.ខ.ក.** ជាឧត្តមទីប្រឹក្សា **ស.ខ.ក.** និងលិខិតតែងតាំងលោក **ចៅ សេរី** អតីតហេរញ្ញិក **ស.ខ.ក.** ទៅជាឧបការីលោកអធិបតី **ស.ខ.ក.** ដោយលិខិតតែងតាំងនោះត្រូវបានប្រគល់ជូនដោយលោក **សឺន ហួរ** ជាអធិបតី **ស.ខ.ក.** ដោយផ្ទាល់ ។

បុងបញ្ចប់នៃកម្មវិធី លោក **ឡឹម តែម** ប្រធានសាខា **ស.ខ.ក.** ប្រចាំរដ្ឋវ៉ាស៊ីងតោន បានថ្លែងនូវសោមនស្សរីកថា និងអរគុណថា បំពោះគណៈអធិបតី ភ្ញៀវកិត្តិយស ទឹងអ្នកចូលរួមទាំងអស់ដែលញុំាងឱ្យពិធីទាំងមូល បានប្រព្រឹត្តទៅដោយភាពរលូនឡើយអធិកអធម យ៉ាងក្រៃលែង ។

អង្គពិធីក៏មានពិធីជប់លៀងអាហារពេលរាត្រី និងពិធីរាំកម្សាន្តផងដែរ ។

ពិធីនេះបានបញ្ចប់ទៅវិញនៅវេលាម៉ោង ២៤ យប់ក្នុងថ្ងៃនោះ ក្នុងបរិយាកាសសប្បាយរីករាយ និងមិត្តភាពយ៉ាងស្និទ្ធស្នាល ។



ព្រះសង្ឃ ថ្នាក់ដឹកនាំ និងសមាជិក ស.ខ.ក. ថតរូបជុំគ្នានៅក្នុងអង្គពិធី ។ រូបថត៖ KKFWA

សហព័ន្ធខ្មែរកម្ពុជាក្រោម ផ្តោលទោសតុលាការយួន ប្រកាសផ្តន្ទាទោសខ្មែរក្រោម ៣ រូប ឱ្យជាប់ពន្ធនាគារ ដោយគ្រាន់តែអនុវត្តសិទ្ធិរបស់ខ្លួន



អ្នកស្រី រដ្ឋ វ៉ារី, លោក ថាច់ ចិន្ត្រា, អ្នកស្រី ចូវ ធី ទៀង នៅក្នុងតុលាការរបបអាណានិគមយួន ។

តុលាការវៀតណាមបានប្រកាសផ្តន្ទាទោសពលរដ្ឋខ្មែរក្រោម បីរូបឱ្យជាប់ពន្ធនាគារនៅក្នុងឆ្នាំ ២០២៦ ។ **ស.ខ.ក.** បានប្តោលទោសសាលក្រមទាំងនេះ ដោយចាត់ទុកថាជាការបង្ក្រាបលើពលរដ្ឋខ្មែរក្រោម ដោយគ្រាន់តែពួកគាត់បញ្ចេញមតិ និងធ្វើការតស៊ូមតិដោយសន្តិវិធី ។

ជំបូង នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០២៦ អ្នកស្រី **រដ្ឋ វ៉ារី** (Thach Thi Hoa Ri) នៅស្រុកកំពង់ស្ពាន ខេត្តព្រះត្រពាំង ត្រូវផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ៣ ឆ្នាំ ៦ ខែ ។ មុនពេលចាប់ខ្លួន អ្នកស្រីតែងតែចូលរួមសកម្មភាពតស៊ូមតិ ដើម្បីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ក្នុងនោះ មានប្រារព្ធទិវាតារីអន្តរជាតិ ការពារអត្តសញ្ញាណជនជាតិដើម និងថែរក្សាសិទ្ធិវប្បធម៌របស់ខ្មែរក្រោម ។

អ្នកស្រី **រដ្ឋ វ៉ារី** ត្រូវអាជ្ញាធររបបអាណានិគមយួនចាប់ខ្លួន នៅថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០២៤ ។

បន្ទាប់មក នៅថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០២៦ លោក **ថាច់ ចិន្ត្រា** (Thach Chanh Tra) នៅខេត្តព្រះត្រពាំង ត្រូវតុលាការប្រជាជនតំបន់ទី ១៣ នៃខេត្តសង់ហោរ ផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ៣ ឆ្នាំ ៦ ខែ ។ ការចោទប្រកាន់ពាក់ព័ន្ធនឹងវីដេអូការផ្សាយផ្ទាល់ និងសារលើបណ្តាញសង្គមដែលលោកបានបញ្ចេញមតិអំពីបញ្ហារបស់ខ្មែរក្រោម និងបញ្ហាទំនាស់ដីធ្លី ដែលលោកចាត់ទុកថា ដីកេររបស់លោកត្រូវគេរឹបយក ។

លោក **ថាច់ ចិន្ត្រា** ត្រូវអាជ្ញាធររបបអាណានិគមយួនចាប់ខ្លួន នៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០២៦ ។

បុងក្រោយ នៅថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២៦ អ្នកស្រី **ចូវ ធី ទៀង** (Chau Thi Thien) អាយុ ៧២ ឆ្នាំ នៅខេត្តឃ្លាំង ត្រូវតុលាការប្រជាជនតំបន់ទី ៦ នៅទីក្រុងព្រែកឫស្សី ផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ២ ឆ្នាំ ៦ ខែ ។ សំណុំរឿងនេះពាក់ព័ន្ធនឹងការបញ្ចេញមតិតាមហ្វេសប៊ុក ក្នុងឆ្នាំ ២០២៣ ដែលមានប្រភពបេញពីវិវាទដីធ្លី ។

អ្នកស្រី **ចូវ ធី ទៀង** ត្រូវអាជ្ញាធររបបអាណានិគមយួនចាប់ខ្លួន នៅថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០២៦ ។

ករណីទាំងបីខាងលើ តុលាការយួនបានចោទប្រកាន់ពលរដ្ឋខ្មែរក្រោមថា បានបំពានមាត្រា ៣៣១ នៃក្រមព្រហ្មទណ្ឌវៀតណាម ស្តីពីបទអ្វីដែលរបបយួនហៅថា «កេងបំណោញលើសិទ្ធិសេរីភាព និងប្រជាធិបតេយ្យ....» ។

សហព័ន្ធខ្មែរកម្ពុជាក្រោម បានចេញសេចក្តីថ្លែងការណ៍ ចាត់ទុកមាត្រានេះថាមានខ្លឹមសារមិនច្បាស់លាស់ និងត្រូវបានប្រើដើម្បីដាក់ទោសអ្នកបញ្ចេញមតិដោយសន្តិវិធី ។ សហព័ន្ធខ្មែរកម្ពុជាក្រោម ក៏បានអំពាវនាវឱ្យដោះលែងអ្នកទាំងបីជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ព្រមទាំងបញ្ឈប់ការប្រើមាត្រា ៣៣១ ដើម្បីបង្ក្រាបសិទ្ធិសេរីភាពបញ្ចេញមតិ ។ សហព័ន្ធ ក៏បានស្នើ ឱ្យ អ.ស.ប. និងរដ្ឋាភិបាលដែលមានកិច្ចសន្ទនាសិទ្ធិមនុស្សជាមួយវៀតណាម លើកយកករណីទាំងនេះ និងជំរុញឱ្យមានការគោរពសិទ្ធិរបស់ពលរដ្ឋខ្មែរក្រោម ៕

សហព័ន្ធខ្មែរកម្ពុជាក្រោម និង GHRD ជាក់ញត្តិជូនសភាហុល្លង់ ជម្រាបអំពីសិទ្ធិមនុស្ស និងយុត្តិធម៌អាកាសធាតុ នៅជែនដីកម្ពុជាក្រោម

ដោយ **ថាប់ ប្រ៊ីជា គឿន**

នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២៦ តំណាង ស.ខ.ក. (KKF) រួមមាន លោក **ត្រឹង បន្ទូសារ៉ាត** លោក **លី សឿង** អ្នកនាង **គឹម ពុទ្ធានី** និង លោក **ហារី វ៉ាន់ ប៊ូមែល** (Harry Van Bommel) រួមជាមួយអង្គការដៃគូ គឺ អង្គការការពារសិទ្ធិមនុស្សសកល (GHRD) បានដាក់ញត្តិជូនសមាជិកសភាហុល្លង់ នៅទីក្រុងឡាអេ ។ ញត្តិនេះលើកឡើងពីបញ្ហាសិទ្ធិមនុស្ស និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុបំពេះជនជាតិដើមខ្មែរក្រោមនៅកម្ពុជាក្រោម និងអំពាវនាវឱ្យប្រទេសហុល្លង់បន្តលើកកម្ពស់សិទ្ធិមនុស្ស ក្នុងការធ្វើធុរកិច្ចប្រកបដោយការទទួលខុសត្រូវ និងយុត្តិធម៌អាកាសធាតុ ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងរដ្ឋការវៀតណាម ។



តំណាង ស.ខ.ក. នាំញត្តិជូនសមាជិកសភា ប្រទេសហុល្លង់ ថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០២៦ ។ រូបថត៖ Harry van Bommel


ក្នុងជំនួបនោះ តំណាង ស.ខ.ក. បានបង្ហាញថា ការកើនឡើងទឹកសមុទ្រ ការជ្រៀតចូលទឹកប្រៃ ការស្រុតដី និងការខូចខាតបរិស្ថាន កំពុងគំរាមកំហែងដល់ជីវភាព សន្តិសុខស្បៀង និងអត្តសញ្ញាណរបស់ជនជាតិដើមខ្មែរក្រោម ។ GHRD បានបញ្ជាក់ថា គម្រោងអភិវឌ្ឍន៍ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវមានតម្លាភាព និងការចូលរួមប្រកបដោយអត្ថន័យពីជនជាតិដើម ព្រមទាំងត្រូវគោរពគោលការណ៍នៃការយល់ព្រមដោយសេរីជាមុន និងដោយទទួលបានព័ត៌មានគ្រប់គ្រាន់ (FPIC) ។

ស.ខ.ក. ក៏បានលើកឡើងពីកង្វល់បំពេះការបង្ក្រាបព្រះសង្ឃ អ្នកការពារសិទ្ធិមនុស្ស និងសកម្មជនខ្មែរក្រោម ដែលតស៊ូមតិដោយសន្តិវិធី ដើម្បីសេរីភាពសាសនា សិទ្ធិវប្បធម៌ និងការទទួលស្គាល់ជាជនជាតិដើម ។ តំណាងសហព័ន្ធបានជម្រាប សមាជិកសភាអំពីករណីជាប់ពន្ធនាគាររបស់ព្រះតេជព្រះគុណ **ថាប់ បន្ធារា** ព្រះតេជព្រះគុណ **គឹម សំរិទ្ធ** និងសកម្មជន មួយចំនួនទៀត ព្រមទាំងបង្ហាញកង្វល់អំពីការប្រើប្រាស់មាត្រា ៣៣១ នៃក្រមព្រហ្មទណ្ឌវៀតណាម ដើម្បីដាក់ទោសការបញ្ចេញមតិ និងការតស៊ូមតិដោយសន្តិវិធីរបស់ខ្មែរក្រោម ។

ក្នុងឱកាសនេះ ស.ខ.ក. បានប្រគល់ឯកសារសង្ខេប អនុសាសន៍គោលនយោបាយ និងឯកសារស្រាវជ្រាវ ដើម្បីជំរុញការតាមដានការអនុវត្តកាតព្វកិច្ចសិទ្ធិមនុស្ស ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសហភាពអឺរ៉ុប និងវៀតណាម (EVFTA) ។ អង្គការទាំងពីរបានថ្លែងអំណរគុណដល់សភាហុល្លង់ដែលទទួលញត្តិ និងបានអំពាវនាវឱ្យធានាថា សំឡេងរបស់ខ្មែរក្រោមត្រូវបានបញ្ចូលក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់អនាគតរបស់ពួកគេ ដើម្បីការពារភាសា វប្បធម៌ ប្រពៃណីព្រះពុទ្ធសាសនា និងសិទ្ធិរស់នៅដោយសេចក្តីថ្លៃថ្នូរលើទឹកដីដូនតា ។

លោក **ហារី វ៉ាន់ ប៊ូមែល** ជាអតីតសមាជិកសភានៃប្រទេសហុល្លង់ និងជាអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម យ៉ាងសកម្ម បានសរសេរព័ណ៌នារឿងនេះនៅលើទំព័រ Facebook របស់ខ្លួនថា ជនជាតិដើមខ្មែរក្រោមនៅតំបន់ដីសណ្ដទន្លេមេគង្គ ក្នុងប្រទេសវៀតណាម កំពុងតែប្រឈមនឹងការកើនឡើងនៃទឹកសមុទ្រ ការជ្រាបចូលនៃទឹកប្រៃ ការស្រុតដី និងបញ្ហាបរិស្ថាន ដែលគំរាមកំហែងដល់សន្តិសុខស្បៀង ជីវភាព និងការរស់រានរបស់សហគមន៍ ។ ទោះបីរងផលប៉ះពាល់ដោយផ្ទាល់ក៏ដោយ ពលរដ្ឋខ្មែរក្រោមភាគច្រើនមិនបានចូលរួមក្នុងការសម្រេចចិត្តលើគោលនយោបាយ បន្សាំនឹងការប្រែប្រួលអាកាស

ធាតុ និងការអភិវឌ្ឍប្រកបដោយបីរភាពឡើយ ។ អត្ថបទក៏លើកឡើងថា ខ្មែរក្រោមជាប្រើនបានភៀសខ្លួនទៅកម្ពុជា ។ ដើម្បីទាមទារការយកចិត្តទុកដាក់ចំពោះបញ្ហានេះ សហព័ន្ធខ្មែរកម្ពុជាក្រោម និងអង្គការ Global Human Rights Defence បានដាក់ញត្តិទៅរដ្ឋសភាប្រទេសហុល្លង់ ដោយធ្វើការអំពាវនាវឱ្យក្រុមហ៊ុនហុល្លង់ ដែលធ្វើអាជីវកម្មជាមួយវៀតណាម ត្រូវប្រកាន់ខ្ជាប់ទំនួលខុសត្រូវសង្គម និងឱ្យអ្នកនយោបាយតាមដានការអនុវត្តរបស់វៀតណាម ។ លោកបានបញ្ជាក់ថា តំណាងរាស្ត្រនៃប្រទេសហុល្លង់ ដូចជា លោក Maes Van Lanschot លោក Henk Vermeer និង លោកស្រី Sarah Dobbe បានទទួលញត្តិនេះ ។ លោកស្រី Sarah Dobbe ដែលបេះនិយាយភាសាខ្មែរយ៉ាងស្ទាត់ជំនាញ បានធ្វើឱ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម មានក្តីសង្ឃឹមបំពេញកិច្ចសហការនាពេលខាងមុខ ។



អ្នកនាង **គីម ពុទ្ធធានី** អានញត្តិរបស់ ស.ខ.ក. ។

ឈ្មោះដើមរបស់ខ្មែរចារលើទឹកដី យួនប្តូរឈ្មោះថ្មីចារលើក្រដាស



ឈ្មោះភូមិសាស្ត្រនៅដែនដីកម្ពុជាក្រោម ចារជាប់នឹងទឹកដីធម្មជាតិ និងមានប្រវត្តិសាវតារដំណើរដើមទងបុស្សគល់ច្បាស់លាស់ណាស់ ។ ដូចជាឈ្មោះភូមិស្រុក ខេត្ត ជ្រលងដងអូរ ទន្លេបឹងបួរ ដងព្រៃ ភ្នំ និងវត្តអារាមជាដើម សុទ្ធតែកើតចេញពីអ្នកស្រុកហៅជាប់មាត់ តាមដំណើររឿងរ៉ាវ ដែលបានកើតឡើងជាក់ស្តែងនៅតាមទីតាំងនីមួយៗ បានជាឈ្មោះទាំងនោះ នៅតែត្រូវបានប្រជាពលរដ្ឋ ឬអ្នកស្រុកនិយមហៅជាប់មាត់ និងតពីជំនាន់មួយទៅជំនាន់មួយ មិនប្រែប្រួល បើទោះបីមានការព្យាយាមលុបបំបាត់ពីពួកអាណានិគមយ៉ាងណាក៏ដោយ ។ ចំណែកឈ្មោះជាភាសាយួន ជាឈ្មោះ ដែលរដ្ឋការ ឬពួកអាណានិគមបង្កើតឡើង កត់ត្រានៅលើក្រដាស ដើម្បីយកមកគ្របដណ្តប់លើផែនដី ក្នុងចេតនាលុបបំបាត់ភស្តុតាង និងអត្តសញ្ញាណដើម នៃជនជាតិដើមខ្មែរក្រោម ។ រូបថត៖ ថាច់ ប្រីជា គឿន

មហាសន្និបាតពិភពលោក លើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម

ប្រធានបទ "សាមគ្គីដើម្បីអនាគតរបស់យើង ផ្តល់សិទ្ធិអំណាចដល់ពលរដ្ឋខ្មែរក្រោមគ្រប់រូប ការតស៊ូមតិដើម្បីសិទ្ធិនៃប្រជាជនរបស់យើង"

បាវចនា "សំឡេងនីមួយ។ សុទ្ធតែសំខាន់ ។ សកម្មភាពនីមួយ។ សុទ្ធតែមានតម្លៃ"

មហាសន្និបាតពិភពលោកលើកទី ១២ នៃសហព័ន្ធខ្មែរកម្ពុជាក្រោម បានប្រព្រឹត្តទៅពីថ្ងៃទី ១៧ ដល់ថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ ២០២៦ នៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. សហរដ្ឋអាមេរិក ក្រោមប្រធានបទ «សាមគ្គីដើម្បីអនាគតរបស់យើង» ដោយមានថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រមកពីជុំវិញពិភពលោកចូលរួម ។ អង្គមហាសន្និបាតបានបោះឆ្នោតជ្រើសរើសគណៈកម្មការនាយកសម្រាប់អាណត្តិ ២០២៦–២០៣០ កំណត់ផែនការសកម្មភាព និងអនុម័ត «សេចក្តីប្រកាសក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ២០២៦» ដែលមានគោលការណ៍ ១០ ចំណុច សំដៅពង្រឹងសាមគ្គីភាព ការពារសិទ្ធិមនុស្ស និងអត្តសញ្ញាណជនជាតិដើមខ្មែរក្រោម ពង្រីកការតស៊ូមតិ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងធានានិរន្តរភាពនៃចលនាតស៊ូរបស់សហព័ន្ធ។ នៅថ្ងៃទី ១៧ ខែកក្កដា សហព័ន្ធបានរៀបចំកិច្ចប្រជុំបិទទ្វារ ដើម្បីបូកសរុបចំណូលចំណាយ បញ្ចប់ការទូទាត់ប្រាក់កម្ចីសម្រាប់ការទិញ និងជួសជុលទីស្នាក់ការ បិទបញ្ជី «ក្រាំងមាសកត់ត្រា» និងពិនិត្យរបៀបវារៈមហាសន្និបាត ។

ខាងក្រោមនេះជា «កំណត់ហេតុ» ដែលបានកត់ត្រា និងរៀបរៀងដោយ ព្រះតេជព្រះគុណ សឹង ឃ៊ីង រតនា លេខាធិការ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម៖



ព្រះសង្ឃ ថ្នាក់ដឹកនាំ និងសមាជិក នៃ សហព័ន្ធខ្មែរកម្ពុជាក្រោមថតរូបជុំគ្នា នៅមុខ ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម ។

ថ្ងៃសៅរ៍ ទី ១៨ ខែកក្កដា ឆ្នាំ ២០២៦

បាប់ពីម៉ោង ៩:០០ ព្រឹក

នៅទីស្នាក់ការសហព័ន្ធខ្មែរកម្ពុជាក្រោម នារដ្ឋធានីវ៉ាស៊ីនតោន ឌីស៊ី សហរដ្ឋអាមេរិកអង្គមហាសន្និបាតលើកទី ១២ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក សឺន ហួរ អធិបតីសហព័ន្ធខ្មែរកម្ពុជាក្រោម ។

អង្គមហាសន្និបាតលើកទី ១២ បានប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក រួមមានការបុះវត្តមាន ការគោរពទង់ជាតិកម្ពុជាក្រោម ការគោរពព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធព្រះវីរសមណៈ និងវីរបុរសជាតិ ព្រះសង្ឃស្វាធ្យាយជ័យន្តោពរជ័យ និងវារំបាំជូនពរ ជូនអង្គមហាសន្និបាត ។

បន្ទាប់មក លោក **សឺន ហួរ** អធិបតី នៃ **ស.ខ.ក.** បានឡើងថ្លែងសុន្ទរកថាស្វាគមន៍ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ រួចប្រកាសបើកអង្គមហាសន្និបាតលើកទី ១២ ជាផ្លូវការ ។

លោកបានថ្លែងថា **ស.ខ.ក.** បានពុះពារគ្រប់ឧបសគ្គ និងបន្តពង្រឹង ពង្រីកផែនការគស្ងឹមគិ ដើម្បីទាមទារសិទ្ធិ និងសេរីភាពជូនបងប្អូនខ្មែរក្រោមនៅលើផែនដីកម្ពុជាក្រោម ឱ្យមានភាពប្រាស់លាស់ និងប្រសិទ្ធភាពខ្ពស់បំផុត ។

ពិធីករ លោក **ថាប់ រឿង** និងអ្នកស្រី **ថាប់ សុម៉ាលីន** បានប្រកាសសមាសភាពថ្នាក់ដឹកនាំ សមាជិក និងអ្នកគាំទ្រ **ស.ខ.ក.** នៅជុំវិញពិភពលោក និងវាគ្មិនកិត្តិយស ដែលបានចូលរួមមហាសន្និបាតពីប្រទេសនានា ដូចជា ប្រទេសកាណាដា ប្រទេសអូស្ត្រាលី សហគមន៍អឺរ៉ុប ប្រទេសអ៊ីតាលី កម្ពុជា និងរដ្ឋនានាជុំវិញសហរដ្ឋអាមេរិក សរុបប្រមាណជិត ១០០ អង្គ និងរូប ។

មុនពេលរំសាយគណៈកម្មការនាយក លោក **សឺន ហួរ** បានឡើងជូន **«បណ្ណាសរសើរ»** ដល់បុគ្គល និងវត្តអារាម ដែលបានផ្តល់ឋវិកាឱ្យ **ស.ខ.ក.** ខ្ចី សម្រាប់ទិញទីស្នាក់ការរបស់ **ស.ខ.ក.** ។

អ្នកដែលបានផ្តល់ឋវិកាឱ្យ **ស.ខ.ក.** ខ្ចី រួមមានៈ

លោក **មៅ មុនី**	$110,000
វត្តខេមរង្សី	$35,000
អ្នកស្រី **អៀង សុខលីន**	$30,000
អ្នកស្រី **តាង ណារី**	$20,000
លោក **សឺន ហួរ**	$10,000
លោក **ថាប់ ឡិន**	$5,000

សរុប៖ $210,000 (ពីរសែនមួយម៉ឺនដុល្លារសហរដ្ឋអាមេរិក ។

លោក **បៅ រៀប** ប្រធានគណៈកម្មការបោះឆ្នោត បានឡើងថ្លែងប្រកាសរំសាយគណៈកម្មការនាយកចាស់ ដើម្បីបើកដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការនាយកសម្រាប់អាណត្តិកាលថ្មី ក្នុងគោលបំណងបន្តនិរន្តរភាពនៃការដឹកនាំ និងដឹកនាំបលនាកម្ពុជាក្រោមឱ្យមានសាមគ្គីភាព និងប្រសិទ្ធភាពក្នុងការសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

ព្រះតេជព្រះគុណ **ថាប់ ធា** បានឡើងអានជីវប្រវត្តិសង្ខេប របស់ លោក



លោក សឺន ហួរ ប្រគេន និងជូន «បណ្ណាសរសើរ» ដល់ថ្នាក់ដឹកដែលមានគុណសម្បត្តិ និងចូលនិវត្តន៍ ។

ព្រឹទ្ធាចារ្យ បៅ រៀប ជាប្រធានគណៈកម្មការរៀបចំការបោះឆ្នោតនៃសហព័ន្ធខ្មែរកម្ពុជាក្រោម (**គ.ប.ស.**) រួចហើយ អង្គមហាសន្និបាតបានជូន និងប្រគេន **«ប័ណ្ណាសរសើរ»** ដល់ថ្នាក់ដឹកនាំជំនាន់ចាស់មួយចំនួន ដែលមានគុណសម្បត្តិនិងស្នាដៃដ៏ធំធេងនៅក្នុង **ស.ខ.ក.** នាពេលកន្លងមក ។ ក្នុងនោះរួមមានៈ

ព្រឹទ្ធាចារ្យ **បៅ រៀប** អតីតប្រធានសភាព្រឹទ្ធាចារ្យ **ស.ខ.ក.**

ព្រឹទ្ធាចារ្យ **សឺង សម្រេច** ទីប្រឹក្សា **ស.ខ.ក.**

លោក **ថាប់ សេ** អតីតប្រធានសភាតំណាង **ស.ខ.ក.**

ព្រះតេជព្រះគុណ **ឡឹម ខៃ** ស្ថាបនិក **ស.ខ.ក.**

អ្នកស្រី **សឺង ធី និត** ប្រធានគណៈកម្មការស្ត្រី **ស.ខ.ក.**

លោក **តាំង សារៈ** ប្រធានតំបន់ប្រចាំប្រទេសកម្ពុជា **ស.ខ.ក.**

លោក **ប្រាក់ សេរីវុឌ្ឍ** អតីតប្រធានប្រតិបត្តិ **ស.ខ.ក.**

ព្រះតេជព្រះគុណ **កាន សុផានណារិទ្ធ** ដែលបានបរិច្ចាគធនធានយ៉ាងប្រើន ដើម្បីចូលរួមចំណែកក្នុងការទិញ ទីស្នាក់ការ **ស.ខ.ក.** នៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. សហរដ្ឋអាមេរិក ។

បន្ទាប់មក ព្រះតេជព្រះគុណ **កាន សុផានណារិទ្ធ** បានឡើងថ្លែងបិទប្រកាសបិទបញ្ជី **"ក្រាំងមាសកត់ត្រា"** ឈប់ទទួលឋវិកាឧបត្ថម្ភ

សម្រាប់ថ្លៃទិញ ទីស្នាក់ការ **ស.ខ.ក.** តទៅទៀត បន្ទាប់ពីសហព័ន្ធបានរៃអង្គាសគ្រប់ចំនួន និងបានសងម្ចាស់កម្ចីបង់សព្វគ្រប់ហើយ ។ ព្រះតេជព្រះគុណ ក៏បានថ្លែងអំណរគុណចំពោះសប្បុរសជនដែលបានចូលរួមបរិច្ចាគថវិកា និងបានផ្តល់ជាប្រាក់កម្ចី ដល់សហព័ន្ធសម្រាប់ទិញ និងជួសជុលទីស្នាក់ការ **ស.ខ.ក.** រហូតសម្រេចជាស្ថាពរ ។

លោក **បៅ រៀប** ប្រធានគណៈកម្មការបោះឆ្នោត បានប្រកាសបេក្ខជនដែលឈរឈ្មោះបោះឆ្នោតចំនួន ៨ រូប ដោយបានបង្ហាញមុខជាសាធារណៈ និងឡើងប្តេជ្ញាចិត្តក្នុងការដឹកនាំ **ស.ខ.ក.** ឆ្ពោះទៅសម្រេចគោលដៅនៃការសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

បេក្ខជនទាំង ៨ រូប រួមមាន៖

១. លោក **សឺន ហួ**	(អាមេរិក)
២. លោក **បៅ សេរី**	(អាមេរិក)
៣. លោក **ត្រឹង សារ៉ុង**	(អ៊ីតាលី)
៤. លោក **ម៉ៅ មុនី**	(អាមេរិក)
៥. អ្នកស្រី **កៀង សុធី**	(អាមេរិក)
៦. លោក **គឹម សិរ៉ា**	(កាណាដា)
៧. លោក **ថាប់ សាម៉ន**	(អាមេរិក)
៨. លោក **ថាប់ ប្រឹដា គឿន**	(អាមេរិក)

សេចក្តីប្តេជ្ញាចិត្តរបស់បេក្ខជន និងលទ្ធផលនៃការបោះឆ្នោត

លោក **សឺន ហួរ** បានឡើងថ្លែងអំពីសេចក្តីប្តេជ្ញាចិត្តចំពោះគោលដៅដែល **ស.ខ.ក.** បានកំណត់ជាច្បាប់ ដោយបញ្ជាក់ថា សមាជិកទាំងអស់



បោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការនាយក ។

គ្នាត្រូវគោរព និងអនុវត្តតាមគោលការណ៍ **ស.ខ.ក.** ឱ្យបានមានប្រសិទ្ធភាពខ្ពស់បំផុត ។

លោក **បៅ សេរី** បានថ្លែងអំពីការគោរព និងអនុវត្តតាមគោល



ទិដ្ឋភាពអង្គសន្និបាត ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ ។

ការណ៍របស់ **ស.ខ.ក.** ព្រមទាំងការផ្សព្វផ្សាយឱ្យបានជ្រាបច្បាស់ដល់សាខា និងតំបន់នីមួយៗនៅជុំវិញពិភពលោក ។

លោក **ត្រឹង សារ៉ុង** បានថ្លែងអំពីការបម្រើការងារក្នុង **ស.ខ.ក.** អស់រយៈពេលជាង ២០ ឆ្នាំ និងបទពិសោធន៍ក្នុងការជួយបំពេញការងាររបស់សហព័ន្ធ ព្រមទាំងការពង្រឹងការបណ្តុះបណ្តាលយុវជន ឱ្យយល់ដឹងអំពីសិទ្ធិមនុស្ស និងស្គាល់អត្តសញ្ញាណរបស់ខ្លួន ។

លោក **ម៉ៅ មុនី** បានថ្លែងអំពីការចូលរួមជួយ **ស.ខ.ក.** ដោយចាត់ទុកថា ជាមោទនភាពក្នុងនាមជាកូនខ្មែរក្រោមមួយរូប និងមានសេចក្តីរីករាយក្នុងការបម្រើ **ស.ខ.ក.** ដើម្បីបន្តទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ជូនពលរដ្ឋខ្មែរក្រោមនៅលើដែនដីកម្ពុជាក្រោម ។

អ្នកស្រី **កៀង សុធី** បានថ្លែងថា អ្នកស្រីបានចូលបម្រើការងារជាមួយ **ស.ខ.ក.** អស់រយៈពេលជាង ២៦ ឆ្នាំ ក្នុងការជួយជំរុញ និងបណ្តុះបណ្តាលយុវជននៅតាមបណ្តាប្រទេសនិងរដ្ឋនានា ដើម្បីបង្កើតទំពាំងស្នងឫស្សីសម្រាប់អនាគតខ្មែរក្រោម ។

លោក **គឹម សិរ៉ា** បានសម្តែងទឹកចិត្តស្រឡាញ់ និងអាណិតពលរដ្ឋខ្មែរក្រោម ក្នុងនាមជាជនជាតិដើមខ្មែរក្រោមមួយរូប ព្រមទាំងសម្តែងការឈឺចាប់ និងមិនសុខចិត្តចំពោះការបៀតបៀន និងការរំលោភសិទ្ធិលើខ្មែរក្រោមជាជនជាតិដើម ដែលបានកើតមានតាំងពីអតីតកាលរហូតមកដល់បច្ចុប្បន្ន ។

លោក **ថាប់ សាម៉ន** បានថ្លែងថា លោកបានចូលបម្រើការងារជាមួយ **ស.ខ.ក.** តាំងពីឆ្នាំ ២០០៧ រហូតមកដល់បច្ចុប្បន្ន ហើយបានប្តេជ្ញាចិត្តបន្តជួយការងារតទៅមុខទៀត ។

លោក **ថាប់ ប្រឹជា គឿន** បានប្តេជ្ញាចិត្តអនុវត្តគោលការណ៍បំនួន ៣ យ៉ាងៈ

១. ធ្វើការជាក្រុមនៅក្នុង **ស.ខ.ក.** ក្នុងនោះ សាខា និងតំបន់ជាដើម ។

២. ទប់ស្កាត់ការបំបាត់ពូជសាសន៍ ដែលលោកបានចាត់ទុកថាបណ្តាលមកពីរបបអាណានិគមយួន បាននិងកំពុងតែជិះជាន់លើសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ទាំងវិធីក្តៅ និងត្រជាក់ ដែលហៅថា «រំលាយពូជសាសន៍ដោយមិនបង្ហូរឈាម» ។

៣. បន្តពង្រឹងគោលការណ៍ **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** របស់ **ស.ខ.ក.** ដោយធ្វើការជាមួយថ្នាក់ដឹកនាំ **ស.ខ.ក.** ដើម្បីបងក្រងជាសៀវភៅបង្កាន់ដៃ **«ទស្សនវិស័យ»** សម្រាប់ថ្នាក់ដឹកនាំ និងសមាជិក **ស.ខ.ក.** គ្រប់រូបយកទៅធ្វើជាគោលការណ៍រួមតែមួយ ក្នុងការផ្សព្វផ្សាយ និងអនុវត្តផែនការរបស់ **ស.ខ.ក.** ។

ការពិភាក្សាជាក្រុម និងទិសដៅការងារៈ



តារាងលទ្ធផលឆ្នោត ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ ។

អង្គមហាសន្និបាតបានបែងចែកសមាជិកជាក្រុមចំនួន ៦ ក្រុម ក្រោមការដឹកនាំរបស់បណ្ឌិត **Joshua Cooper** ជាទីប្រឹក្សា **ស.ខ.ក.** ដើម្បីពិភាក្សា និងផ្តល់យោបល់អំពីការបណ្តុះបណ្តាលយុវជន និងសមាជិកពលរដ្ឋខ្មែរក្រោម ការជំរុញឱ្យមានការបើកសាលារៀនភាសាខ្មែរនៅតាមសាខា និងតំបន់នានា ព្រមទាំងការផ្សព្វផ្សាយអំពីប្រពៃណី និងទំនៀមទម្លាប់របស់ខ្មែរក្រោម ។

ជាពិសេស អង្គមហាសន្និបាតបានលើកឡើងអំពីការប្រើប្រាស់ពេលវេលាឱ្យមានតម្លៃ ដើម្បីចូលរួមការពារជាតិមាតុភូមិ និងទាមទារសិទ្ធិ និងសេរីភាពពលរដ្ឋនៅកម្ពុជាក្រោម ។

មហាសន្និបាតបានលើកឡើងថា ក្នុងមួយឆ្នាំទៅមួយឆ្នាំ សហព័ន្ធបានបន្តពង្រឹងការដឹកនាំ និងការពន្យល់ដល់ពលរដ្ឋខ្មែរក្រោមអំពីសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ព្រមទាំងទិតទំធ្វើឱ្យអន្តរជាតិស្គាល់ **ស.ខ.ក.** និងស្គាល់អត្តសញ្ញាណ និងស្ថានភាពរបស់ខ្មែរក្រោមកាន់តែប្រែន តាមរយៈការដាក់ញត្តិទៅកាន់ **អ.ស.ប.** និងអង្គការផ្សេងៗ ដើម្បីលើកឡើងអំពីសិទ្ធិរបស់ជនជាតិដើមខ្មែរក្រោម ។

លទ្ធផលនៃការបោះឆ្នោតៈ

អ្នកដែលបានចូលរួមមហាសន្និបាត បានបោះឆ្នោតដោយផ្ទាល់ និងអ្នកដែលមិនបានចូលរួមបោះតាម Online ដោយមនសិការជាតិ ដើម្បីជ្រើសរើស គណៈកម្មការនាយកថ្មី នៃ **ស.ខ.ក.** សម្រាប់ដឹកនាំបន្តនៅក្នុងអាណត្តិពី ឆ្នាំ ២០២៦ ដល់ ២០៣០ ។

សំឡេងឆ្នោតដែលបេក្ខជនម្នាក់ៗបានទទួល រួមមានៈ

លោក **សឺន ហួរ**	៤៧ សំឡេង
លោក **បៅ សឺន**	៤១ សំឡេង
លោក **ម៉ៅ មុនី**	៦៣ សំឡេង
អ្នកស្រី **កៀង សុធី**	៥៨ សំឡេង
លោក **ត្រឹង សារ៉ុង**	៥៣ សំឡេង
លោក **គីម សិរ៉ា**	៤៤ សំឡេង
លោក **ថាប់ សាម៉ន**	៥៤ សំឡេង
លោក **ថាប់ ប្រឹជា គឿន**	៥២ សំឡេង

បេក្ខជនទាំង ៨ រូប **គ.ប.ស.** ជ្រើសរើសយកតែ ៧ រូប ប៉ុណ្ណោះ ។ លោក **បៅ សឺន** មិនបានឈរក្នុងឆ្នោត គណៈកម្មការនាយក



សមាជិក គណៈកម្មការនាយក សហព័ន្ធខ្មែរកម្ពុជាក្រោម
អាណត្តិ ២០២៦ - ២០៣០ ។

ទៀតទេ ដោយសារសំឡេងឆ្នោតតិបជាងគេ ។

បន្ទាប់ពីបានដឹងលទ្ធផលឆ្នោតហើយ គណៈកម្មការនាយកជាប់ឆ្នោតថ្មីទាំង ៧ រូប បានប្រជុំបិទទ្វារ ហើយសម្រេចជ្រើសតាំងថ្នាក់ដឹកនាំ ៤ អង្គ/រូបទៀត ឱ្យបួលជាគណៈកម្មការនាយក ក្នុងនោះ មានព្រះសង្ឃ ២ អង្គ ស្ត្រីម្នាក់ និងយុវជនម្នាក់ ។ ថ្នាក់ដឹកនាំដែលបានជ្រើសតាំងនោះ រួមមាន ព្រះតេជព្រះគុណ **កាន សុផានណាវិទ្ធ** ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា** អ្នកស្រី **សឺង ធី ឥត** និង នាង **ថាប់ វើធីញ៉ា** ។

បន្ទាប់មកទៀត គណៈកម្មការនាយកទាំង ១១ រូបនេះ បានបន្ត



ប្រកាសឈ្មោះ និងតួនាទីរបស់គណៈកម្មការនាយក ស.ខ.ក.
ល្ងាចថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ ។

ប្រជុំបិទទ្វារដើម្បីបែងចែកតួនាទី ។ ជាលទ្ធផល របនាសម្ព័ន្ធថ្មី នៃគណៈកម្មការនាយក **ស.ខ.ក.** សម្រាប់អាណត្តិឆ្នាំ ២០២៦ - ២០៣០ បានប្រសូតចេញជារូបរាង ដូចខាងក្រោមៈ

១. លោក **សឺន ហ្គួរ** ជាអធិបតី **ស.ខ.ក.**

២. លោក **ម៉ៅ មុនី** ប្រធានប្រតិបត្តិ

៣. អ្នកស្រី **កៀង សុធី** អនុប្រធានប្រតិបត្តិ

៤. លោក **ត្រឹង សារ៉ុង** ប្រធានសភាព្រឹទ្ធាចារ្យ

៥. លោក **គឹម សិរ៉ា**ប្រធានសភាតំណាង

៦. លោក **ថាប់ សាម៉ន** ហេរញ្ញិក

៧. ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា** លេខាធិការ

៨. ព្រះតេជព្រះគុណ **កាន សុផានណាវិទ្ធ** ប្រធាន **គ.ស.ស.ខ.ក.**

៩. អ្នកស្រី **សឺង ធីនិត** ជាប្រធានគណៈកម្មការស្ត្រី

១០. លោក **ថាប់ ប្រ៊ីជា គឿន** ជាប្រធានគណៈកម្មការព័ត៌មាន

១១. នាងកញ្ញា **ថាប់ វើធីញ៉ា** ជាប្រធានគណៈកម្មការយុវជន

ការប្តេជ្ញាចិត្តរបស់គណៈកម្មការនាយកថ្មីៈ

ពេលរសៀល ក្រោយពីបានបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំថ្មីរួចហើយ គណៈកម្មការនាយកថ្មី អាណត្តិ ២០២៦-២០៣០ បានឈរនៅមុខរូបសំណាកវីរបុរសជាតិ លោកឧកញ៉ា **សឺន គុយ** ដែលតាំងនៅមុខ ទីស្នាក់ការ **ស.ខ.ក.** ដោយបានប្តេជ្ញាចិត្តបម្រើ **ស.ខ.ក.** រហូតដល់ទទួលបានជោគជ័យក្នុងការ **សម្រេចវាសនាខ្លួនដោយខ្លួនឯង** នៃប្រជាជាតិខ្មែរក្រោម ។

ពេលយប់ បន្ទាប់ពីកិច្ចអធិដ្ឋានប្តេជ្ញាចិត្ត (ស្បថ) នៃ គណៈកម្មការនាយកក្លួច អ្នកចូលរួមទាំងអស់បានចូលទីស្នាក់ការប្រជុំបន្តទៀតដោយមានបើកវេទិកាបំហសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្របញ្ចេញមតិ ឬទស្សនៈផ្សេងៗ លើការគស្ងរបស់ **ស.ខ.ក.** ។

ថ្ងៃអាទិត្យ ទី ១៩ ខែកក្កដា ឆ្នាំ២០២៦

ចាប់ពីម៉ោង ៩:០០ ព្រឹក

ការតែងតាំងឧត្តមក្រុមប្រឹក្សា នៃ ស.ខ.ក.ៈ

អង្គមហាសន្និបាតបានតែងតាំងព្រឹទ្ធាចារ្យ **បៅ រៀប** ព្រឹទ្ធាចារ្យ **សឺង សម្រេប** និងបណ្ឌិត Joshua Cooper ជាទីប្រឹក្សានៅក្នុងឧត្តមក្រុមប្រឹក្សា នៃ **ស.ខ.ក.** ។

បន្ទាប់មក គណៈកម្មការនីមួយៗនៃ **ស.ខ.ក.** ក៏បានជ្រើសតាំងទីប្រឹក្សា ជំនួយការ និងអនុប្រធានទៅតាមតម្រូវការបាំបាច់ ។

លោក **បៅ សេរី** ត្រូវបានតែងតាំងជាឧត្តមទីប្រឹក្សា និងលោក

ថាប់ វិន ត្រូវបានតែងតាំងជាហេរញ្ញិករង ផ្នែកហេរញ្ញវត្ថុ ។

លោក **គឹម ស្វនី** ជាអនុប្រធានសភាព្រឹទ្ធាចារ្យ និង លោក **ឡឹម ស៊ីវេត** ជាអនុប្រធានសភាតំណាង ប្រចាំសហរដ្ឋអាមេរិក ។



សមាជិក គណៈកម្មការនាយក សហព័ន្ធខ្មែរកម្ពុជាក្រោម អាណត្តិ ២០២៦ - ២០៣០ ស្បថចូលកាន់តំណែង នៅចំពោះមុខរូបសំណាក ឧកញ៉ា សឺន គុយ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ ។

ការរៀបចំបោះឆ្នោតតាមតំបន់ និងសាខា:

លោក **ម៉ៅ មុនី** ជាប្រធានប្រតិបត្តិ **ស.ខ.ក.** បានជ្រើសរើស និងស្នើដល់ប្រធានតំបន់ និងប្រធានសាខាឱ្យរៀបចំការបោះឆ្នោតតាមតំបន់ ឬតាមសាខារៀងៗខ្លួនឡើងវិញ យ៉ាងយូរបំផុតក្នុងរយៈពេលបីខែខាងមុខ ដើម្បីបន្តការងារឆ្ពោះទៅមុខ ក្នុងការតស៊ូទាមទារសិទ្ធិ និងសេរីភាពជូនពលរដ្ឋដែនដីកម្ពុជាក្រោម ។

ប្រធានតំបន់ដែលបានប្រកាសតែងតាំងរួមមាន:

លោក **តាំង សារៈ**	ប្រទេសកម្ពុជា
លោក **ថាប់ តង**	ភាគខាងលិចសហរដ្ឋអាមេរិក
លោក **សឺន សារុម**	ភាគកណ្តាលសហរដ្ឋអាមេរិក
លោក **យ៉ង់ តួន**	ភាគខាងកើតសហរដ្ឋអាមេរិក
លោក **ត្រឹម ឫទ្ធីវ**	តំបន់ប្រចាំប្រទេសកាណាដា
លោក **យ៉ង់ ឫណាត**	តំបន់ប្រចាំទ្វីបអូស្ត្រាលី
លោក **ឃួន ណាកា**	តំបន់ទ្វីបអឺរ៉ុប

ការតែងតាំងក្នុងការិយាល័យលេខាធិការ:

ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា** លេខាធិការ **ស.ខ.ក.** បានប្រកាសតែងតាំង:

ភិក្ខុ **ថាប់ ធា**	អនុប្រធានលេខាធិការទីមួយ
ភិក្ខុ **សឺន រ៉ុន**	អនុប្រធានលេខាធិការទីពីរ
ភិក្ខុ **ថាប់ ទាយ**	ជំនួយការលេខាធិការ
ភិក្ខុ **ថាប់ ស្នាល**	ជំនួយការលេខាធិការ
ភិក្ខុ **ថាប់ តឺ**	ជំនួយការលេខាធិការ

ការតែងតាំងក្នុងគណៈកម្មការព័ត៌មាន:

លោក **ថាប់ ប្រឹដា គឿន** ប្រធានគណៈកម្មការព័ត៌មាន **ស.ខ.ក.** បានប្រកាសតែងតាំង:

លោក **ថាប់ រឿង**	អនុប្រធានទីមួយ
លោក **សឺន ថាយ ធន**	អនុប្រធានទីពីរ
អ្នកស្រី **តាង ណារី**	សហការីនៅសហរដ្ឋអាមេរិក
អ្នកស្រី **ថាប់ សុជាតា**	សហការីនៅកាណាដា
ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា**	ឧត្តមក្រុមប្រឹក្សា
ព្រឹទ្ធាចារ្យ **សឺង សម្រេប**	ឧត្តមក្រុមប្រឹក្សា
លោក **តាំង សារៈ**	ឧត្តមក្រុមប្រឹក្សា

ការបិទអង្គមហាសន្និបាត:

អង្គមហាសន្និបាត ដែលបានប្រព្រឹត្តទៅអស់រយៈពេលបីថ្ងៃ គឺនៅថ្ងៃសុក្រ ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ទី ១៧ - ១៨ និងទី ១៩ ខែកក្កដា ឆ្នាំ ២០២៦ បានបញ្ចប់ប្រកបដោយជោគជ័យដ៏ត្រចះត្រចង់ ក្នុងបរិយាកាសមិត្តភាព និងសាមគ្គីភាពដ៏ជ្រាលជ្រៅ នៃមហាគ្រួសារ ស.ខ.ក. ។ អង្គមហាសន្និបាតបានបន្តដាក់ចេញនូវផែនការការងារ ដើម្បីទាមទារសិទ្ធិ និងសេរីភាពជូនពលរដ្ឋខ្មែរក្រោម ដែលកំពុងរស់នៅក្រោមរបបអាណានិគមយូរអង្វែងពេលបច្ចុប្បន្ន តាមមធ្យោបាយអហិង្សា ស្របតាមច្បាប់ និងគោលការណ៍របស់ **អ.ស.ប.** ។

គោលការណ៍ ១០ ចំណុច:

បន្ទាប់ពីអង្គមហាសន្និបាតបានបញ្ចប់ទៅ នៅថ្ងៃទី ២០ ខែកក្កដា **ស.ខ.ក.** បានចេញ **«សេចក្តីប្រកាសក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ២០២៦»** សម្រេចលើគោលការណ៍ ១០ ចំណុច ។ សេចក្តីសម្រេចនេះកើតចេញពីការអនុម័តជាឯកច្ឆន្ទដោយប្រតិភូ **ស.ខ.ក.** ដែលបានចូលរួមមហាសន្និបាត ។ គោលការណ៍នោះរួមមាន:

១. ពង្រឹងសាមគ្គីភាពជាសកល ។

២. បន្តការតស៊ូមតិដោយសន្តិវិធីលើឆាកអន្តរជាតិ ។

៣. ការពារសិទ្ធិមនុស្សជាមូលដ្ឋាន ។
៤. បន្តទាមទារឱ្យរបបយួនដោះលែងខ្មែរក្រោម ។
៥. ការពារអត្តសញ្ញាណជនជាតិដើម ។
៦. ផ្តល់សិទ្ធិអំណាចដល់ខ្មែរក្រោមគ្រប់រូប ។
៧. បណ្តុះបណ្តាលធនធានមនុស្សសម្រាប់បន្តវេន ។
៨. ពង្រីកភាពជាដៃគូអន្តរជាតិ ។
៩. ចូលរួមដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព ។
១០. ពង្រឹង សហព័ន្ធខ្មែរកម្ពុជាក្រោម ឱ្យកាន់តែរឹងមាំ ។

អ្នកធ្វើកំណត់ហេតុ
ភិក្ខុ សឺង យ៉ឹង រតនា (សុវណ្ណប្បញ្ញោ)
លេខាធិការ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម



ពិធីគោរពទង់ជាតិកម្ពុជាក្រោម និងគោរពរំឭកគុណវីរបុរស និងវីរសមណៈ នៅមុខទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម ព្រឹកថ្ងៃអាទិត្យទី ១៩ ខែកក្កដា ឆ្នាំ ២០២៦ (ថ្ងៃទី ៣ នៃមហាសន្និបាត) ។

សេចក្តីសម្រេចលើគោលការណ៍ ១០ ចំណុច
របស់ «សេចក្តីប្រកាសក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ២០២៦»

១. ពង្រឹងសាមគ្គីភាពជាសកល ។
២. បន្តការតស៊ូមតិដោយសន្តិវិធីលើឆាកអន្តរជាតិ ។
៣. ការពារសិទ្ធិមនុស្សជាមូលដ្ឋាន ។
៤. បន្តទាមទារឱ្យរបបយួនដោះលែងខ្មែរក្រោម ។
៥. ការពារអត្តសញ្ញាណជនជាតិដើម ។
៦. ផ្តល់សិទ្ធិអំណាចដល់ខ្មែរក្រោមគ្រប់រូប ។
៧. បណ្តុះបណ្តាលធនធានមនុស្សសម្រាប់បន្តវេន ។
៨. ពង្រីកភាពជាដៃគូអន្តរជាតិ ។
៩. ដោះស្រាយបញ្ហាអាកាសធាតុ និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព ។
១០. ពង្រឹង សហព័ន្ធខ្មែរកម្ពុជាក្រោម ឱ្យកាន់តែរឹងមាំ ។

សមាសភាព គណៈកម្មការ សាខា និងតំបន់ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅតាមរដ្ឋ និងប្រទេសផ្សេងៗនៅលើពិភពលោក

បន្ទាប់ពី សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) បានបោះឆ្នោតជ្រើសរើសគណៈកម្មការនាយកសម្រាប់អាណត្តិ ២០២៦–២០៣០ កាលពីខែកក្កដា ឆ្នាំ ២០២៦ កន្លងទៅ ការរៀបចំសមាសភាពគណៈកម្មការដឹកនាំតំបន់ និងសាខានៅជុំវិញពិភពលោក ក៏បានប្រព្រឹត្តទៅតាមរយៈការតែងតាំង ឬការបោះឆ្នោតជ្រើសរើសជាបន្តបន្ទាប់ ។ ការរៀបចំនេះមានគោលបំណងពង្រឹងរចនាសម្ព័ន្ធដឹកនាំ កិច្ចសហការ និងសាមគ្គីភាព ដើម្បីបន្តបេសកកម្មបម្រើ និងការពារសិទ្ធិពលរដ្ឋនៅដែនដីកម្ពុជាក្រោម ។ គណៈកម្មការដឹកនាំតំបន់ និងសាខាទាំងនេះ រួមមាននៅព្រះរាជាណាចក្រកម្ពុជា សហរដ្ឋអាមេរិក កាណាដា អឺរ៉ុប និងអូស្សានី ។ ព្រឹត្តិបត្រ កម្ពុជាក្រោម សូមជូនសមាសភាពថ្នាក់ដឹកនាំដែលត្រូវបានតែងតាំង ឬជ្រើសរើស និងជាប់ឆ្នោត ដូចខាងក្រោមៈ



ព្រះសង្ឃ ថ្នាក់ដឹកនាំ និងអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម បោះឆ្នោតជ្រើសប្រធានតំបន់ប្រចាំទ្វីបអូសេអានី នៅប្រទេសអូស្ត្រាលី ក្នុងខែសីហា ឆ្នាំ ២០២៦ ។

ព្រះរាជាណាចក្រកម្ពុជា

ក- **សមាសភាពតំបន់**

លោក **តាំង សារៈ**	ប្រធានតំបន់
ព្រះគ្រូធម្មវិរិយាចារ្យ **ហាញ់ បំរុង** (ធម្មបាលោ)	ទីប្រឹក្សាតំបន់
លោកបណ្ឌិត **សឺន ជុំជ្ជិន**	អនុប្រធាន
លោក **ថាប់ គេវិសាវ៉ាង**	លេខាធិការ
លោក **គឹម រមរ្យមុនី**	ឧបការីប្រធានតំបន់ទទួលបន្ទុកមើលការខេត្តកោះកុង

ខ-**សមាសភាពសាខា**

លោក **សឺន យឿង**	ប្រធាន
លោក **ញឹម ឫទ្ធី**	អនុប្រធាន
លោក **គឹម ស៊ីសំណា**	លេខាធិការ
លោក **ថាប់ សុវណ្ណាមុនី**	ហេរញ្ញិក
លោក **សឺន សុធន**	ប្រធានផ្នែកព័ត៌មាន
អ្នកស្រី **តាំង កែវពិសី**	ប្រធានផ្នែកយុវជន
លោក **ស៊ុន ឈៃងបើន**	អនុប្រធានផ្នែកព័ត៌មាន
អ្នកស្រី **ជិន សុខា**	អនុប្រធានយុវជន

តំបន់សហរដ្ឋអាមេរិកភូមិភាគខាងលិច

លោក **ថាប់ តង**	ប្រធានតំបន់
លោក **ថាប់ ជួន**	អនុប្រធាន

តំបន់សហរដ្ឋអាមេរិកភូមិភាគកណ្តាល

លោក **សឺន សារ៉ុម**	ប្រធានតំបន់

តំបន់កាណាដា

លោក **ត្រឹម ប៊ុយប៊ូវ**	ប្រធានតំបន់

តំបន់អូស្សានី

លោក **សឺន ធារិទ្ធ**	ប្រធានតំបន់
លោក **យ៉ែម ប៊ូណាត**	អនុប្រធាន
លោក **ថាប់ បន្ទួស្សធីរ៍**	លេខាធិការប្រចាំរដ្ឋវិចតូរីយ៉ា ។

តំបន់អឺរុប

លោក **ឃួន ណាកា**	ប្រធានតំបន់

សមាសភាពគណៈកម្មការសាខា

សាខាទីក្រុង San Jose រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក

លោក **ឡឹម ស៊ីវេត**	ប្រធាន
លោក **បន្ទួ សុផាត**	អនុប្រធាន

លោក **ថាប់ រឿង**	លេខាធិការ	
ព្រះភិក្ខុ **ថាប់ ស្នាល**	ហេរញ្ញិក	
ព្រះភិក្ខុ **ថាប់ តឺ**	ហេរញ្ញិករង	
លោក **ថាប់ ថាយ**	ប្រធានយុវជន	
លោក **លឺ ឃោន**	ទីប្រឹក្សា	(អតីតប្រធាន)
លោក **ថាប់ ជួន**	ទីប្រឹក្សា	(អតីតប្រធាន)
អ្នកស្រី **នាង ណារី**	ទីប្រឹក្សា	(អតីតប្រធាន)

សាខារដ្ឋណេតការ៉ូឡាញណា សហរដ្ឋអាមេរិក

លោក **យេន ថាវក្ស**	ប្រធាន
លោក **យ៊ិន ប្រុស**	អនុប្រធាន
អ្នកស្រី **ថាប់ បរិយា**	លេខាធិការ
អ្នកស្រី **ថាប់ វ.**	ហេរញ្ញិក
លោក **សឺន ថាយ ធន**	ទីប្រឹក្សា (អតីតប្រធាន)

សាខាទីក្រុងប៉ារីស ប្រទេសបារាំង

លោក **ថាប់ វាសនា**	
លោក **សឺន វិត**	
លោក **គីម ឫទ្ធី**	
លោក **ទ្វី ណាវ**	
លោក **ហៀ ភីលីប**	
លោក **ថាប់ សុធន**	

សាខាប្រទេសហុល្លង់

លោក **ត្រឹង ប័ន្ធសាវ៉ាត**	ប្រធាន
លោក **ថាប់ សំខាន់**	អនុប្រធាន និងជាប្រធានយុវជន
អ្នកស្រី **ថាប់ ថា**	ប្រធានស្ត្រី
លោក **លឺ សឿង**	ប្រធានផែនការ

សាខាប្រទេសអ៊ីតាលី

លោក **យ័ញ ថាន់**	ប្រធាន
លោក **ត្រឹង គីមណៃ**	អនុប្រធាន

សាខាអូស្ត្រាលីខាងត្បូង

លោក **កៀង ប័ន្ធ**	ប្រធាន

សាខារដ្ឋវិចតូរីយ៉ា ប្រទេសអូស្ត្រាលី

លោក **ថាប់ សុទ្ធី**	ប្រធាន

សមាសភាព និងគណៈកម្មការខាងលើ ប្រមូលព័ត៌មាន និងរៀបរៀងដោយ លោក តាំង សារៈ



គណៈកម្មការ សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំទីក្រុង សាន ហូស្សេ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២៦ ។

ប្រវត្តិនៃការបង្កើត ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម និង រូបសំណាក វីរបុរសជាតិកម្ពុជាក្រោម ឧកញ៉ា សឺន គុយ នៅរដ្ឋធានី វ៉ាស៊ីនតោន ឌី.ស៊ី. សហរដ្ឋអាមេរិក

ការមានទីស្នាក់ការផ្ទាល់ខ្លួននៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក គឺជាសមិទ្ធផលប្រវត្តិសាស្ត្រដ៏សំខាន់របស់សហព័ន្ធខ្មែរកម្ពុជាក្រោម។ ទីស្នាក់ការនេះបានបង់ថ្លៃទិញផ្តាច់ជាកម្មសិទ្ធិនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៥ និងសម្ពោធជាផ្លូវការនៅថ្ងៃទី ១២ និង ១៣ ខែកក្កដា ឆ្នាំ២០២៥ ។ ក្រៅពីជាកន្លែងបំពេញការងារ ទីនេះក៏ជាកន្លែងតម្កល់ និងបង្ហាញប្រវត្តិសាស្ត្រ វប្បធម៌ និងស្នាព្រីតស៊ូរបស់ខ្មែរក្រោម ដោយមានរូបសំណាក ឧកញ៉ាសេនាបតី សឺន គុយ នៅមុខទីស្នាក់ការជានិមិត្តរូបដ៏សំខាន់ ។

សមិទ្ធផលនេះ កើតចេញពីការរួមចំណែករបស់ថ្នាក់ដឹកនាំ សមាជិក ព្រះសង្ឃ ប្រជាពលរដ្ឋ និងអ្នកគាំទ្រទូទាំងពិភពលោក ដែលបានឧបត្ថម្ភថវិកាជាង ៣៧០,០០០ ដុល្លារក្នុងរយៈពេលមិនដល់ពីរឆ្នាំ ។ ក្នុងនោះ ប្រមាណ ២៨០,០០០ ដុល្លារសម្រាប់សងថ្លៃទិញអគារ ប្រមាណ ៨០,០០០ ដុល្លារសម្រាប់ជួសជុលកែលម្អ និងនីតិវិធីពាក់ព័ន្ធ និងប្រមាណ ១០,០០០ ដុល្លារសម្រាប់ដឹកជញ្ជូន និងរៀបចំការកសាងរូបសំណាក ។ ការរួមចំណែកនេះ បានធ្វើឲ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម មានទីស្នាក់ការអចិន្ត្រៃយ៍ និងមានមូលដ្ឋានតស៊ូយូរអង្វែង ដើម្បី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» នៃប្រជាជាតិខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ។

ប្រវត្តិ ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម



សម្ពោធ ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី ថ្ងៃទី ១២ និង ១៣ ខែកក្កដា ឆ្នាំ ២០២៥ ។

ដោយ **ថាប់ ប្រឹជា គឿន**

១. សារវិភាគនៃការបង្កើតទីស្នាក់ការ ស.ខ.ក.៖

ការបង្កើត ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. សហរដ្ឋអាមេរិក គឺជាគម្រោងសំខាន់មួយ កើតចេញពីតម្រូវការជាក់ស្តែងក្នុងការពង្រឹងការងាររបស់ **ស.ខ.ក.** នៅលើឆាកអន្តរជាតិ ជាពិសេស ក្នុងវិស័យការទូត និងការតស៊ូមតិដោយសន្តិវិធី ។ គំនិតនេះត្រូវបាន លោក **ម៉ៅ មុនី** ដែលកាលនោះជាអនុប្រធានទីមួយ នៃ **ស.ខ.ក.** លើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំរបស់គណៈកម្មការនាយក **ស.ខ.ក.** អំពីតម្រូវការចាំបាច់ និងសារៈសំខាន់របស់ទីស្នាក់ការ ។ គណៈកម្មការនាយក **ស.ខ.ក.** បានបើកកិច្ច

ប្រជុំទូរសន្ទិបាតនៅថ្ងៃទី ២៤ ខែសីហា និងថ្ងៃទី ៥ ខែតុលា ឆ្នាំ ២០២៤ បានសម្រេចជាឯកច្ឆន្ទអនុម័តឱ្យសហព័ន្ធទិញអគារមួយខ្នងតម្លៃ **$១០០.០០០** (មួយសែនដុល្លារសហរដ្ឋអាមេរិក) សម្រាប់ធ្វើជាទីស្នាក់ការរបស់ខ្លួននៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. ។ នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០២៤ **ស.ខ.ក.** បានបេញសេចក្តីប្រកាសព័ត៌មានជាផ្លូវការមួយស្តីពីគម្រោងទិញទីស្នាក់ការ និងបានអំពាវនាវដល់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រនៅជុំវិញពិភពលោក ឱ្យចូលរួមបំណែកតាមលទ្ធភាព ដើម្បីឱ្យគម្រោងនេះសម្រេចបានជោគជ័យ ។

ការសម្រេចទិញទីស្នាក់ការនេះ ក៏ជាការឆ្លើយតបទៅនឹងការងារដែល **ស.ខ.ក.** ត្រូវបំពេញជាប្រចាំនៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. នៃសហរដ្ឋអាមេរិក ។ ថ្នាក់ដឹកនាំសហព័ន្ធ តែងតែធ្វើដំណើរទៅក្រុងវ៉ាស៊ីនតោន ឌី.ស៊ី. ដើម្បីជួបមន្ត្រីរដ្ឋាភិបាល តំណាងស្ថាប័ន និងភាគីពាក់ព័ន្ធដើម្បីលើកឡើងពីស្ថានភាពសិទ្ធិមនុស្ស សិទ្ធិជនជាតិដើម និងបញ្ហាពាក់ព័ន្ធនឹងពលរដ្ឋខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ។

ដូច្នេះ ការមានទីស្នាក់ការផ្ទាល់ខ្លួននៅទីក្រុងនេះ ត្រូវបានចាត់ទុកថា ជាមូលដ្ឋានសម្រាប់សម្រួលការងារ និងបង្កើនភាពជាប់លាប់នៃសកម្មភាពការទូត និងការតស៊ូមតិយូរអង្វែងរបស់សហព័ន្ធ ។

២. គោលបំណងនៃការបង្កើតទីស្នាក់ការ

ទីស្នាក់ការបង្កើតឡើង មានគោលបំណងសំខាន់ៗជាច្រើន ។ **ទីមួយ** គឺធ្វើជាមជ្ឈមណ្ឌលសម្រាប់ការងាររបស់ **ស.ខ.ក.** នៅសហរដ្ឋអាមេរិក ជាពិសេស ការងារតស៊ូមតិដោយសន្តិវិធី និងអហិង្សាផ្តោតលើវិស័យការទូត និងការចូលរួមនៅក្នុងវេទិកាអន្តរជាតិ ។ **ទីពីរ** សម្រួលដល់ការងាររបស់ថ្នាក់ដឹកនាំ និងតំណាងសហព័ន្ធ ដែលត្រូវធ្វើដំណើរមកកាន់រដ្ឋធានីវ៉ាស៊ីនតោន ដើម្បីជួបពិភាក្សា និងរាយការណ៍ជូនមន្ត្រីរដ្ឋាភិបាលសហរដ្ឋអាមេរិក និងស្ថាប័នពាក់ព័ន្ធអំពីស្ថានភាពប្រជាជននៅកម្ពុជាក្រោម ។ **ទីបី** ទីស្នាក់ការត្រូវបានរៀបចំជាមជ្ឈមណ្ឌលឯកសារ និងបណ្ណាល័យសម្រាប់រក្សាទុកឯកសារប្រវត្តិសាស្ត្រ ឯកសារការទូត ឯកសារតស៊ូមតិ និងស្នាដៃនានារបស់ **ស.ខ.ក.** ។ ឯកសារទាំងនេះមានគោលបំណងបម្រើដល់និស្សិត អ្នកសិក្សា អ្នកស្រាវជ្រាវ អ្នកតស៊ូមតិសិទ្ធិមនុស្ស អ្នកនយោបាយ និងសាធារណជន ដែលមានបំណងសិក្សាស្វែងយល់អំពីប្រវត្តិសាស្ត្រ និងបញ្ហារបស់ខ្មែរក្រោម ។ **ទីបួន** រក្សាទុកជាមរតកឯកសារនៃការងាររបស់ **ស.ខ.ក.** ដើម្បីឱ្យមនុស្សជំនាន់ក្រោយអាចសិក្សា និងឈ្វេងយល់ពីដំណើរវិវត្តនៃការតស៊ូមតិរបស់ **ស.ខ.ក.** ។

៣. ការចូលរួមគាំទ្រ និងការបរិច្ចាគថវិកា

គម្រោងបង្កើតទីស្នាក់ការនេះ មិនមែនជាស្នាដៃរបស់បុគ្គល ឬក្រុមណាមួយតែម្នាក់ឡើយ ប៉ុន្តែជាលទ្ធផលនៃការចូលរួមពីព្រះសង្ឃ ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រ **ស.ខ.ក.** នៅជុំវិញពិភពលោក ។ ក្នុងនោះ មានការចូលរួមគាំទ្រពីមហាជន និងបានបរិច្ចាគថវិកាសរុបប្រមាណ **៣៧០,០០០ ដុល្លារអាមេរិក** ត្រូវបានប្រើប្រាស់សម្រាប់គម្រោងទីស្នាក់ការនេះ ដោយរួមមាន៖

២៨០,០០០ ដុល្លារ សម្រាប់បង់ថ្លៃពេញ ឬបង់ផ្តាច់ថ្លៃទិញទីស្នាក់ការ ។ **៨០,០០០ ដុល្លារ** សម្រាប់ការជួសជុលកែលម្អ និងនីតិវិធីពាក់ព័ន្ធផ្សេងៗ ។ **១០,០០០ ដុល្លារ** សម្រាប់ការកសាងរូបសំណាក និងដឹកជញ្ជូនរូបសំណាក ពីលោក **សឺន គុយ** មកពីប្រទេសកម្ពុជា ។

សកម្មភាពនៃការចូលរួមទាំងនេះ បានបង្ហាញឱ្យឃើញពីការគាំទ្ររួមដល់ការតស៊ូមតិរបស់ **ស.ខ.ក.** និងសុឆន្ទៈបំពេញការបង្កើតមូលដ្ឋានការងារជាអចិន្ត្រៃយ៍មួយនៅក្នុងរដ្ឋធានីសហរដ្ឋអាមេរិក ។

ក្នុងរយៈពេលមិនដល់ពីរឆ្នាំផង ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រ **ស.ខ.ក.** បានរួមគ្នាបរិច្ចាគថវិកាតាមលទ្ធភាពរៀងៗខ្លួន ដើម្បីធ្វើឱ្យគម្រោងដែលបានចាប់ផ្តើមពីគំនិតក្នុងកិច្ចប្រជុំមួយ បានក្លាយទៅជាទីតាំងជាក់ស្តែងសម្រាប់បម្រើការងារដល់ការតស៊ូមតិ ។

៤. ទីតាំង និងនិមិត្តសញ្ញានៃទីស្នាក់ការ

ទីស្នាក់ការ **ស.ខ.ក.** ស្ថិតនៅក្នុងរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. ដែលជាមជ្ឈមណ្ឌលរដ្ឋបាល និងនយោបាយរបស់សហរដ្ឋអាមេរិក និងជាទីតាំងប្រមូលផ្តុំដោយស្ថានទូត និងស្ថាប័នការទូតជាច្រើនពីជុំវិញពិភពលោក ។

ដោយសារតែទីស្នាក់ការ មានទីតាំងនៅតាមបណ្តោយផ្លូវតភ្ជាប់ទៅកាន់តំបន់សំខាន់ៗជាច្រើនក្នុងរដ្ឋធានី ទីស្នាក់ការត្រូវបានមើលឃើញថា មានភាពងាយស្រួលសម្រាប់ការទំនាក់ទំនង និងការងារតស៊ូមតិជាមួយស្ថាប័នពាក់ព័ន្ធ ។

តាមការបកស្រាយរបស់សហព័ន្ធ ទីតាំងនេះក៏មានន័យនិមិត្តសញ្ញា

ដែលភ្ជាប់ទៅនឹងប្រវត្តិសាស្ត្រ និងគោលបំណងរបស់ខ្លួនផងដែរ ។ ក្នុងនោះ គេឃើញផ្លូវមួយដែលអាចតភ្ជាប់ពីទីស្នាក់ការទៅកាន់សេតវិមាន មានឈ្មោះ Independence ដែលមានន័យថា **«ឯករាជ្យ»** ។ ពាក្យនេះ ត្រូវបានសហព័ន្ធយកមកភ្ជាប់ជាមួយគោលគំនិតអំពីសិទ្ធិរបស់ប្រជាជាតិមួយក្នុងការកំណត់អនាគតរបស់ខ្លួនគឺ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។

មួយទៀត គឺលេខអាសយដ្ឋាន **4953** របស់ទីស្នាក់ការ ។ តាមការបកស្រាយរបស់សហព័ន្ធ លេខ **49** ត្រូវបានភ្ជាប់ទៅនឹងឆ្នាំ **១៩៤៩** ដែលជា**ឆ្នាំបារាំងផ្ទេរដែនដីកម្ពុជាក្រោមឱ្យទៅយួនបន្តធ្វើអាណានិគមលើខ្មែរក្រោម** ខណៈលេខ **53** ត្រូវបានភ្ជាប់ទៅនឹងឆ្នាំ **១៩៥៣** ដែលជាឆ្នាំកម្ពុជាទទួលបាន**ឯករាជ្យ**ពីបារាំង ។

លើសពីនេះ ការបូកលេខ ៤ + ៩ + ៥ + ៣ = **២១** ត្រូវបានសហព័ន្ធយកមកធ្វើជានិមិត្តសញ្ញាមួយទៀត ដោយភ្ជាប់ទៅនឹងចំនួន **២១ ខេត្ត** នៅដែនដីកម្ពុជាក្រោម ។

ដោយហេតុនេះ ទីស្នាក់ការនេះត្រូវបានផ្តល់នូវអត្ថន័យលើសពីការជាអគារសម្រាប់ធ្វើការរដ្ឋបាល ។ តាមទស្សនៈរបស់សហព័ន្ធ វាក៏ជានិមិត្តរូបនៃការរក្សាអត្តសញ្ញាណ ប្រវត្តិសាស្ត្រ ឯកសារ និងការបន្តការងារតស៊ូមតិរបស់ **ស.ខ.ក.** នៅលើឆាកអន្តរជាតិ ។

៤. ការទិញជាកម្មសិទ្ធិ ការសម្ពោធ និងការសងផ្តាប់ប្រាក់កម្ចី៖

ស.ខ.ក. ត្រូវបានតំណាងដោយលោកអធិបតី **ស៊ឹង ហួរ** ចុះហត្ថលេខាការទិញទីស្នាក់ការនេះ និងបានបង់ថ្លៃពេញផ្តាប់ជាកម្មសិទ្ធិនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៥ ។

បន្ទាប់មក ទីស្នាក់ការត្រូវបានជួសជុល និងកែលម្អឱ្យប្រសើរឡើង ដើម្បីឱ្យអគារអាចប្រើប្រាស់បានជាកន្លែងធ្វើការរបស់សហព័ន្ធ ក្នុងនោះ មានប្រជុំ ទទួលភ្ញៀវអន្តរជាតិ អ្នកសិក្សា និងអ្នកស្រាវជ្រាវជាដើម ។

ក្រោយការរៀបចំរួចរាល់ សហព័ន្ធខ្មែរកម្ពុជាក្រោម បានរៀបចំពិធីសម្ពោធជាផ្លូវការ និងមានកិច្ចអភិសេករួបសំណាក ឧកញ៉ា **ស៊ឹង គុយ** នៅថ្ងៃទី ១២ និង ១៣ ខែកក្កដា ឆ្នាំ ២០២៥ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ សមាជិក អ្នកគាំទ្រ ព្រះសង្ឃ និងភ្ញៀវពាក់ព័ន្ធ ជាច្រើនរូប ។

ការសម្ពោធនេះបានក្លាយជាបំណុចសំខាន់មួយក្នុងប្រវត្តិ នៃការបង្កើតទីស្នាក់ការ **ស.ខ.ក.** នៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. ព្រោះវាបានបង្ហាញថា គម្រោងដែលចាប់ផ្តើមពីការពិភាក្សា និងការអំពាវនាវឱ្យមានការចូលរួមពីមហាជន បានឈានដល់ដំណាក់កាលដែលអគារអាចប្រើប្រាស់ជាផ្លូវការ ។

នៅថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០២៦ នៅក្នុងមហាសន្និបាតពិភពលោកលើកទី ១២ **ស.ខ.ក.** បានទូទាត់សងផ្តាប់ប្រាក់កម្ចីទាំងស្រុង បំពេញបេសកកម្មដែលខ្លួនបានខ្ចីសមាជិក ដើម្បីបង់ពេញផ្តាប់ថ្លៃអគារនៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០២៥ ។ នេះបំណុចដ៏សំខាន់មួយ ធ្វើឱ្យកេរ្តិ៍ឈ្មោះរបស់សហព័ន្ធស្អាតស្អំនៅក្នុងអភិបាលកិច្ចផ្ទៃកហិរញ្ញវត្ថុ និងធ្វើឱ្យទីស្នាក់ការក្លាយជាទ្រព្យសម្បត្តិរួមមួយ ដែលអាចបម្រើការងាររបស់សហព័ន្ធក្នុងរយៈពេលយូរអង្វែង ។

សរុបសេចក្តីមក ការបង្កើតទីស្នាក់ការនេះ គឺជាជំណើរមួយដែលចាប់ផ្តើមពីការពិភាក្សារបស់គណៈកម្មការនាយក នៃ **ស.ខ.ក.** តាំងឆ្នាំ ២០២៤ បន្តទៅការអំពាវនាវ និងមានការចូលរួមបរិច្ចាគពីជុំវិញពិភពលោក រហូតសម្រេចបានទូវការទិញអគារ ធ្វើការជួសជុលកែលម្អ ហើយសម្ពោធជាផ្លូវការ និងបានទូទាត់សងផ្តាប់ប្រាក់កម្ចីជាស្ថាពរនៅក្នុងឆ្នាំ ២០២៦ ។

ជាមួយនឹងថវិកាប្រមាណ **៣៧០,០០០ ដុល្លារអាមេរិក** ដែលបានប្រើប្រាស់សម្រាប់ការទិញ និងជួសជុលកែលម្អ ព្រមទាំងកសាងរូបសំណាកឧកញ៉ា **ស៊ឹង គុយ** ទីស្នាក់ការនេះ បានក្លាយជាមូលដ្ឋានសម្រាប់ការងាររបស់ **ស.ខ.ក.** នៅរដ្ឋធានីសហរដ្ឋអាមេរិក ។

លើសពីតម្លៃជាអគារធម្មតា ទីស្នាក់ការនេះ ត្រូវបានសហព័ន្ធកំណត់អត្ថន័យជាទីតាំងសម្រាប់បម្រើការងារការទូត ការតស៊ូមតិ ការរក្សាទុកឯកសារ និងការផ្សព្វផ្សាយចំណេះដឹងអំពីប្រវត្តិសាស្ត្រ និងអត្តសញ្ញាណខ្មែរក្រោម ។ និមិត្តសញ្ញានៃទីតាំង ដូចជាពាក្យ «Independence» និងលេខអាសយដ្ឋាន **4953** ក៏ត្រូវបានសហព័ន្ធភ្ជាប់ជាមួយប្រវត្តិសាស្ត្រ និងគោលគំនិតស្តីពី **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** ។

ប្រវត្តិរូបសំណាកវីរបុរសជាតិនៅដែនដីកម្ពុជាក្រោម ឧកញ៉ា សឺន គុយ

ដោយ **ថាប់ ប្រ៊ីជា គឿន**

បន្ទាប់ពីគណៈកម្មការនាយក នៃ **ស.ខ.ក.** បានសម្រេចជាផ្លូវការឱ្យទិញទីស្នាក់ការ នៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. អង្គប្រជុំបានសម្រេចផ្តល់ភារកិច្ចជូនលោក **ថាប់ ប្រ៊ីជា គឿន** ឱ្យដឹកនាំការកសាងរូបសំណាកវីរបុរសជាតិកម្ពុជាក្រោម គឺ ឧកញ៉ាសេនាបតី សឺន គុយ ដើម្បីតម្កល់នៅមុខទីស្នាក់ការសហព័ន្ធ ។

បន្ទាប់ពីទទួលភារកិច្ច លោក **ថាប់ ប្រ៊ីជា គឿន** បានស្វែងរកសិល្បករដែលមានជំនាញ និងបទពិសោធន៍ផ្នែកសូនរូប និងបម្លាក់ ព្រមទាំងមានការបណ្តុះបណ្តាលត្រឹមត្រូវពីស្ថាប័នសិល្បៈ ។ ជាលទ្ធផល លោកបានជ្រើសរើស លោក **គិន បន្នី** ដែលជាសិល្បករជំនាញផ្នែកសូនរូប និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រឯកទេសចម្លាក់ ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នៃប្រទេសកម្ពុជា ។ លោក **គិន បន្នី** ក៏ធ្លាប់មានស្នាដៃសូន និងឆ្លាក់រូបសំណាកល្បីៗជាច្រើន រួមមានរូបសំណាកអតីតព្រះមហាក្សត្រខ្មែរ ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ដែលមានកាយវិការទ្រង់ឈរកាន់ព្រះរាជសារ និងបង្ហុលបង្ហាញទៅមុខ ជាក់តាំងនៅក្នុងបរិវេណសាលាជាដើម ។



រូបសំណាកវីរបុរសជាតិនៅដែនដីកម្ពុជាក្រោម សឺន គុយ នៅមុខទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម ។

លោក **ថាប់ ប្រ៊ីជា គឿន** បានចាប់ផ្តើមទាក់ទង និងពិភាក្សាជាមួយលោក **គិន បន្នី** អំពីគម្រោងកសាងរូបសំណាក ឧកញ៉ា សឺន គុយ តាំងពីដើមខែមករា ឆ្នាំ ២០២៥ ។ ក្នុងដំណើរការនេះ មានការផ្តល់រូបថត និងឯកសារជាច្រើនជាប្រភពយោង សម្រាប់គូររូបព្រាង រចនាទម្រង់ និងសូនពុម្ពរូបសំណាក ។ មុនពេលសូនរូប លោក **ថាប់ ប្រ៊ីជា គឿន** បានយកគម្រោងបង្ហាញ និងពិភាក្សាជាមួយនឹងថ្នាក់ដឹកនាំ **ស.ខ.ក.** នៅទីក្រុង សាន ហ្សូស្សេ រដ្ឋកាលីហ្វ័រញ៉ា ក្នុងនោះរួមមាន ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា** លោក **ម៉ៅ មុនី** និង លោក **ថាប់ រឿង** ជាដើម និងបានបង្ហាញគំរោងដល់ថ្នាក់ដឹកនាំ **ស.ខ.ក.** នៅក្នុងអង្គប្រជុំផងដែរ ដើម្បីសម្រេចរួមគ្នា ។

បន្ទាប់ពីការសូនពុម្ពត្រូវបានបញ្ចប់ លោក **គិន បន្នី** បានប្រគល់ពុម្ពទៅ លោក **សុខ ពិសិដ្ឋ** ដែលជាជាងចម្លាក់ព្រះស្ពាន់ មានទីតាំងនៅខេត្តកំពង់ស្ពឺ ដើម្បីចាក់ជាស្ពាន់ ។ ដំណើរការកសាងរូបសំណាកត្រូវបានបញ្ចប់ជាស្ថាពរ នៅថ្ងៃទី **២៧ ខែឧសភា ឆ្នាំ ២០២៥** ត្រូវនឹងថ្ងៃអង្គារ ១ កើត ខែជេស្ឋ ឆ្នាំរោង សប្តស័ក ព.ស. ២៥៦៩ បន្ទាប់ពីប្រើ រយៈពេលប្រមាណ **៥ ខែ** ។

ប្រភព និងលំនាំសម្រាប់កសាងរូបសំណាកៈ

ដើម្បីឱ្យរូបសំណាកមានលក្ខណៈប្រណីត និងរក្សាបានន័យវិអត្ត សញ្ញាណសិល្បៈខ្មែរ លោក **គិន បន្នី** បានយកប្រភពរូបភាព និងឯកសារមួយចំនួនមកធ្វើជាគោលក្នុងការសូនរូប ។ ប្រភពសំខាន់ៗ រួមមានរូបគំនូរដែលគូរឡើងក្នុងឆ្នាំ ២០១៧ ដោយលោក **ថៃ សាន**



ពីឆ្វេងទៅស្តាំ៖ **ទីមួយ** រូបឧកញ៉ា សឺន គុយ នៅលើក្របសៀវភៅ **"ចៅហ្វាយ គុយ"** និពន្ធដោយ កែវ សុវត្ថិ ឆ្នាំ ១៩៧១, ក្រោយមក លោក ថាច់ សេ ដាក់នៅលើក្របសៀវភៅ "ទុក្ខខ្មែរក្រោម" ។ **ទីពីរ** រូបគំនូរប្រែងគូរដោយ លោក អ៊ុយ សុភ័ក្ត្រ តាំងនៅការិយាល័យ មិត្តសមាគមខ្មែរកម្ពុជាក្រោម នៅវត្តសាមគ្គីរង្សី ។ **ទីបី** រូបគំនូរគូរដោយ លោក ថៃ សាន នៅភ្នំពេញ ឆ្នាំ ២០១៧ ។

វិបិត្រកររួយរូបនៅប្រទេសកម្ពុជា ព្រមទាំងរូបមុខឧកញ៉ា **សឺន គុយ** ដែលបង្ហាញនៅលើក្របសៀវភៅ **«ចៅហ្វាយ គុយ»** បោះពុម្ពនៅឆ្នាំ ១៩៧១ និពន្ធដោយលោក **កែវ សុវត្ថិ** ។ លើសពីនេះ ក៏មានការយោងតាមរូបគំនូររបស់លោក **អ៊ុយ សុភ័ក្ត្រ** ជាអតីតអគ្គលេខាធិការ នៃ **មិត្តសមាគមខ្មែរកម្ពុជាក្រោម** នៅប្រទេសកម្ពុជា ។ ការយកប្រភពរូបភាពទាំងនេះមកធ្វើជាមូលដ្ឋាន បានជួយឱ្យសិល្បករអាចបង្កើតរូបសំណាកដែលឆ្លុះបញ្ចាំងមរក្បាទម្រង់ និងអត្តសញ្ញាណរបស់ឧកញ៉ា **សឺន គុយ** តាមប្រភពប្រវត្តិសាស្ត្រ និងស្នាដៃសិល្បៈដែលមានស្រាប់ ។

ភាពដូចបេះបិទ និងភាពអស្ចារ្យ

ព្រះឥន្ទ្រិមុនី ម៉ឺង សាង (ញាណសារោ) ជាប្រធាន**ពុទ្ធិកសមាគមព្រះសង្ឃខ្មែរ-សហរដ្ឋអាមេរិក** បានថ្លែងនៅក្នុងពិធីសម្ពោធ ទីស្នាក់ការ **ស.ខ.ក.** នៅរដ្ឋធានី Washington ឌីស៊ី សហរដ្ឋអាមេរិក ថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០២៥ ថា រូបសំណាកឧកញ៉ា **សឺន គុយ** ត្រូវបានវិបិត្រកររឿងយ៉ាងប៉ិនប្រសប់ និងដូចគំនរូបរាងពិតរបស់លោកយ៉ាងខ្លាំង រហូតដល់ធ្វើឱ្យអ្នកដែលបានឃើញរូបសំណាក មានអារម្មណ៍ដូចជាបានឃើញ និងរំឭកដល់ព្រលឹងរបស់វីរបុរសឧកញ៉ា សឺន គុយ ដែលកំពុងស្ថិតនៅទីនោះ ។ តាមរយៈរូបសំណាកនេះ អ្នកទស្សនាអាចនឹកឃើញឡើងវិញនូវអតីតកាល និងការតស៊ូដ៏អង់អាចរបស់លោកឧកញ៉ា សឺន គុយ ក្នុងប្រវត្តិសាស្ត្រខ្មែរកម្ពុជាក្រោម ។ ព្រះអង្គថ្លែងយ៉ាងនេះថា៖

"ថ្ងៃនេះ បងប្អូនខ្មែរ ព្រះសង្ឃ និងប្រជាពលរដ្ឋយើង បានធ្វើពិធីរៀបចំដើម្បីរំឭកដ៏ក្រៃលែង នោះគឺ ពិធីអភិសេករូបបដិមា ដែលជាស្នាដៃនៃវិបិត្រកររឿងដ៏ប៉ិនប្រសប់ ដូចបេះបិទ ដូចជាព្រលឹងរបស់លោកឧកញ៉ា សឺន គុយ មកស្ថិតនៅទីនេះ ដែលយើងបានឃើញរូបបដិមាហើយ យើងបានសម្លឹងមើលឃើញ បាននឹកឃើញនូវអតីតកាល នៃការតស៊ូដ៏អង់អាចរបស់លោកវីរបុរស សឺន គុយ" ។

នៅបំពេះមុខសមិទ្ធផលដ៏មានអត្ថន័យ ដែលកំពុងឈរត្រដែតនៅទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម លោក **ជុន ប័ន្ធបុត្រ** អតីតប្រធានការិយាល័យ អ្នកសម្របសម្រួលកិច្ចសម្ភាសន៍ និងអ្នកដឹកនាំកម្មវិធីផ្សាយផ្នែកភាសាខ្មែរ នៃវិទ្យុអាស៊ីសេរី បានសម្តែងការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះសមិទ្ធផលនេះ ។



លោក ជុន ប័ន្ធបុត្រ ថ្លែងនៅក្នុងពិធីសម្ពោធ ទីស្នាក់ការ ស.ខ.ក. នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០២៥ ។

លោកបានបញ្ជាក់ថា អ្វីដែលលោកមើលឃើញនៅបំពេះមុខមិនមែនមានត្រឹមតែអគារទីស្នាក់ការ **ស.ខ.ក.** ប៉ុណ្ណោះទេ ប៉ុន្តែអ្វីដែលលោកចាប់អារម្មណ៍ និងចាត់ទុកថាមានអត្ថន័យជ្រាលជ្រៅ គឺ **រូបសំណាកឧកញ៉ា សឺន គុយ** ដែលត្រូវបានតាំងយ៉ាងសមរម្យនៅខាងមុខទីស្នាក់ការ ។

តាមការយល់ឃើញរបស់លោក **ជុន ប័ន្ធបុត្រ** ការតាំងរូប

សំណាកឧកញ៉ា **សឺន គុយ** នេះ គឺជាសមិទ្ធផលដ៏អស្ចារ្យមួយ ដែលមិនគួរត្រូវបានមើលឃើញត្រឹមជាស្នាដៃស្ថាបត្យកម្ម ឬជារូបសំណាកធម្មតាមួយឡើយ ។ ផ្ទុយទៅវិញ វាជានិមិត្តរូបនៃការគោរពបងប៉ាំ និងរំឭកដល់វីរភាពរបស់បុព្វបុរសខ្មែរក្រោម ដែលបានបន្សល់ទុកនូវមរតកប្រវត្តិសាស្ត្រ និងស្មារតីតស៊ូសម្រាប់កូនខ្មែរជំនាន់ក្រោយ ។

លោកបានថាត់ទុកការតាំងរូបសំណាកនេះថាជា **ការទុទ្ធិសដ៏សក្តិសមបំពោះ ឧកញ៉ា សឺន គុយ** ដែលធ្វើឱ្យទីស្នាក់ការ **ស.ខ.ក.** មិនត្រឹមតែជាទីកន្លែងសម្រាប់ការងាររបស់អង្គការប៉ុណ្ណោះទេ ប៉ុន្តែបែមទាំងក្លាយជាទីកន្លែងមួយសម្រាប់រំឭកដល់ប្រវត្តិសាស្ត្រ វីរភាព និងអត្តសញ្ញាណនៃពលរដ្ឋខ្មែរក្រោម ផងដែរ ។ នៅក្នុងពិធីសម្ពោធទីស្នាក់ លោកបានមានប្រសាសន៍យ៉ាងនេះថា៖

---

*"ដោយគោរព និងសរសើរអស់ពីបេះដូងតែម្តងបំពោះសមិទ្ធផលដ៏អស្ចារ្យមួយ ដែលតាំងពីមុខយើងនេះ ខ្ញុំមិនចង់និយាយត្រឹមតែអគារ នៃទីស្នាក់ការ **ស.ខ.ក.** តែប៉ុណ្ណោះទេ ខ្ញុំនិយាយអំពីការតាំងរូបសំណាកវីរបុរសខ្មែរកម្ពុជាក្រោម នោះគឺរូបសំណាករបស់ ឧកញ៉ា សឺន គុយ ដែលកំពុងតែឈរត្រជែតនៅបំពោះមុខយើងនេះតែម្តង ។ ខ្ញុំគិតថា នេះគឺជាការទុទ្ធិសមួយដល់ ឧកញ៉ា សឺន គុយ ដ៏សក្តិសមអ្វីម្លេះទេ បំពោះ ទីស្នាក់ការខ្មែរកម្ពុជាក្រោម នាពេលនេះ" ។*



ថតរូបជុំគ្នាមុខរូបសំណាក ឧកញ៉ា សឺន គុយ ។

ការដឹកជញ្ជូនរូបសំណាកមកសហរដ្ឋអាមេរិក៖

បន្ទាប់ពីសូនពុម្ព និងចាក់ជាស្ពាន់រួចរាល់ រូបសំណាកមានកម្ពស់ **១ ម៉ែត្រ ៧០ សង់ទីម៉ែត្រ** និងទម្ងន់ **២២៣.៤០ គីឡូក្រាម** ។ រូបសំណាកត្រូវបានរៀបចំដឹកជញ្ជូនចេញពីរាជធានីភ្នំពេញ ប្រទេសកម្ពុជា នៅថ្ងៃទី **២០ ខែមិថុនា ឆ្នាំ ២០២៥** ហើយបានមកដល់សហរដ្ឋអាមេរិក នៅថ្ងៃទី **២១ ខែមិថុនា ឆ្នាំ ២០២៥** ។

ក្នុងដំណើរការរៀបចំការដឹកជញ្ជូនរូបសំណាកនេះ លោក **តាំង សារៈ** ជាប្រធានតំបន់ នៃ **ស.ខ.ក.** នៅកម្ពុជា លោក **សឺន យឿង** លោក **ស៊ឹន បែងបើន** លោក **គិន បន្នី** និងលោក **សុខ ពិសិដ្ឋ** បានចូលរួមយ៉ាងសកម្មក្នុងការទាក់ទង និងសម្របសម្រួលជាមួយក្រុមហ៊ុនដឹកជញ្ជូន ក្នុងការដាក់សំណើទៅកាន់ **ក្រសួងវប្បធម៌** និង**វិចិត្រសិល្បៈ** និង **អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា** ដើម្បីស្នើសុំការអនុញ្ញាត និងបំពេញនីតិវិធីពាក់ព័ន្ធនឹងការដឹកជញ្ជូនរូបសំណាកនេះ នាំចេញពីប្រទេសកម្ពុជា ដោយមាន ព្រះតេជព្រះគុណ **សឺង ឃុីង រតនា** ឈរឈ្មោះក្នុងនាម **ស.ខ.ក.** ។

រូបសំណាកស្ពាន់មានកម្ពស់ **១ ម៉ែត្រ ៧០ សង់ទីម៉ែត្រ** ខណៈបល្ល័ង្កស៊ីម៉ង់សម្រាប់តម្កល់ មានកម្ពស់ប្រមាណ **១ ម៉ែត្រ** ។ ដូច្នេះរូបសំណាកដែលតម្កល់នៅមុខទីស្នាក់ការសហព័ន្ធសព្វថ្ងៃ មានកម្ពស់សរុបប្រមាណ **២ ម៉ែត្រ ៧០ សង់ទី ម៉ែត្រ** ។

ការតាំងរូបសំណាកទៅតម្កល់នៅទីស្នាក់ការ៖

នៅថ្ងៃទី **២២ ខែមិថុនា ឆ្នាំ ២០២៥** បន្ទាប់ពីរូបសំណាកបានមកដល់សហរដ្ឋអាមេរិក ព្រះតេជព្រះគុណ **សឺង ឃុីង រតនា** ដែលពេលនោះជាប្រធានគណៈកម្មការព័ត៌មាន នៃ **ស.ខ.ក.** បានដឹកនាំក្រុមការងារទៅកាន់ក្រុមហ៊ុនដឹកជញ្ជូន ដើម្បីតាំរូបសំណាកមកកាន់ទីស្នាក់ការសហព័ន្ធ នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. ។

ក្នុងដំណើរតាំរូបសំណាកដោយរបៀបយន្តមកទីស្នាក់ការ ព្រះសង្ឃក៏បានស្វាធ្យាយធម៌បម្រើនជ័យមង្គល តាមប្រពៃណីព្រះពុទ្ធសាសនាផងដែរ ។ បន្ទាប់ពីរៀបចំពិធីសុំម្ងាស់ទឹកម្ងាស់ដីរួចរាល់ហើយ ក្រុមការងារបានចាប់ផ្តើមលើក និងតម្កល់រូបសំណាកឡើងលើឈរលើបល្ល័ង្កនៅមុខទីស្នាក់ការ ។

អ្នកដែលបានរួមចំណែកក្នុងការធ្វើបល្ល័ង្ក និងលើករូបសំណាក

រួមមាន ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា** ព្រះតេជព្រះគុណ **ថាប់ ខៃ** ព្រះតេជព្រះគុណ **ថាប់ សំណាង (ភារៈ)** ព្រះតេជព្រះគុណ **ថាប់ យាន់** គ្រួសារ **លោក សឺន ថាយ ធន** លោក **ថាប់ ឡុង** លោក **ថាប់ ស៊ីវុត្ថា** លោក **រស់ ថៃ** និងលោក **លួន បត្តា** ។

ការកសាង និងការតម្កល់រូបសំណាកលោកឧកញ៉ា **សឺន គុយ** នៅមុខទីស្នាក់ការ **ស.ខ.ក.** គឺជាការរួមចំណែកពីសំណាក់ថ្នាក់ដឹកនាំ សមាជិក សមាជិកា ព្រះសង្ឃ និងអ្នកគាំទ្រជាច្រើនរូប ដែលបានចូលរួមទាំងផ្នែកគំនិត ការសម្របសម្រួល ការសាងសង់ ការដឹកជញ្ជូន ការតម្កល់ និងបានផ្តល់ជាថវិកាប្រមាណ **$១០,០០០ ដុល្លារសហរដ្ឋអាមេរិក** ក្នុងការកសាង និងដឹកជញ្ជូនផងដែរ ។ រូបសំណាកនេះ ត្រូវបានតម្កល់ជានិមិត្តរូបនៃការរំឭកដល់ជីវិត ស្នាដៃ និងវីរភាពរបស់ឧកញ៉ា **សឺន គុយ** ដែលជាបុគ្គលសំខាន់មួយរូបក្នុងប្រវត្តិសាស្ត្រកម្ពុជាក្រោម និងជានិមិត្តរូបនៃស្មារតីស្នេហាជាតិរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅជុំវិញពិភពលោក ក្នុងការតស៊ូដោយសន្តិវិធីដើម្បី **«សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»** នៃប្រជាជាតិខ្មែរក្រោមនៅដែនដីកម្ពុជាក្រោម ។



កាត់ខ្សែបូរនៅមុខរូបសំណាក ឧកញ៉ា សឺន គុយ ថ្ងៃសម្ពោធ ទីស្នាក់ការ ។



គោលការណ៍ ១០ ចំណុច ដែលសម្រេចដោយប្រតិភូចូលរួម មហាសន្និបាតពិភពលោក លើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម

សហព័ន្ធខ្មែរកម្ពុជាក្រោម បានចេញ «សេចក្តីប្រកាសក្រុងវ៉ាស៊ីងតោន ឌី.ស៊ី. ឆ្នាំ ២០២៦» នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២៦ បន្ទាប់ពីមហាសន្និបាតពិភពលោកលើកទី ១២ ដែលបានប្រព្រឹត្តទៅនៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. ដោយមានការចូលរួមពីប្រតិភូតំណាងទូទាំងពិភពលោក ។ សេចក្តីប្រកាសនេះ ត្រូវបានអនុម័តជាឯកច្ឆន្ទ ដោយកំណត់គោលការណ៍សំខាន់ ១០ ចំណុច រួមមាន ការពង្រឹងសាមគ្គីភាពជាសកល ការតស៊ូមតិដោយសន្តិវិធីលើឆាកអន្តរជាតិ ការការពារសិទ្ធិមនុស្ស និងអត្តសញ្ញាណជនជាតិដើម ការអភិរក្សភាសា វប្បធម៌ និងសាសនា ការផ្តល់សិទ្ធិអំណាចដល់សមាជិក ការបណ្តុះបណ្តាលយុវជន ការពង្រីកភាពជាដៃគូអន្តរជាតិ ការការពារបរិស្ថាន និងការពង្រឹងសហព័ន្ធឱ្យកាន់តែរឹងមាំ ដើម្បីបន្តការតស៊ូមតិសម្រាប់សិទ្ធិ សេចក្តីថ្លៃថ្នូរ និងអនាគតរបស់ប្រជាជាតិខ្មែរក្រោមនៅកម្ពុជាក្រោម ។

បុព្វកថា

យើងខ្ញុំជាប្រតិភូ មហាសន្និបាតពិភពលោកលើកទី ១២ របស់សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលតំណាងឱ្យសមាជិក និងសមាជិកាទូទាំងពិភពលោក បានជួបប្រជុំគ្នានៅទីក្រុងវ៉ាស៊ីងតោន ឌី.ស៊ី. នៅថ្ងៃទី ១៨ និង ១៩ ខែកក្កដា ឆ្នាំ ២០២៦ ដើម្បីបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់យើងចំពោះការតស៊ូមតិដោយសន្តិវិធី ដើម្បីសិទ្ធិសេចក្តីថ្លៃថ្នូរ និងអនាគតរបស់ប្រជាជាតិខ្មែរក្រោម ដែលជាជនជាតិដើមនៃដែនដីកម្ពុជាក្រោម ។



មហាសន្និបាតពិភពលោក លើកទី ១២ នៃ ស.ខ.ក. នៅរដ្ឋធានីវ៉ាស៊ីងតោន ឌី.ស៊ី. ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ ។ រូបថតៈ ថាច់ សុម៉ាលីន

សន្និបាតនេះ ក៏ជាការរំឭកដល់ខួប ៣០ ឆ្នាំ នៃការអនុម័តឈ្មោះ **«សហព័ន្ធខ្មែរកម្ពុជាក្រោម»** (**ស.ខ.ក.**) ដែលតំណាងឱ្យស្មារតីភាពសេចក្តីព្យាយាមអត់ធ្មត់ និងការតស៊ូមតិនៅលើឆាកអន្តរជាតិរយៈពេលបីទសវត្សរ៍សម្រាប់ប្រជាជនរបស់យើង ។

ក្នុងឱកាសមហាសន្និបាតនេះដែរ យើងខ្ញុំក៏ធ្វើសេចក្តីគោរពដឹងគុណយ៉ាងក្រៃលែងចំពោះវីរបុរសជាតិ និងបុព្វការីជនគ្រប់ជំនាន់ ក្នុងនោះ មានវីរសមណៈជាទីគោរពសក្ការៈ មេដឹកនាំគ្រប់រូបនៅក្នុង **ស.ខ.ក.** សមាគមនានា និងពលរដ្ឋទាំងអស់ ដែលបានលះបង់ដើម្បីថែរក្សាអត្តសញ្ញាណជាតិ វប្បធម៌ ភាសា សាសនា និងសិទ្ធិជាមូលដ្ឋានរបស់ខ្មែរក្រោម ។ យើងខ្ញុំសូមគោរពជាពិសេសចំពោះអ្នកដែលបន្តស៊ូទ្រាំប្រឈមនឹងការជាប់ពន្ធនាគារ ការគំរាមកំហែង ការរើសអើង និងប្រឈមទម្រង់ផ្សេងៗទៀត នៃការបៀតបៀនពីរបបអាណានិគមយួន បំពោះការអនុវត្តសិទ្ធិមនុស្សដែលទទួលស្គាល់ជាសកល ។

ដោយមើលឃើញបញ្ហាប្រឈមកាន់តែខ្លាំងឡើងដែលខ្មែរក្រោមកំពុងជួបប្រទះ រួមទាំងការរឹតត្បិតលើសេរីភាពសាសនា ឬជំនឿ ការបង្ក្រាបលើការបញ្ចេញមតិ ការបាត់បង់ដីដូនតា ការរិចរិលបរិស្ថាននៅក្នុងតំបន់ដែនដីកម្ពុជាក្រោម ការគំរាមកំហែងដល់អត្តសញ្ញាណជនជាតិដើម និងការគំរាមកំហែងឆ្លងដែនពីរបបអាណានិគមយួន យើងខ្ញុំប្តេជ្ញាថា នឹងបន្តពង្រឹងបលនាតស៊ូជាសកលរបស់យើង ដោយសាមគ្គីភាព ធ្វើការតស៊ូមតិដោយសន្តិវិធី និងធ្វើសកម្មភាពដែលប្រកបដោយអត្ថន័យសម្រាប់ប្រជាជាតិរបស់យើង ។

អាស្រ័យហេតុនេះ យើងខ្ញុំបានបេញសេចក្តីសម្រេច ដូចតទៅៈ

១. ពង្រឹងនូវសាមគ្គីភាពជាសកល

យើងសូមបញ្ជាក់ជាថ្មីថា កម្លាំងនៃបលនាតស៊ូរបស់ខ្មែរក្រោមស្ថិតនៅក្នុងសាមគ្គីភាពជាសកល ក្នុងគោលការណ៍នៃប្រជាធិបតេយ្យ និងសេរីភាព ។ យើងសូមសន្យាថា នឹងធ្វើការជាមួយគ្នានៅក្នុងបំណោមមនុស្សគ្រប់វ័យ គ្រប់ហានុក្រមតំបន់ និងប្រទេសនានា

ដោយការគោរពគ្នាទៅវិញទៅមក ការទទួលខុសត្រូវរួមគ្នា និងឈរលើបក្ខវិស័យរួមគ្នា ។

២.បន្តការតស៊ូមតិលើឆាកអន្តរជាតិដោយសន្តិវិធី

យើងសូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ **ស.ខ.ក.** បំពេះការតស៊ូមតិដោយសន្តិវិធីតាមរយៈប្បាប់អន្តរជាតិ និងការចូលរួមជាមួយនឹងអង្គការសហប្រជាជាតិ រដ្ឋាភិបាលប្រជាធិបតេយ្យ ស្ថាប័នតំបន់ និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់សិទ្ធិរបស់ខ្មែរក្រោម ។

៣. ការពារសិទ្ធិមនុស្សជាមូលដ្ឋាន

យើងសូមអំពាវនាវឱ្យមានការការពារសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋខ្មែរក្រោម រួមទាំងសេរីភាពសាសនា ឬជំនឿ ការបញ្ចេញមតិ និងការជួបជុំគ្នាដោយសន្តិវិធី សិទ្ធិក្បាវិប្បវធម៌ និងភាសា សិទ្ធិដីធ្លី និងសិទ្ធិរបស់ជនជាតិដើមក្នុងការរក្សា និងពង្រឹងអត្តសញ្ញាណជាតិ និងស្ថាប័នរបស់ខ្លួន ។

៤. បន្តទាមទារឱ្យរបបយួនដោះលែងខ្មែរក្រោម

យើងនៅតែបន្តបលនាអំពាវនាវឱ្យមានការដោះលែងជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌនូវព្រះសង្ឃ ពលរដ្ឋខ្មែរក្រោមទាំងអស់ ដែលរបបយួនចាប់ដាក់គុក ឬធ្វើទុក្ខបុកម្នេញ ដោយសារតែការអនុវត្តនិងប្រើប្រាស់នូវសិទ្ធិមនុស្សជាមូលដ្ឋានរបស់ខ្លួនដោយសន្តិវិធី ។

៥. ការពារអត្តសញ្ញាណជនជាតិដើម

យើងសូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់យើងក្នុងការអភិរក្ស ភាសា វប្បធម៌ ប្រពៃណី ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌព្រះពុទ្ធសាសនាថេរវាទនៃពលរដ្ឋខ្មែរក្រោម និងអប់រំមនុស្សជំនាន់ក្រោយអំពីអត្តសញ្ញាណជាតិ និងការទទួលខុសត្រូវរបស់ខ្លួនបំពេះវាសនាជាតិ ។

៦. ផ្តល់សិទ្ធិអំណាចដល់ខ្មែរក្រោមគ្រប់រូប

យើងទទួលស្គាល់ថា បុព្វហេតុតស៊ូយូរអង្វែងរបស់យើងមិនមែនជាការពឹងផ្អែកលើបន្ទុករបស់មេដឹកនាំរូបណាតែម្នាក់ឯងនោះទេ ។ ពលរដ្ឋខ្មែរក្រោមគ្រប់រូបអាចចូលរួមចំណែកតាមរយៈការតស៊ូមតិ ការអប់រំ ផ្តល់ជាជំនួយដល់ប្រជាជនៅក្នុងភូមិស្រុក តាមរយៈជំនាញវិជ្ជាជីវៈ បរិញ្ញវត្ថុ ការចូលរួមរបស់យុវជន ឬការយល់ដឹងជាសាធារណៈជាដើម ។ យើងសូមលើកទឹកចិត្តដល់សមាជិក សមាជិកាម្នាក់ៗ នៃពលរដ្ឋខ្មែរក្រោមឱ្យមានការប្តេជ្ញាចិត្តផ្ទាល់ខ្លួន ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ក្នុងការអភិវឌ្ឍជាតិរបស់យើងឱ្យកាន់តែប្រសើរ និងថ្លៃថ្នូរឡើង ។

៧. បណ្តុះបណ្តាលមនុស្សស្រម្រាប់បន្តវេន

យើងប្តេជ្ញាថានឹងបន្តបណ្តុះបណ្តាលភាពជាអ្នកដឹកនាំរបស់យុវជនតាមរយៈការផ្តល់ឱកាសឱ្យពួកគាត់អភិវឌ្ឍខ្លួន បង្កើនចំណេះដឹងជំនាញ និងបទពិសោធន៍ ដែលជាតម្រូវការចាំបាច់របស់ជាតិ ដើម្បីបន្តការតស៊ូមតិដោយសន្តិវិធីយូរអង្វែងរបស់យើង សម្រាប់មនុស្សជំនាន់ក្រោយ ។

៨. ពង្រឹកភាពជាដៃគូអន្តរជាតិ

យើងនឹងបន្តកសាងភាពជាដៃគូស្ថាបនាជាមួយអង្គការជនជាតិដើម អ្នកការពារសិទ្ធិមនុស្ស ស្ថាប័នសិក្សា រដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើម្បីលើកកម្ពស់ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ខ្មែរក្រោម ។

៩. ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយចីរភាព

ដោយមើលឃើញថា បញ្ហាប្រឈមផ្នែកបរិស្ថានកាន់តែធ្ងន់ធ្ងរនៅដែនដីកម្ពុជាក្រោម យើងនឹងបន្តតស៊ូមតិសម្រាប់ការចូលរួមដ៏សកម្មរបស់ខ្មែរក្រោមក្នុងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ដីដូនតា និងធនធានធម្មជាតិរបស់យើង និងជំរុញឱ្យមានគោលនយោបាយអភិវឌ្ឍន៍ដែលគោរពសិទ្ធិជនជាតិដើម ។

១០. ពង្រឹង សហព័ន្ធខ្មែរកម្ពុជាក្រោម ឱ្យកាន់តែរឹងមាំ

យើងប្តេជ្ញាថា និងរួមគ្នាពង្រឹងបលនាតស៊ូ **ស.ខ.ក.** ឱ្យកាន់តែរឹងមាំ តាមរយៈតម្លាភាព ការទទួលខុសត្រូវ ភាពជាអ្នកដឹកនាំដែលមានការទទួលខុសត្រូវខ្ពស់ ពង្រីកសមាជិកភាព និងការចូលរួមកាន់តែប្រែនៅតាមសាខា និងសមាជិក សមាជិកាម្នាក់ៗ នៅក្នុងពិភពលោក ដើម្បីរក្សានូវនិរន្តរភាព កម្លាំងគាំទ្រដល់បលនាតស៊ូរបស់ **ស.ខ.ក.** ។

ការប្តេជ្ញាចិត្តរបស់យើង

ក្នុងនាមជាអ្នកតំណាងនៃមហាសន្និបាតនេះ យើងខ្ញុំសូមប្តេជ្ញាចិត្តថា នឹងចូលរួមចំណែកទៅតាមសមត្ថភាព និងកាលៈទេសៈរបស់ខ្លួន ។

យើងទទួលស្គាល់ថាអនាគតរបស់ខ្មែរក្រោមមិនត្រឹមតែអាស្រ័យទៅលើថ្នាក់ដឹកនាំ **ស.ខ.ក.** តែប៉ុណ្ណោះទេ ប៉ុន្តែបែមទាំងអាស្រ័យទៅលើការលះបង់ សាមគ្គីភាព និងសកម្មភាពនាំឲ្យផ្លាស់ប្តូរពីសមាជិកពលរដ្ឋខ្មែរក្រោម គ្រប់រូបនៅក្នុងពិភពលោកផងដែរ ។

យើងខ្ញុំសូមប្តេជ្ញាចិត្តថា នឹងបន្តរក្សាគោលជំហរសាមគ្គីភាពជាមួយប្រជាពលរដ្ឋគ្រប់រូប និងបន្តកិច្ចខិតខំប្រឹងប្រែងដោយសន្តិវិធីដើម្បីលើកកម្ពស់យុត្តិធម៌ ការពារអត្តសញ្ញាណជាតិ សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជំនាន់បច្ចុប្បន្ន និងអនាគត នៃប្រជាជាតិខ្មែរក្រោមឲ្យកាន់តែប្រសើរឡើង ។

អនុម័តជាឯកច្ឆ័ន្ទដោយប្រតិភូ មហាសន្និបាតពិភពលោក លើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ។

រដ្ឋធានី វ៉ាស៊ីនតោន ឌី.ស៊ី. ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២៦

គណៈកម្មការនាយក នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម អាណត្តិ ២០២៦ - ២០៣០

អធិបតី

លោក **សឺន ហួរ**

ប្រធានប្រតិបត្តិ

លោក **ម៉ៅ មុនី**

អនុប្រធានប្រតិបត្តិ

អ្នកស្រី **កៀវ សុធី**

ប្រធានសភាតំណាង

លោក **គីម សិរ៉ា**

ប្រធានសភាព្រឹទ្ធាចារ្យ

លោក **ត្រឹង សារ៉ុង**

ប្រធានហេរញ្ញិក

លោក **ថាច់ សាម៉ន**

លេខាធិការ

ព្រះតេជព្រះគុណ **សឺង យ៉ឹង រតនា** (សុវណ្ណប្បញ្ញោ)

ប្រធានគណៈកម្មការទាំង ៤ របស់ សហព័ន្ធខ្មែរកម្ពុជាក្រោម

គណៈកម្មការសាសនា

ព្រះមហាថេរ ធម្មសទ្ធោ **កាន សុជាន**ណារិទ្ធ

គណៈកម្មការស្ត្រី

អ្នកស្រី **សឺង ធី និត**

គណៈកម្មការព័ត៌មាន

លោក **ថាច់ ប្រ៊ីជា គឿន**

គណៈកម្មការយុវជន

នាងកញ្ញា **ថាច់ តើជីញ៉ា**

ក្រៅពី ថ្នាក់ដឹកនាំជា «គណៈកម្មការនាយក» នៅមានសមាជិក «**ខ្ពស់ក្រៃក្រប្រឹក្សា**» នៅពីលើ អនុប្រធានសមាជិកគណៈកម្មការនាយក និងថ្នាក់ដឹកនាំនៅតាមសាខា និងតំបន់នៃរដ្ឋនានាក្នុងសហរដ្ឋអាមេរិក និងប្រទេសនានានៅក្នុងពិភពលោក ។

របាយការណ៍ស្តីពីសកម្មភាពរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម តំបន់ព្រះរាជាណាចក្រកម្ពុជា រយៈពេល ៣០ ឆ្នាំ (១៩៩៦ - ២០២៦)

សហព័ន្ធខ្មែរកម្ពុជាក្រោម (KKF) បានចាប់ផ្តើមមានតំណាងនៅព្រះរាជាណាចក្រកម្ពុជាតាំងពីឆ្នាំ ២០០០ ហើយបានពង្រឹងរចនាសម្ព័ន្ធ និងពង្រីកសកម្មភាពជាបន្តបន្ទាប់ ជាពិសេសចាប់ពីឆ្នាំ ២០០២ មក ។ សកម្មភាពមានដូចជា ការផ្សព្វផ្សាយគោលការណ៍ និងបេសកកម្ម ការភ្ជាប់ទំនាក់ទំនងជាមួយខ្មែរក្រោមនៅកម្ពុជា និងការចូលរួមក្នុងវេទិកាអន្តរជាតិរបស់ ស.ខ.ក. ។ នៅកម្ពុជាបានរួមចំណែកលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ អត្តសញ្ញាណ និងបញ្ហាប្រឈមរបស់ពលរដ្ឋខ្មែរកម្ពុជាក្រោម ព្រមទាំងពង្រឹងសាមគ្គីភាពជាមួយពលរដ្ឋខ្មែរក្រោមនៅជុំវិញពិភពលោក ។ ទោះបីប្រឈមនឹងកង្វះទីស្នាក់ការ ការមិនទាន់បានចុះបញ្ជី និងឧបសគ្គផ្សេងៗក្នុងការបំពេញការងារក៏ដោយ ស.ខ.ក. នៅកម្ពុជា បានបន្តសកម្មភាពផ្នែកសាសនា វប្បធម៌ សង្គម និងមនុស្សធម៌ ដោយសហការជាមួយព្រះសង្ឃ អង្គការ សមាគម និងសប្បុរសជនទាំងក្នុង និងក្រៅប្រទេស ។ សកម្មភាពទាំងនេះរួមមានការឧបត្ថម្ភវត្តអារាម ការជួយជនភៀសខ្លួន និងជនរងគ្រោះ ព្រមទាំងការផ្តល់អំណោយដល់កងទ័ពរងរបួស និងប្រជាពលរដ្ឋភៀសសឹក ។ អត្ថបទខាងក្រោមនេះ ជាការបង្ហាញអំពីប្រវត្តិសកម្មភាពសំខាន់ៗ និងការលំបាករបស់ ស.ខ.ក. នៅកម្ពុជា ចាប់ពីការកកើតដំបូង រហូតដល់ឆ្នាំ ២០២៦ ។

I. សេចក្តីផ្តើម

នៅពេលដែលមហាសន្និបាតសកលខ្មែរកម្ពុជាក្រោមលើកទី ៥ ដែលប្រព្រឹត្តទៅនៅទីក្រុងតូរ៉ុនតូ នៃប្រទេសកាណាដា នាខែសីហា ឆ្នាំ ១៩៩៦ បានសម្រេចប្តូរឈ្មោះ **សភាធម្មនុញ្ញខ្មែរកម្ពុជាក្រោម** ទៅជា **សហព័ន្ធខ្មែរកម្ពុជាក្រោម** ដែលពេលនោះ សម្តេចព្រះសាក្យមុនី កិត្តិបណ្ឌិតទស្សនវិជ្ជា **រ័ត្ន សារឿន** ជាព្រះចៅអធិការវត្តសុវណ្ណមុនីសាគរ សំរោងណ្លែត រាជធានីភ្នំពេញ ជាតំណាងអង្គការ សមាគមខ្មែរកម្ពុជាក្រោម នៅព្រះរាជាណាចក្រកម្ពុជា បានឯកមតិទៅចូលរួមផងដែរនោះ គឺព្រះអង្គត្រូវបានចាត់ទុកជាជាតំណាង **ស.ខ.ក.** នៅទីនោះ (កម្ពុជា) ។ ប៉ុន្តែអាស្រ័យដោយស្ថានភាពនយោបាយនៅកម្ពុជាពុំទាន់មានស្ថេរភាពផង អាស្រ័យដោយប្រព័ន្ធឃោសនារបស់ **ស.ខ.ក.** នៅមានកម្រិតផង មន្ត្រី **ស.ខ.ក.** ដែលធ្វើដំណើរទៅកាន់កម្ពុជា មានការយល់ដឹងពីគោលការណ៍ និងមាគ៌ារបស់ **ស.ខ.ក.** ពុំសូវប្រាស់លាស់ផង និងសកម្មភាពរបស់ **ស.ខ.ក.** ពុំទាន់បានទទួលលទ្ធផលគួរឱ្យកត់សម្គាល់ផង ទើបគេមើលឃើញថាក្នុងហ៊ានៈជាតំណាង **ស.ខ.ក.** របស់ព្រះតេជព្រះគុណតំណាងនៅកម្ពុជាពុំទាន់អាចធ្វើសកម្មភាពក្នុងភាពសកម្មនៅឡើយ ។

តែទោះជាយ៉ាងណាក៏ដោយព្រះអង្គក៏គឺជាមូលដ្ឋាន សម្រាប់ការទំនាក់ទំនងរវាង **ស.ខ.ក.** នៅបណ្តាប្រទេសនានាជាមួយនឹងខ្មែរក្រោមនៅកម្ពុជា ហើយវត្តសុវណ្ណមុនីសាគរសំរោងអណ្តែត គឺជាទីតាំងសម្រាប់បដិសណ្ឋារកិច្ចដល់មន្ត្រី **ស.ខ.ក.** ដូចជាការផ្តល់ទីកន្លែងស្នាក់នៅដល់មន្ត្រី **ស.ខ.ក.** ដើម្បីឈានទៅទំនាក់ទំនងនឹងមនុស្ស ឬមជ្ឈដ្ឋានដទៃទៀតលើកិច្ចការ **ស.ខ.ក.** និងកិច្ចការដទៃទៀតជាដើម ។ និងនៅក្នុងដំណើរបេសកម្មជាលើកដំបូងរបស់ថ្នាក់ដឹកនាំ **ស.ខ.ក.** គឺលោក **សឺន ទួត** ដែលពេលនោះជាប្រធានប្រតិបត្តិ និងលោក **ប្រាក់ សេរីវុឌ្ឍ** ដែលកាលនោះជាអនុប្រធានប្រតិបត្តិ នៃ



សកម្មភាពរបស់គណៈប្រតិភូ ស.ខ.ក. នៅកម្ពុជាត្រៀមផ្តល់អំណោយដល់ជនរងគ្រោះដោយបាក់ស្ពានកោះពេជ្រនៅតាមមន្ទីរពេទ្យនានា កាលពីឆ្នាំ ២០១០ ។ រូបថត៖ តាំង សារ:

ស.ខ.ក. ទៅកម្ពុជាក្នុងបុងខែធ្នូ ឆ្នាំ ២០០០ បានពន្យល់ខ្មែរក្រោមនៅកម្ពុជាឱ្យបានជ្រួតជ្រាបពីសកម្មភាព និងបេសកកម្មរបស់ **ស.ខ.ក.** នៅលើឆាកអន្តរជាតិ ។ បានធ្វើឱ្យខ្មែរក្រោមនៅកម្ពុជាចាប់ផ្តើមជ្រួតជ្រាបនូវគោលការណ៍ និងមាគ៌ារបស់ **ស.ខ.ក.** បានខ្លះៗ ។

កិត្តិនាម និងកិត្តិស័ព្ទរបស់ **ស.ខ.ក.** ចាប់ផ្តើមមានការជ្រួតជ្រាបក្នុងមជ្ឈដ្ឋានខ្មែរក្រោម ខ្មែរកណ្តាល រហូតដល់មជ្ឈដ្ឋានអ្នកនយោបាយខ្មែរនៅកម្ពុជាជាបណ្តើរៗ និងកាន់តែខ្លាំងឡើងជាលំដាប់នៅក្នុងអំឡុងឆ្នាំ ២០០១ និង ២០០២ តាមរយៈសកម្មភាព ដ៏សំខាន់ ២ គឺ៖

១- សកម្មភាពចូលរួមប្រណាំងទូកក្នុងអង្គការប្រណាំងទូកអន្តរជាតិ (IDBF) ប្រកបដោយជោគជ័យទទួលបានជ័យលាភីថ្នាក់លេខ ១ នៅទីក្រុងភីឡាដែលភៀ រដ្ឋផេនស៊ីលវេនៀ (USA) នៅឆ្នាំ ២០០១ និងបានអង្គការ IDBF ទទួលស្គាល់ជាសមាជិកពេញសិទ្ធិពីពេលនោះមក ។

២- ត្រូវបានអង្គការ នៃប្រជាជាតិគ្មានតំណាងដែលហៅកាត់ថា UNPO ទទួលឱ្យចូលជាសមាជិកពេញសិទ្ធិនៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០១ ។

នៅខែធ្នូ ឆ្នាំ ២០០០ នៅក្នុងដំណើរបេសកកម្មរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់ KKF គឺលោក សឺន ទួន ប្រធានប្រតិបត្តិ និងលោក ប្រាក់ សេរីវុឌ្ឍ អនុប្រធានទទួលបន្ទុកកិច្ចការអន្តរជាតិ នៅកម្ពុជា ក៏បានតែងតាំងលោក **ទៀ ឋេន** ចាងហ្វាងទស្សនាវដ្តី**តន្ត្រទេវី** ជាអនុប្រធាន KKF ទទួលបន្ទុកទ្វីបអាស៊ី ។ ប៉ុន្តែក្នុងរយៈពេលខ្លីមួយលោក **ទៀ ឋេន** ក៏បានលាលែងពីតំណែងនេះទៅ ។

លុះដល់ឆ្នាំ ២០០២ លោក **សឺន ទួន** ជាប្រធានប្រតិបត្តិ បានតែងតាំងតំណាង KKF ថ្មីមួយប្រចាំនៅកម្ពុជាដែលមានសមាសភាពដូចខាងក្រោម៖

១-លោក **តាំង សារៈ**	ជាប្រធានសាខា
២-លោក **ប៉ាប់ សាង**	(គ្រូម៉ាន់) ជាអនុប្រធាន
៣-លោក **អ៊ុយ សុភ័ក្ត្រ**	(ប៉ាប់ ង៉ុក ងាក) ជាលេខាធិការ
៤-លោក **គឹម សុងជា**	ហេរញ្ញិក ។

សមាសភាពនេះត្រូវបានកែប្រែសមាសភាពជាបន្តបន្ទាប់ ។

ចាប់ពីពេលនោះមកទើបសកម្មភាពរបស់ KKF នៅកម្ពុជាមានភាពសកម្មគួរឱ្យកត់សម្គាល់រហូតមកដល់សព្វថ្ងៃ ។

II.សកម្មភាពរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមនៅកម្ពុជា

នៅបុងខែធ្នូ ឆ្នាំ ២០០០ បានរៀបចំជាពិធីជួបជុំរវាងខ្មែរក្រោមនៅកម្ពុជា ដើម្បីស្តាប់បាឋកថារបស់លោក **សឺន ទួន** ស្តីពីគោលការណ៍ និងមាគ៌ារបស់ KKF ដែលរៀបចំឡើងនៅក្នុង**វត្តសាមគ្គីរង្សី** ហៅ**វត្តកម្ពុជាក្រោម** ក្នុងសង្កាត់ស្ទឹងមានជ័យ រាជធានីភ្នំពេញ ក្រោមការរៀបចំ និងចាត់ចែងរបស់ព្រះតេជព្រះគុណ **វិជ្ជារតនប្បញ្ញា យឿន លិន** ជាព្រះបៅអធិការ និងប្រធាន **សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម** ប្រចាំកម្ពុជា លោក **ទៀ ឋេន** អនុប្រធាន KKF ទទួលបន្ទុកទ្វីបអាស៊ី និង លោក **តាំង សារៈ** និពន្ធនាយក **សារព័ត៌មានឧត្តមគតិខ្មែរ** ។

នៅឆ្នាំ ២០០២ ដោយវត្តសាមគ្គីរង្សី ជាវត្តខ្មែរកម្ពុជាក្រោមតែ ១ គត់នៅកម្ពុជាដែលទើបតែកសាងឡើងនៅថ្ងៃទី ៦ ខែកក្កដា ឆ្នាំ ១៩៩៧ មានកង្វះខាត និងក្រីក្រយ៉ាងខ្លាំង ។ ក្នុងឆ្នាំនោះ ពុំមានអ្នកធ្វើជាអង្គកឋិនដង្ហែទៅប្រគេនព្រះសង្ឃ ដែលគង់ចាំព្រះវស្សានៅក្នុងវត្តនេះទេ ទើបភិក្ខុ **ប៉ាប់ ខ្ឃែន** ជាព្រះសង្ឃដែលមានវស្សាចាស់ជាងគេក្នុងវត្តនេះបន្ទាប់ពីព្រះបៅអធិការ បានស្នើលោក **តាំង សារៈ** ជាប្រធានសាខា សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីស្វែងរកអង្គកឋិនដង្ហែប្រគេនព្រះសង្ឃក្នុងវត្តនេះ ។ លោក **តាំង សារៈ** បានសម្រេចស្នើមកលោក **ប៉ាប់ តាន់តារា** អធិបតី KKF ដើម្បីសាងជាអង្គកឋិនមួយដង្ហែទៅប្រគេនព្រះសង្ឃក្នុងវត្តនេះ នៅក្នុងឆ្នាំនោះ ។ លោក **ប៉ាប់ តាន់តារា** ក៏បានទទួលយកសំណើនេះ ។

ទើបនៅថ្ងៃ ១៣ កើត ខែកត្តិក ឆ្នាំមមី បក្ខាស័ក ព.ស. ២៥៤៦ គ.ស. ២០០២ អង្គកឋិនរបស់សហព័ន្ធខ្មែរកម្ពុជាក្រោមមួយ បានដង្ហែទៅកាន់ព្រះរាជាណាចក្រកម្ពុជា (វត្តសាមគ្គីរង្សី) ជាលើកដំបូងដែលមានព្រះតេជព្រះគុណ **ឡឹម ខៃ** ដែលកាលនោះនៅជាគ្រហស្ថ និងលោក **សឺន ជាញ់ ឡឹប** (យួយ) ប្រធានសាខា KKF រដ្ឋញ៉ីវជេស៊ី (USA) ជាតំណាង KKF ទៅជាអធិបតី ក្រោមការរៀបចំ និងចាត់ចែងរបស់សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំកម្ពុជា ។

ឆ្នាំ ២០០២ លោក **តាំង សារៈ** ប្រធានសាខាសហព័ន្ធ នៅកម្ពុជាត្រូវបានលោក **សឺន ទួន** ប្រធានប្រតិបត្តិរបស់សហព័ន្ធ អញ្ជើញមកកាន់សហរដ្ឋអាមេរិកជាលើកដំបូង ដើម្បីទទួលការណែនាំស្តីពីរបៀបរបបវិធានការណ៍ និងផែនការអនុវត្តសកម្មភាពរបស់សាខាសហព័ន្ធនៅកម្ពុជា ។

ឆ្នាំ ២០០៤ សាខាសហព័ន្ធខ្មែរកម្ពុជាក្រោមនៅកម្ពុជា បានបញ្ជូនព្រះសង្ឃខ្មែរក្រោមចំនួន ២ ព្រះអង្គពីកម្ពុជា គឺ ព្រះតេជព្រះគុណ **យ៉ាន ថាត** ព្រះចៅអធិការ**វត្តអង្គតាមិញ** និង ព្រះតេជព្រះគុណ **កាន សុផាន ណាវិទ្ធ** ដែលកាលនោះ ជាព្រះចៅអធិការវត្ត**ព្រែកប្រា** រាជធានីភ្នំពេញ ចូលរួមសម័យប្រជុំនៃគណៈកម្មាធិការអចិន្ត្រៃយ៍ អ.ស.ប. ស្តីពីបញ្ហាជនជាតិដើម (UNPFII) នៅទីស្នាក់ការ អ.ស.ប. នាទីក្រុង ញ៉ីវយ៉ក (USA) ។

ឆ្នាំ ២០០៥ ថ្ងៃទី ៤ ខែសីហា នៅពេលដែលខ្មែរក្រោមបានភៀសខ្លួនពីដែនដីកម្ពុជាក្រោមមករស់នៅកម្ពុជា អាស្រ័យដោយការធ្វើទុក្ខបុកម្នេញពីសំណាក់រដ្ឋាភិបាលវៀតណាម បានធ្វើបាតុកម្មនៅខាងមុខទីស្នាក់ការខុតុមស្នងការ អ.ស.ប. ទទួលបន្ទុកជនភៀសខ្លួន (UNHCR) ប្រចាំកម្ពុជា សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម បានតាមដានយ៉ាងយកចិត្តទុកដាក់ និងស្វះស្វែងរកអំណោយឧបត្ថម្ភដល់ជនភៀសខ្លួនទាំងនោះទៀតផង ។

ក្រោយពេល (UNHCR) បានបដិសេធ មិនទទួលយកជនភៀសខ្លួនខ្មែរក្រោមទាំងនោះជាជនភៀសខ្លួន សាខា (KKF) នៅកម្ពុជា បានធ្វើសន្និសីទសារព័ត៌មានមួយនៅថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៥ ដោយបញ្ជាក់ថាបំណាត់ការរបស់ (UNHCR) ដែលបដិសេធមិនទទួលស្គាល់ជនភៀសខ្លួនខ្មែរក្រោមថាជាជនភៀសខ្លួននោះ គឺពុំមានភាពយុត្តិធម៌ព្រោះផ្ទុយពីស្មារតីនៃសេចក្តីសម្រេចរបស់អាជ្ញាធរបណ្តោះអាសន្ន អ.ស.ប. (UNHCR) នៅកម្ពុជាកាលពីឆ្នាំ ១៩៩២ ដែលពេលនោះ លោក **យ៉ូទ្រុស ប៊ុទ្រុស ហ្គាលី** អគ្គលេខាធិការ អ.ស.ប និងលោក **យ៉ាស្ស៊ូប៊្យឺ** អាកាស៊ី ប្រធាន UNTAC មិនអនុញ្ញាតឱ្យខ្មែរក្រោមនៅកម្ពុជាមានសិទ្ធិបោះឆ្នោតជ្រើសរើស សមាជិកសភាធម្មនុញ្ញដែលរៀបចំដោយ UNTAC នាឆ្នាំ ១៩៩៣ ឡើយដោយចាត់ទុកខ្មែរក្រោមថាមិនមែនជាជនជាតិខ្មែរ ។

ឆ្នាំ ២០០៦ សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម នៅកម្ពុជាបានប្រារព្ធធ្វើពិធីអបអរសាទរខួបគម្រប់ ៥ ឆ្នាំ ថ្ងៃ សហព័ន្ធខ្មែរកម្ពុជាក្រោមបានចូលជាសមាជិកអង្គការ UNPO នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៦ នៅក្នុងវត្តសាមគ្គីរង្សីនាររាជធានីភ្នំពេញ ។

ឆ្នាំ ២០០៧ លោកប្រធាន សាខា សហព័ន្ធកម្ពុជាក្រោម បានមកចូលរួមក្នុងសម័យប្រជុំ UNPFII ជាលើកទី ២ និងបានចូលរួមក្នុងក្បួនបាតុកម្មដែលរៀបចំឡើងដោយ សហព័ន្ធខ្មែរកម្ពុជាក្រោម នៅទីក្រុងវ៉ាស៊ីនតោន ដើម្បីតវ៉ាប្រឆាំងនឹងរដ្ឋាភិបាលវៀតណាមដែលបានចាប់ផ្សឹកព្រះសង្ឃខ្មែរក្រោមនៅខេត្តឃ្លាំងចំនួន ៩ អង្គ ដែលបានធ្វើបាតុកម្មទាមទារឱ្យរដ្ឋាភិបាលវៀតណាមគោរពសិទ្ធិសេរីជំនឿរបស់ពលរដ្ឋខ្មែរក្រោមនៅខាងមុខស្នងការដ្ឋានឧត្តមកុងស៊ុលខេត្តឃ្លាំង ។

នៅឆ្នាំ ២០០៧ នេះដែរ សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម នៅកម្ពុជា បានរៀបចំពិធីបដិសណ្ឋារកិច្ចប្រតិភូ នៃ គណៈកម្មាធិការអចិន្ត្រៃយ៍ អ.ស.ប. ទទួលបន្ទុកជនជាតិដើម UNPFII ដែលដឹកនាំដោយលោកស្រី **វិបគី** ប្រធាន UNPFII ដោយមានការចូលរួមពីថ្នាក់ដឹកនាំរបស់ សហព័ន្ធខ្មែរកម្ពុជាក្រោម មួយចំនួនរួមមាន លោក **ប្រាក់ សេរីវុឌ្ឍ** អនុប្រធាន លោកស្រី **សឺន ធីនិត** លោកស្រី **កៀង សុធី** ព្រះតេជព្រះគុណ **ធីធី ធម្មោ** លោក **ថាប់ ប៊ីរ៉ុង** ដែលកាលណោះនៅជាព្រះសង្ឃនៅឡើយ និង លោក **ត្រឹង យ៉ាប** ដោយបានរៀបចំជាពិធីសំណេះសំណាលយ៉ាងពិសេសមួយរវាងគណៈប្រតិភូ UNPFII និងព្រះសង្ឃព្រមទាំងបងប្អូនខ្មែរក្រោមនៅកម្ពុជា ។ ដែលពិធីនេះរៀបចំនៅក្នុងវត្តសាមគ្គីរង្សី ។

ក្នុងឆ្នាំដដែលនោះដែរ សាខា សហព័ន្ធខ្មែរកម្ពុជាក្រោម នៅកម្ពុជាបានជូនដំណើរអ្នកស្រី **សឺន ធីនិត** តំណាងឱ្យ KKF ប្តេជ្ញាបន្តជួយជនភៀសខ្លួនខ្មែរក្រោម ដែលត្រូវបានអាជ្ញាធរកម្ពុជារារាំងមិនឱ្យឆ្លងដែនចូលមកកម្ពុជានៅប្រករបៀងក្នុងឃុំព្រះបាទជាន់ជុំ ស្រុកគិរីវង្ស ខេត្តតាកែវ ដើម្បីជូនជាអំណោយ សម្រាប់បំណីអាហារ និងពិនិត្យស្ថានភាព ជាក់ស្តែងនៃជនភៀសខ្លួនទាំងនោះផង ។

នៅខែវិច្ឆិកា ឆ្នាំ ២០១០ សាខាសហព័ន្ធខ្មែរកម្ពុជាក្រោម បានសាំ

យកអំណោយរបស់ KKF ហើយចាត់បែងយកទៅចែកជូនជនរងគ្រោះដោយបាក់ស្ពាន កោះពេជ្រនៅក្នុងព្រះរាជពិធីបុណ្យ អកអំបុក អុំទូកសំពះព្រះខែ និងលយប្រទីប ជាប្រើនរយនាក់ដែលសម្រាក់ព្យាបាលនៅមន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យ មិត្តភាពខ្មែរសូវៀត និងមន្ទីរពេទ្យ ព្រះគន្ធមាលា រាជធានីភ្នំពេញ ។

បុងឆ្នាំ ២០១៤ លោក **សឺន ជុំជ្ជែន** អគ្គលេខាធិការសាខា សហព័ន្ធខ្មែរកម្ពុជាក្រោមនៅកម្ពុជា បានទៅចូលរួមសម័យប្រជុំដំណាប់ឆ្នាំ ២០១៥ នៅរដ្ឋវ៉ាស៊ីងតោន (USA) ។

ឆ្នាំ ២០១៦ សាខា KKF នៅកម្ពុជាដែលរួមមានលោក **តាំង សារៈ** លោក **សឺន យឿង** លោក **សឺន ជុំជ្ជែន** និងសមាជិកមួយបំនួនទៀត បានទៅចូលរួមវគ្គសិក្ខាសាលាស្តីពី SGJ នៅទីក្រុងបាងកក ប្រទេសថៃ ក្រោមអធិបតីភាពរបស់ **ប្ចហ្ស៊ែរ ក្ចហ្វ៊ើរ** ទីប្រឹក្សាជាន់ខ្ពស់ និងលោក **ម៉ៅ មុនី** អនុប្រធាន KKF ។

ថ្ងៃទី ០១ ខែមករា ឆ្នាំ២០១៧ តំណាង សាខា **ស.ខ.ក.** គឺ លោក **តាំង សារៈ** បានទៅចូលរួមសម័យប្រជុំប្រចាំឆ្នាំ ២០១៧ ដែលធ្វើឡើងនៅវត្តពុទ្ធិកខ្មែរនាទីក្រុងឡាស់វេហ្គាស់រដ្ឋ NEVADA (USA) ។

ឆ្នាំ ២០១៧ លោក **ថាប់ កេវសាវ៉ាង** ឧបការីប្រធាន KKF តំបន់ព្រះរាជាណាចក្រកម្ពុជា បានទៅចូលរួមសម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ អ.ស.ប. ស្តីពីជនជាតិដើម (UNPFII) នៅទីស្នាក់ការ អ.ស.ប. នាប្ចរីញ៉ីវយ៉ក (USA) ។

ខែមិថុនា ឆ្នាំ ២០១៨ ថ្នាក់ដឹកនាំសាខា សហព័ន្ធខ្មែរកម្ពុជាក្រោមនៅកម្ពុជារួមមាន លោក **តាំង សារៈ** លោក **សឺន យឿង** ព្រះតេជព្រះគុណ **ប៉ាង សូដា** និង លោក **គឹម រម្យមុន្នី** បានទៅចូលរួមសន្និសីទអន្តរជាតិស្តីពីខ្មែរកម្ពុជាក្រោម ដែលរៀបចំដោយ ស.ខ.ក. នៅវិមានព្រឹទ្ធសភាសាធារណរដ្ឋបារាំង ដោយមានការជ្រោមជ្រែងពីលោកព្រឹទ្ធសមាជិក **អង់ដ្រេកាតុលីន** សមាជិកព្រឹទ្ធសភាបារាំង ។

និងនៅថ្ងៃទី ៤ ខែមិថុនា ប្រតិភូនៃសាខា KKF ប្រចាំកម្ពុជាក៏បានទៅចូលរួមពិធីរំឭកខួប ៦៩ ឆ្នាំ កម្ពុជាក្រោមមនៅក្រោមអាណានិគមយួន នៅវត្តពោធិវង្ស នាទីក្រុងបារីស ដែលរៀបចំឡើងដោយ ស.ខ.ក. ប្រចាំទ្វីបអឺរុប ក្រោយអធិបតីភាព ព្រះតេជព្រះគុណ **ជិន ភេត** ។

ខែមករា ឆ្នាំ ២០១៨ លោក **សឺន យឿង** អនុប្រធានសាខា KKF នៅកម្ពុជា បានទៅចូលរួមសន្និបាតដំណាប់ឆ្នាំ ២០១៩ របស់ KKF នៅទីក្រុង San Jore រដ្ឋកាលីហ្វ័រញ៉ា (USA) ។

ឆ្នាំ ២០២០ លោក **សឺន យឿង** បានទៅចូលរួមសន្និបាតប្រចាំឆ្នាំ ២០២០ របស់ KKF នៅទីក្រុងឡាស់វេហ្គាស់រដ្ឋណេវ៉ាដា (USA) ។

ឆ្នាំ ២០២២ លោក **តាំង សារៈ** និង លោក **សឺន យឿង** បានទៅ



លោក តាំង សារៈ, លោក សឺន យឿង និង លោក ស៊ឺន ចែងចើន ចូលរួមមហាសន្និបាត លើកទី ១១ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ។

ចូលរួមមហាសន្និបាតលើកទី ១១ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មាធិការនាយក សម្រាប់អាណត្តិ ឆ្នាំ ២០២២ - ២០២៦ នៅទីក្រុងភីឡាដែលភៀ រដ្ឋផេនស៊ីលវេនញ៉ា (USA) ។

ឆ្នាំ ២០២៤ លោក **តាំង សារៈ** បានទៅចូលរួមពិធី រំឭកខួបគម្រប់ ១៣ ឆ្នាំ ទិវានារីអន្តរជាតិដែលរៀបចំដោយគណៈកម្មការស្ត្រី នៃ KKF នៅទីក្រុងភីឡាដែលភៀ និងចូលរួមពិធីអនុស្សាវរីយ៍គម្រប់ខួប ២០ ឆ្នាំថ្ងៃយុវជន KKF ធ្វើសកម្មភាព ក្នុងសម័យប្រជុំ UNPFII នៅទីក្រុងភីឡាដែលភៀ ដដែល។

ខែកក្កដា ឆ្នាំ ២០២៥ តំណាង សហព័ន្ធខ្មែរកម្ពុជាក្រោម នៅកម្ពុជាបំនួន ២ រូបគឺ លោក **តាំង សារៈ** ប្រធាន KKF ប្រចាំតំបន់កម្ពុជា និងលោក **សឺន ជុំជ្ជែន** អនុប្រធានសាខា KKF នៅកម្ពុជា បានទៅចូលរួមពិធីសម្ពោធការិយាល័យកណ្តាលនៃ KKF ស្ថិតនៅរដ្ឋធានីវ៉ាស៊ីនតោន ឌី.ស៊ី. ។



សកម្មភាពតំណាង ស.ខ.ក. នៅកម្ពុជាចុះចែកអំណោយដល់វីរយុទ្ធជនដែលរងរបួស និងមានជំងឺនៅពេលប្រយុទ្ធជាមួយទ័ពសៀម នៅឆ្នាំ ២០២៥ ដែលកំពុងសំរាកព្យាបាលនៅមន្ទីរពេទ្យ ។
រូបថត៖ តាំង សារ:

នៅឆ្នាំ ២០២៥ និងឆ្នាំ ២០២៦ KKF តំបន់ និងសាខា KKF នៅកម្ពុជា បានរៀបចំបាត់បែងនូវអំណោយរបស់ KKF ដោយការវិភាគទានពីសាខា KKF ជាច្រើនដូចជា សាខា នៃរដ្ឋ Fiorina Canada ទីក្រុង Philadelphia អឺរ៉ុប រដ្ឋ Washington វត្តបន្ទរដ្បិ ទីក្រុង TACOMA និងសប្បុរសជននៅក្រៅប្រទេសទៅបែកជូនដល់វីរកងទ័ព និងជនភៀសសឹកដោយសង្គ្រាមរវាងកម្ពុជា និងថៃក្នុងខេត្តសៀមរាប ខ្នុរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ចាម និងខេត្តពោធិ៍សាត់ ជាដើម ។

ក្រៅពីកិច្ចការដោយឡែករបស់ KKF តំបន់និងសាខា KKF ប្រចាំកម្ពុជាដូចរៀបរាប់សង្ខេបខាងលើនេះលោក **តាំង សារ:** ដែលជាប្រធានតំបន់ បានសហការជាមួយអង្គការ សមាគមខ្មែរកម្ពុជាក្រោម ជាពិសេសលេខាធិការដ្ឋាន អង្គការ សមាគមខ្មែរកម្ពុជាក្រោម នៅកម្ពុជា ធ្វើកិច្ចការជាច្រើនទៀត ដូចជាការចូលរួមប្រជុំរៀងរាល់កិច្ចប្រជុំរបស់លេខាធិការដ្ឋាន ការរៀបចំពិធីបុណ្យជាតិ អន្តរជាតិ ពិធីបុណ្យទំនៀមទម្លាប់ប្រពៃណី និងពិធីបុណ្យព្រះពុទ្ធសាសនាជាដើម ។

I. អំពីការលំបាករបស់ KKF តំបន់ប្រចាំកម្ពុជា:

ក—ដោយ KKF នៅកម្ពុជា មិនបានបុះបញ្ជី និងពុំមានទីស្នាក់ការនៅកម្ពុជា ដូច្នេះការធ្វើសកម្មភាពធ្វើងៗត្រូវធ្វើដោយការប្រុងប្រយ័ត្ន និងមានកម្រិត ។

ខ-ក្នុងតំណាក់កាលដំបូងៗ ជាពិសេសក្នុងពេលចាត់តាំងឱ្យមានបេសកជនរបស់ KKF ដំបូងៗ (រវាងឆ្នាំ ២០០២ - ២០០៤) KKF បានឆ្លងកាត់ព្យុះសង្ឃរាបក់បោកយ៉ាងខ្លាំងដោយមានអង្គការ សមាគមខ្មែរកម្ពុជាក្រោមខ្លះនៅកម្ពុជាបានធ្វើសកម្មភាពដើម្បីរារាំង និងបន្ទុកបង្អាក់សកម្មភាពរបស់បេសកជន KKF នៅកម្ពុជាយ៉ាងខ្លាំងក្លាធ្វើយ៉ាងណាកុំឱ្យមានសកម្មភាពរបស់ KKF នៅកម្ពុជាបានដូចជា:

១-សមាគមខ្មែរកម្ពុជាក្រោមខ្លះបានប្តឹងទៅក្រសួងមហាផ្ទៃចោទប្រកាន់ថា KKF បានសហការជាមួយអង្គការអន្តរជាតិ ដើម្បីប្រឆាំងទៅលើរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតចិន ដែលជាមិត្តដៃតែថៃបរបស់ព្រះរាជាណាចក្រកម្ពុជា ។

២- មានសមាគមខ្មែរក្រោមខ្លះទៀតមានបំណងប្តឹង KKF នៅកម្ពុជាថា បានយករូបសញ្ញា (គឺរូបរាហ៊ូបាប់ប័ន្ន) ដែលជារូបសញ្ញារបស់សមាគមគេមកធ្វើជារូបសញ្ញារបស់ KKF ។

៣- ពេលនោះសកម្មជនខ្មែរក្រោមនៅកម្ពុជា ដោយជឿទៅលើពួកក្រុមនោះផង និងដោយមានបំណងលើកកម្ពស់ នៃសមាគមរបស់ពួកគេរៀងៗខ្លួនឱ្យបានស្មើឬខ្ពស់ជាង KKF ផងមិនសូវមានអ្នកគាំទ្រ KKF ទេ ។

ថ្ងៃច័ន្ទ ៩ កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២០២៦
ជ. សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំតំបន់កម្ពុជា
តាំង សារ:
ប្រធានតំបន់ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំកម្ពុជា

សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំតំបន់ និង សាខានៅព្រះរាជាណាចក្រកម្ពុជា ប្រកាសសមាសភាពថ្មី សម្រាប់អាណត្តិឆ្នាំ ២០២៦ - ២០៣០

ដោយ **តាំង សារៈ**

ស.ខ.ក. តំបន់ និងសាខា **ស.ខ.ក.** ប្រចាំកម្ពុជា បានប្រារព្ធធ្វើពិធីប្រកាសសមាសភាពគណៈកម្មការថ្មី នៅពីថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០២៦ នៅវត្តសុវណ្ណមុនីសាគរ សំរោងអណ្តែក ក្រោមព្រះអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចសាក្យមុនីកត្តិបណ្ឌិត បណ្ឌិតទស្សនវិជ្ជា រ័ត្ន សារឿន ជាព្រះអគ្គាធិការរង នៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ខុទ្ទមប្រឹក្សាផ្ទាល់ សម្តេចព្រះមហាសុមេធាធិបតី សម្តេចព្រះសង្ឃនាយក គណៈមហានិកាយ នៃ ព្រះរាជាណាចក្រកម្ពុជា និងជាសម្តេចព្រះបៅអធិការវត្តសុវណ្ណមុនីសាគរ សំរោងអណ្តែត ។



ថ្នាក់ដឹកនាំ សាខា និងតំបន់ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំប្រទេសកម្ពុជា ថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០២៦ ។ រូបថត៖ តាំង សារៈ

ជាកិច្ចចាប់ផ្តើមកម្មវិធី លោក **តាំង សារៈ** បានអានរបាយការណ៍ថ្វាយប្រគេន និងជូនអង្គប្រជុំ ដែលមានខ្លឹមសារជាអាទិ៍ថា ដោយយោងតាមការកំណត់របស់អង្គមហាសន្និបាតលើកទី ១២ របស់ **ស.ខ.ក.** កាលពីថ្ងៃទី ១៨ និង ១៩ ខែកក្កដា ឆ្នាំ ២០២៦ ដែលបានកំណត់ឱ្យសហព័ន្ធតំបន់ និងសាខា សហព័ន្ធខ្មែរកម្ពុជាក្រោម តាមរដ្ឋ និងប្រទេសនីមួយៗ ទិតទំតាមលទ្ធភាព ដើម្បីរៀបចំរចនាសម្ព័ន្ធគណៈកម្មការសហព័ន្ធតំបន់ និងសាខាសហព័ន្ធប្រចាំរដ្ឋ និងប្រទេសនានា ឱ្យបានបញ្ចប់សព្វគ្រប់យ៉ាងយឺតណាស់ក្នុងត្រីមាសទីមួយ ក្រោយមហាសន្និបាត ។

ទើបនៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០២៦ រូបលោកក្នុងនាមជាប្រធានសហព័ន្ធតំបន់នៅកម្ពុជា បានដាក់ពាក្យស្នើទៅ **ស.ខ.ក.** តាមការឯកភាពរបស់គណៈកម្មការសហព័ន្ធនៅកម្ពុជា ស្នើសុំសេចក្តីសម្រេចរបស់គណៈកម្មការនាយកថ្មី តែងតាំងសមាសភាពគណៈកម្មការ **ស.ខ.ក.** ថ្មីប្រចាំកម្ពុជាសម្រាប់អាណត្តិឆ្នាំ ២០២៦ - ២០៣០ ដែលមានបំនួន ១៣ រូបក្នុងនោះ សមាសភាព តំបន់មាន ៥ រូប និងសមាសភាពសាខាបំនួន ៨ រូប ហើយត្រូវបានគណៈកម្មការនាយកថ្មីឯកភាពទាំងស្រុង ។

បន្ទាប់លោក **ថាប់ កេវ សាវ៉ាង** ឧបការីប្រធានសហព័ន្ធ តំបន់កម្ពុជា បានអានសេចក្តីសម្រេចតែងតាំងរបស់ **ស.ខ.ក.** ដែលបុះហត្ថលេខាដោយលោក **គឹម សិវ៉ា** ប្រធានសភាតំណាង នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ជាជំនួសមុខឱ្យ សហព័ន្ធខ្មែរកម្ពុជាក្រោម បានបេញលិខិតតែងតាំងបុះថ្ងៃសុក្រ ៨ កើត ខែស្រាពណ៍ ឆ្នាំមមី អដ្ឋស័ក ព. ស. ២៥៧០ ត្រូវនឹង ថ្ងៃទី ២១ ខែសីហា ឆ្នាំ ២០២៦ ដែលមានសមាសភាព ដូចខាងក្រោមនេះ ។

សមាសភាព តំបន់បំនួន ៥ រូបគឺ៖

១- លោក **តាំង សារៈ**	ប្រធាន
២-ព្រះគ្រូធម្មវិរិយាចារ្យ **ហាញ់ បំរុង** (ធម្មបាលោ)	ជាទីប្រឹក្សា
៣-លោកបណ្ឌិត **សឺន ជុំជ្ជិន**	ជាអនុប្រធាន
៤-លោក ថាប់ កេវសាវ៉ាង	ជាលេខាធិការ
៥-លោក **គឹម រម្យមុនី**	ជាឧបការីប្រធានតំបន់ទទួលបន្ទុកមើលការ ខេត្តកោះកុង

សមាសភាពសាខាមាន ៨ រូបគឺ៖

១-លោក **សឺន យឿង**	ជាប្រធាន
២-លោក **ញឹម ឫទ្ធី**	អនុប្រធាន
៣-លោក **គឹម ស៊ីសំណា**	លេខាធិការ
៤-លោក **ថាប់ សុវណ្ណមុនី**	ហេរញ្ញិក



លោក តាំង សារៈ អានរបាយការណ៍ ។

៥-លោក **សឺន ជុំសុធន**	ប្រធានផ្នែកព័ត៌មាន
៦-អ្នកស្រី **តាំង កែវពិសី**	ប្រធានផ្នែកយុវជន
៧-លោក **ស៊ឺន បែងបើន**	អនុប្រធានផ្នែកព័ត៌មាន
៨-អ្នកស្រី **ផន សុខា**	អនុប្រធានផ្នែកយុវជន

ក្រោយពីលោក **ឋាប់ កេវសារ៉ាង** អានសេចក្តីសម្រេចតែងតាំងនោះហើយលោក **គឹម ស៊ីសំណា** លេខាធិការ **ស.ខ.ក.** ប្រចាំកម្ពុជាដែលជាពិធីករនៃអង្គពិធី បានអារាធនាគិមគ្គសម្តេចព្រះសក្យមុនី **វ័ន្ត សារឿន** សម្តេចព្រះបៀអធិការវត្តសំរោងអំណែត ដែលជាព្រះអធិបតី នៃអង្គពិធីប្រទានលិខិតតែងតាំង ដល់សមាសភាពគណៈកម្មការ **ស.ខ.ក.** តំបន់ និងសាខា **ស.ខ.ក.** ទាំង ១៣ រូបតាមលំដាប់លេខរៀងខាងលើនេះ និងបានបិតរូបទុកជាអនុស្សាវរីយ៍ទៀតផង ។

កម្មវិធីបុងក្រោយបង្អស់ គឺជាព្រះបេរដីកាដ៏ខ្ពង់ខ្ពស់របស់សម្តេចព្រះអធិបតីសំណេះសំណាលដាស់តឿន និងប្រទានឱវាទដល់គណៈកម្មការថ្មីនៃ **ស.ខ.ក.** ប្រចាំតំបន់ និងសាខា **ស.ខ.ក.** ប្រចាំកម្ពុជា ដោយសម្តេចមានព្រះឱវាទជាអាទិ៍ថា សូមឱ្យគណៈកម្មការទាំងអស់ធ្វើសកម្មភាព ដើម្បីបម្រើប្រជាពលរដ្ឋខ្មែរជាពិសេសខ្មែរក្រោមទៅតាមគោលការណ៍ ទិសដៅ និងសំណូមពររបស់ **ស.ខ.ក.** និងប្រជាពលរដ្ឋខ្មែរក្រោម ឱ្យស្របទៅតាមទំនុកចិត្តរបស់សហព័ន្ធ និងក្តីសង្ឃឹមរបស់ពលរដ្ឋខ្មែរក្រោមទាំងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងនៅក្នុងមាតុភូមិកម្ពុជាក្រោមរបស់យើង ។

ព្រះអង្គទ្រង់រំឭកទៀតថា រាល់សកម្មភាពរបស់ **ស.ខ.ក.** នៅកម្ពុជាក៏ត្រូវឱ្យស្របទៅតាមគោលការណ៍ច្បាប់ នៃព្រះរាជាណាចក្រកម្ពុជាផងដែរ និងបៀសវាងការជម្រុញឱ្យខ្មែរក្រោមនៅក្នុងស្រុកធ្វើអ្វីៗឱ្យប្រាស់ចាកពីច្បាប់ទម្លាប់របស់ប្រទេសគេ ដែលធ្វើឱ្យពួកគាត់មានគ្រោះថ្នាក់ដោយប្រការផ្សេងៗ ។

ពិធីនេះបានបញ្ចប់ដោយ សម្តេចព្រះសាក្យមុនី និងព្រះគ្រូវិរិយាចារ្យស្វាធ្យាយសំវិជ្ជនិយគាថា បង្សុកូល ដើម្បីឧទ្ទិសកុសលដល់ព្រះវិញ្ញាណក្ខន្ធ និងវិញ្ញាណក្ខន្ធវីរសមណៈវីរបុរស និងបុព្វការីជន ។



លេខាធិការដ្ឋានអង្គការ សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា ធ្វើសិក្ខាសាលាស្តីពី «សិទ្ធិស្វ័យសម្រេចរបស់ជនជាតិដើមខ្មែរក្រោម»



ទិដ្ឋភាពអង្គសិក្ខាសាលាស្តីពី «សិទ្ធិស្វ័យសម្រេចរបស់ជនជាតិដើមខ្មែរក្រោម» រៀបចំដោយ លេខាធិការដ្ឋាន អង្គការ សមាគម ខ.ក.ក. ។

ដោយ **តាំង សារៈ**

លេខាធិការដ្ឋាន អង្គការសមាគមខ្មែរកម្ពុជាក្រោម ប្រចាំកម្ពុជា បានរៀបចំប្រារព្ធជាសិក្ខាសាលាមួយក្រោមប្រធានបទ «សិទ្ធិស្វ័យសម្រេចរបស់ជនជាតិដើមខ្មែរខ្មែរក្រោម» កាលពីថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០២៦ ដោយមានការចូលរួមពីព្រះសង្ឃ និងខ្មែរក្រោមដែលក្នុងនោះរួមមានសមាជិក សមាជិកា នៃអង្គការ សមាគមខ្មែរកម្ពុជាក្រោមនានា បំណុះឱ្យលេខាធិការដ្ឋាន និងនិស្សិតខ្មែរក្រោម សរុបចំនួនប្រមាណជាជាង ៥០ អង្គនិងរូប ។

សិក្ខាសាលាបានប្រព្រឹត្តឡើងក្នុងគោលបំណងស្វែងយល់ពី **សិទ្ធិស្វ័យសម្រេចរបស់ជនជាតិដើមខ្មែរក្រោម** ដែលកំពុងតែរស់នៅក្នុងទឹកដីកម្ពុជាក្រោម ក្រោមការគ្រប់គ្រង និងត្រួតត្រាដោយរបបវៀតណាម ។

លោក **តាំង សារៈ** ប្រធាន **ស.ខ.ក.** ប្រចាំតំបន់កម្ពុជា និងជាអនុប្រធានក្រុមប្រឹក្សាភិបាល នៃសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ (KKKHRDA) ដែលជាវាគ្មិន ១ រូបនៃអង្គសិក្ខាសាលា បានលើកឡើងថា អាស្រ័យការខកខានរបស់វៀតណាមពីជំនាន់មួយទៅជំនាន់មួយពុំបានអនុវត្តទាល់តែសោះនូវកិច្ចព្រមព្រៀងស្តីពីសិទ្ធិជនជាតិភាគតិចមិនមែនជាយួន ដែលកំពុងរស់នៅក្នុងប្រទេសវៀតណាមបច្ចុប្បន្ន ដែលបានចុះហត្ថលេខាដោយលោក **ប៉ូល កុស្ត ផ្លូវរ៉េតិ** រដ្ឋមន្ត្រីនាយសមុទ្ររបស់អាណានិគមបារាំងជាមួយ និងលោក **អង់សាំង អូរីយ៉ូ** ប្រធានាធិបតី នៃសាធារណរដ្ឋបារាំង និង **បារី ជាយ** ជាអធិរាជអាណ្ណាម ដែលកិច្ចព្រមព្រៀងនោះ តម្រូវឱ្យមានការផ្តល់នូវលក្ខន្តិក:ពិសេសបំពោះជនជាតិភាគតិច ដែលមិនមែនជាយួន ក្នុងនោះ និយាយរួមទាំងខ្មែរក្រោមផងដែរ ។

លោក **តាំង សារៈ** បានលើកឡើងទៀតថា អាស្រ័យដោយរដ្ឋាភិបាលវៀតណាម មិនបានផ្តល់លក្ខន្តិក:ណាមួយសម្រាប់ជនជាតិភាគតិចដែលរស់នៅក្នុងទឹកដីវៀតណាម ពិសេសគឺខ្មែរក្រោមនោះ ហើយទើបនៅឆ្នាំ ១៩៦៩ អ្នកតំណាងរាស្ត្រខ្មែរក្រោមចំនួន ៦ រូបរួមមានលោក **កៀង ស្វក** លោក **តាំង បា ស្វីង** លោក **យ៉ញ កឿង** លោក **បៅ ស្វកកាន** លោក **ថាប់ ង៉ែន** និងលោក **យ៉ញ ណើ** បានសរសេរលក្ខន្តិក:សម្រាប់ខ្មែរក្រោម ដែលរស់នៅក្នុងប្រទេសវៀតណាម ស្នើទៅរដ្ឋសភាវៀតណាមឱ្យអនុម័តទៅលើលក្ខន្តិក:នោះ តែត្រូវរដ្ឋសភាវៀតណាមខាងត្បូងបដិសេធដោយចំនួនសមាជិករដ្ឋសភា ដែលមានវត្តមានក្នុងអង្គប្រជុំចំនួន ៨៧ នាក់គឺមានដល់ទៅ ៥២ សំឡេងបដិសេធទល់និង ២៩ សំឡេងគាំទ្រ អនុប្បវាទ ៤ សំឡេង និង ១ សំឡេងយកជាការមិនបាន ។

ដោយពុំមានលក្ខន្តិក: ចែងពីសិទ្ធិរស់នៅរបស់ខ្មែរក្រោម នៅក្នុងប្រទេសវៀតណាមប្លាស់លាស់នេះហើយ ដែលធ្វើឱ្យជនជាតិដើមខ្មែរក្រោមត្រូវទទួលរងនូវការរំលោភសិទ្ធិជាបន្តបន្ទាប់ ពីសំណាក់រដ្ឋការវៀតណាមរហូតដល់បច្ចុប្បន្ន ។ កត្តានេះហើយដែលតម្រូវឱ្យយើងជាខ្មែរក្រោមត្រូវធ្វើជាសិក្ខាសាលាដើម្បីស្វែងយល់ពី «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ក្រោមប្រធានបទ «របស់ជនជាតិ



លោក តាំង សារ: ប្រធានតំបន់ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំប្រទេសកម្ពុជា ថ្លែងនៅក្នុងអង្គសិក្ខាសាលា ។

ដើមខ្មែរក្រោម» នាពេលនេះ ។

លោកបណ្ឌិត **សឺន ជុំជួន** អនុប្រធាន សហព័ន្ធខ្មែរកម្ពុជាក្រោម តំបន់កម្ពុជា និងជាអនុប្រធានសមាគមខ្មែរកម្ពុជាក្រោម ដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍ ក៏ជាវាគ្មិន ១ រូបទៀតក្នុងអង្គសិក្ខាសាលាបានធ្វើបទបង្ហាញអំពីច្បាប់ សន្ធិសញ្ញា កិច្ចព្រមព្រៀងនិងសេចក្តីប្រកាសផ្សេងៗរបស់អង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា នៅលើពិភពលោក ដូចជាសេចក្តីប្រកាសជាសកលរបស់ អ.ស.ប. ស្តីពីសិទ្ធិមនុស្ស និងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនជាតិដើម ជូនអង្គសិក្ខាសាលាដើម្បីធ្វើការសិក្សាស្វែងយល់ទៅតាមឯកសារទាំងនោះ សម្រាប់ជាមូលដ្ឋានក្នុងការតស៊ូទាមទារ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដល់ខ្មែរកម្ពុជាក្រោមដែលកំពុងរស់នៅក្នុងទឹកដីកម្ពុជាក្រោម ក្រោមការគ្រប់គ្រង និងត្រួតត្រារបស់រដ្ឋាភិបាលវៀតណាម ។

នៅក្នុងអង្គសិក្ខាសាលានេះដែរ អ្នកចូលរួមបានលើកជាសំណួរមួយចំនួនសួរទៅវាគ្មិនទាំង ២ ដោយសំណួរទី ១ លោកស្រី **ថាប់ ដីវ៉ា** សួរថា តើរាល់ច្បាប់ និងសេចក្តីប្រកាសផ្សេងៗពាក់ព័ន្ធដល់ការទាមទារសិទ្ធិស្វ័យសម្រេចរបស់ខ្មែរក្រោម តើត្រូវអនុវត្តពីណាទៅមុខ? ។

លោក **សឺន ជុំជួន** បានឆ្លើយថា ជាដំបូងយើងត្រូវធ្វើឱ្យអន្តរជាតិបានស្គាល់ថាខ្មែរក្រោមជាអនរណា មានប្រភពមកពីណា កំពុងរស់នៅទីណា មានអរិយធម៌យ៉ាងដូចម្តេច និងមានភស្តុតាងអ្វីខ្លះជាសម្គាល់?

សំណួរទី ២ កញ្ញា **ហៅ ជាតី** ជានិស្សិតឆ្នាំទី ៤ (វគ្គបញ្ចប់) បានសួរថា តាមឯកសាររបស់អាណានិគមបារាំងបានបញ្ជាក់ថាក្នុង ១៩៤៨ ខ្មែរក្រោមនៅដែនដីកម្ពុជាក្រោមមានចំនួន ៤៥០.០០០ នាក់ និងនៅឆ្នាំ ១៩៨៩ តាមលិខិតរបស់តំណាងរាស្ត្រខ្មែរក្រោមទាំង ៦ រូបធ្វើប្រគេនគឹងដូនព្រះសង្ឃនិងជនរួមជាតិខ្មែរក្រោមបញ្ជាក់ថា ខ្មែរក្រោមមានជាង ២ លាននាក់ ហេតុដូចម្តេចតួលេខខ្មែរក្រោមរបស់រដ្ឋាភិបាលវៀតណាមបច្ចុប្បន្នថាខ្មែរក្រោមមានតែជាង ១ លាននាក់ទៅវិញ? ។

លោក **តាំង សារ:** ឆ្លើយថា មានកត្តា ២ យ៉ាងគឺ:

១ - ដោយរដ្ឋាភិបាលវៀតណាមមានបំណងបំបាត់តួលេខនៃចំនួនខ្មែរក្រោមពិតប្រាកដ ដើម្បីកុំឱ្យអន្តរជាតិមើលឃើញថា ខ្មែរក្រោមមានចំនួនច្រើន នាំឱ្យមានសម្ពាធពីអន្តរជាតិឱ្យវៀតណាមទទួលស្គាល់ខ្មែរក្រោមជាជនជាតិដើម ។

២ - ឬអាចថាវៀតណាមទទួលស្គាល់តែខ្មែរក្រោមណា ដែលមានតាមត្រកូលចំនួន ៧ ត្រកូលដែលស្តេចយ៉ាឡុងរបស់យួនបង្ខំឱ្យខ្មែរក្រោមទទួលយកតាំងពីឆ្នាំ ១៨១៦ គឺត្រកូល **សឺន ថាប់ យ៉ញ គីម កៀង ហៅ** និង **តាង** តែប៉ុណ្ណោះ ឯត្រកូលដទៃទៀតត្រូវគេបដិសេធថា មិនមែនជាខ្មែរក្រោម ទើបចំនួនខ្មែរក្រោមត្រូវបិយបុះយ៉ាងដូច្នេះ។

អង្គសិក្ខាសាលាត្រូវបានបញ្ចប់ទៅវិញនៅវេលាម៉ោង ៥ និង ១០ នាទី ក្នុងថ្ងៃនោះ ។



បណ្ឌិត សឺន ជុំជួន អនុប្រធាន សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំតំបន់ប្រទេសកម្ពុជា និងជាអនុប្រធាន KKKHRDA ថ្លែងនៅក្នុងអង្គសិក្ខាសាលា ។

សេចក្តីថ្លែងការណ៍
៧៧ ឆ្នាំនៅក្រោមរបបអាណានិគមយួន
តស៊ូមតិដើម្បីសិទ្ធិ នៃប្រជាជាតិខ្មែរក្រោម
(៤ មិថុនា ១៩៤៩ - ៤ មិថុនា ២០២៦)

ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ២០២៦ ជាគម្រប់ ៧៧ ឆ្នាំ ដែលចារឹងបានផ្នែរដែនដីកម្ពុជាក្រោម ឲ្យទៅវៀតណាមបន្តធ្វើអាណានិគមលើពលរដ្ឋខ្មែរក្រោម ។ ជារៀងរាល់ឆ្នាំឲ្យតែដល់ថ្ងៃទី ៤ ខែមិថុនា ពលរដ្ឋខ្មែរក្រោម វត្តអារាម អង្គការ សមាគម និងសាខា សហព័ន្ធខ្មែរកម្ពុជាក្រោម នៅជុំវិញពិភពលោក តែងតែប្រារព្ធពិធីរំឭកដល់ថ្ងៃប្រវត្តិសាស្ត្រមួយនេះឥតដែលខាន ។ នៅក្នុងពិធីខួប ៧៧ ឆ្នាំនេះដែរ សហព័ន្ធខ្មែរកម្ពុជាក្រោម ដែលមានមូលដ្ឋាននៅរដ្ឋធានី Washington ឌីស៊ី សហរដ្ឋអាមេរិក បានចេញសេចក្តីថ្លែងការណ៍មួយ (ពីរភាសាគឺ ខ្មែរ និងអង់គ្លេស) រំឭកពីការធ្វើទុក្ខបុកម្នេញលើពលរដ្ឋខ្មែរក្រោម រយៈពេល ៧៧ ឆ្នាំ នៅក្រោមនឹមអាណានិគមយួន ក្នុងនោះ ការចាប់ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោម ដាក់ពន្ធនាគារ ដោយសារការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួន នាប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ស.ខ.ក. ក៏បញ្ជាក់ថា ខួប ៧៧ ឆ្នាំ នៃព្រឹត្តិការណ៍ថ្ងៃទី ៤ ខែមិថុនា គឺជាឱកាសសម្រាប់រំឭកឡើងវិញនូវប្រវត្តិសាស្ត្រ អត្តសញ្ញាណជាតិ និងការតស៊ូរបស់ប្រជាជាតិខ្មែរក្រោម ក្នុងការការពារសិទ្ធិវប្បធម៌ ភាសា សាសនា និងសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។ សេចក្តីថ្លែងការណ៍នេះ ត្រូវបានតំណាងសាខា និងតំបន់ នៃ ស.ខ.ក. នៅជុំវិញពិភពលោក យកទៅអាននៅក្នុងអង្គប្រជុំនៃពិធីរំឭកខួបព្រឹត្តិការណ៍មួយនេះគ្រប់ទីកន្លែង មានដូចជា សហរដ្ឋអាមេរិក កាណាដា អូស្ត្រាលី អឺរ៉ុប ក្បាលខាងត្បូង និងព្រះរាជាណាចក្រកម្ពុជា ។ ក្រៅពីនេះ ក៏បានផលិតជាវីដេអូ ហើយផ្សាយតាមបណ្តាញ Facebook «ទូរទស្សន៍កម្ពុជាក្រោម» (Kampuchea Krom TV) និងកម្មវិធីផ្សាយ «សំឡេងកម្ពុជាក្រោម» (Voice of Kampuchea Krom - VOKK) មានអ្នកទស្សនាយ៉ាងច្រើន ។

សេចក្តីថ្លែងការណ៍នេះ មានអត្ថន័យយ៉ាងណា? ព្រឹត្តិបត្រ កម្ពុជាក្រោម លេខនេះ សូមលើកយកមកចុះផ្សាយខ្លឹមសារជាភាសាខ្មែរទាំងស្រុងដូចតទៅ៖



ថ្ងៃនេះ យើងមកជួបជុំគ្នាដើម្បីរំឭកខួប ៧៧ ឆ្នាំ ដែលដែនដីកម្ពុជាក្រោមរបស់យើង ត្រូវអាណានិគមបារាំងផ្នែរឲ្យទៅរបបយួនបន្តធ្វើអាណានិគមលើប្រជាពលរដ្ឋខ្មែរក្រោមម្ចាស់ស្រុក នៅថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ ។ ការផ្នែរអំណាចដោយរបបអាណានិគមបាស់ផ្លាស់ប្តូរប្តីបន្តវេនគ្នាត្រួតត្រាគោះមិនបានជួនដំណឹង ឬមានការយល់ព្រមណាមួយពីជនជាតិដើមខ្មែរក្រោមជាម្ចាស់ទឹកដី នៃដែនដីកម្ពុជាក្រោមឡើយ ។

អស់រយៈពេល ៧៧ ឆ្នាំកន្លងមកនេះ ពលរដ្ឋខ្មែរក្រោមត្រូវប្រឈមនឹងការធ្វើទុក្ខបុកម្នេញឥតស្រាកស្រាន្តពីរបបអាណានិគមប្តី ដែលកើតបេញពីសេចក្តីសម្រេចដ៏អយុត្តិធម៌មួយនេះ ។ ការរស់នៅក្រោមរបបអាណានិគមទម្រង់ប្តី បានធ្វើឲ្យយើងមានការឈឺចាប់ ព្រោះការបាត់បង់នូវការគ្រប់គ្រងនៅលើទឹកដីកេរដំនែរបស់ខ្លួន និង

ត្រូវអាជ្ញាធរថ្មីធ្វើទុក្ខបុកម្នេញជាបន្តបន្ទាប់ ។ ភាពឈឺចាប់បានធ្វើឲ្យពលរដ្ឋរបស់យើងក្រោកឈរជាបន្តបន្ទាប់ ដើម្បីសិទ្ធិជាមូលដ្ឋានរបស់ខ្លួន ក្នុងនោះ មានសិទ្ធិរក្សាឆ្លូវវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ភាសា និងអក្សរសាស្ត្រខ្មែរ ព្រមទាំងសិទ្ធិស៊ីវិល និងនយោបាយជាពិសេសគឺ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ។

ខ្មែរក្រោមមិនមែនជា «ជនជាតិភាគតិច» ដែលរស់នៅលើដីបរទេស ដូចអ្វីដែលរបបយួនឃោសនានោះទេ ។ យើងជា «ជនជាតិដើម» នៃដែនដីកម្ពុជាក្រោមដែលមានប្រវត្តិសាស្ត្រ និងវប្បធម៌ដ៏ចំណាស់នៅលើទឹកដីរបស់ខ្លួន ជាយូរលង់ណាស់មកហើយ គឺមានវត្តមាន មុនការបង្កើតព្រំដែននយោបាយ និងការបង្កើតរដ្ឋទំនើបទាំងឡាយនាពេលបច្ចុប្បន្នោះទៅទៀត ។

សេចក្តីប្រកាសរបស់ អ.ស.ប. ស្តីពីសិទ្ធិជនជាតិដើម (UNDRIP) និងវេទិកាអចិន្ត្រៃយ៍របស់ អ.ស.ប. ស្តីពីបញ្ហាជនជាតិដើម (UNPFII) បានទទួលស្គាល់សិទ្ធិរបស់ខ្មែរក្រោមក្នុងការកំណត់នូវអត្តសញ្ញាណ និង «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ជាជនជាតិដើមនៅលើដែនដីរបស់ខ្លួន ។

នៅពេលដែលយើងកំពុងរំឭកនូវព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ ពលរដ្ឋរបស់យើងនៅកម្ពុជាក្រោម នៅតែបន្តត្រូវប្រឈមមុខនឹងការរំលោភបំពានជិះជាន់យ៉ាងទម្ងន់ពីរបបអាណានិគមយួន ។ បច្ចុប្បន្ននេះ ព្រះសង្ឃ និងពលរដ្ឋដែលជាអ្នកការពារវប្បធម៌ និងក្រោកឈរអនុវត្តនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនជាជនជាតិដើម ត្រូវអាណានិគមយួនចាប់យកទៅឃុំឃាំង និងផ្តន្ទាទោសទាំងអយុត្តិធម៌ ។ ស.ខ.ក. បានធ្វើសកម្មភាពតស៊ូមតិនៅលើឆាកអន្តរជាតិយ៉ាងសស្រាក់សស្រាំ ដើម្បីទាមទារឱ្យមានការគោរពសិទ្ធិខ្មែរក្រោមជាជនជាតិដើម និងឱ្យរបបយួនដោះលែងព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមឱ្យមានសេរីភាពវិញដោយឥតលក្ខខណ្ឌ ។

នៅក្នុងឱកាសនេះដែរ យើងទាំងអស់គ្នាសូមរំឭកនឹកគុណគោរពបំពេះវីរភាព នៃព្រះតេជព្រះគុណ **ជាប់ បន្ទ តារា** ព្រះតេជព្រះគុណ **យឿង ទាយ** ព្រះតេជព្រះគុណ **គឹម សំរិទ្ធ** ជាព្រះសង្ឃគំរូ ដែលត្រូវរបបយួនធ្វើឃ្លែក និងចាប់ព្រះកាយក្នុងបុព្វហេតុតស៊ូមតិដោយសន្តិវិធីសម្រាប់សិទ្ធិជនជាតិដើម សិទ្ធិសាសនា និងវប្បធម៌របស់យើង ។ យើងក៏សូមរំឭកដល់ លោក **ជាប់ ង៉ា** និងលោក **ជាប់ ស្វឹង ជុង** ដែលត្រូវឃុំខ្លួនដោយសារអនុវត្តសិទ្ធិសាសនា និងបង្ហាញនូវអត្តសញ្ញាណជាតិរបស់ខ្លួន ។

យើងសូមកោតសរសើរដល់ លោក **គោ ហ្វាង បឿង** លោក **ជាប់ ឿង** និង លោក **យ័ញ មិញ ក្វាង** អ្នកដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារជាយូរឆ្នាំ ពីបទចែកចាយសេចក្តីប្រកាសរបស់ **អ.ស.ប.** ស្តីពីសិទ្ធិជនជាតិដើម (UNDRIP) និងការអនុវត្តសិទ្ធិជាជនជាតិដើម ។ យើងមានមោទនភាពចំពោះអ្នកស្រី **រង្គ វ៉ារី** ជាស្ត្រីខ្មែរក្រោមម្នាក់ដែលបានតស៊ូមតិសម្រាប់សិទ្ធិនារី ហើយត្រូវបានចាប់ខ្លួនដោយសារបៀបចំទិវានារីអន្តរជាតិ ដែលជាព្រឹត្តិការណ៍មួយដែលស្ត្រីជនជាតិយួនរបស់គេអាចប្រារព្ធបានដោយសេរី ។

យើងសូមកោតសរសើរដល់លោក **ជាប់ ប៊ិត្រា** និងគ្រួសារជាសកម្មជនសិទ្ធិមនុស្សខ្មែរក្រោម ដែលបានប្រើប្រាស់បណ្តាញសង្គមដ៏ក្លាហាន ដើម្បីផ្សព្វផ្សាយព័ត៌មានពិត និងការផ្សាយផ្ទាល់អំពីការរឹបអូសយកដីធ្លី អំពើអយុត្តិធម៌ ការគំរាមកំហែង ការបំភិតបំភ័យ និងការឃុំខ្លួនដោយបំពាន ដែលពលរដ្ឋខ្មែរក្រោមកំពុងតែត្រូវប្រឈមមុខនៅដែនដីកម្ពុជាក្រោម ។

តើការអានឯកសារដែលចេញផ្សាយដោយ **អ.ស.ប.** ជាបទឧក្រិដ្ឋមែនឬ? តើការបង្រៀនកូនចៅរបស់យើងឱ្យចេះភាសាខ្មែរ ឬការប្រតិបត្តិតាមមាគ៌ាព្រះពុទ្ធសាសនាបេរាទ ដូចបុព្វបុរសរបស់យើង គឺជាការគំរាមកំហែងដល់សន្តិសុខជាតិរបស់យួនមែនទេ? តើការប្រារព្ធទិវានារីអន្តរជាតិ ឬទិវាសិទ្ធិមនុស្សអន្តរជាតិ គួរត្រូវបានចាត់ទុកថាជាការរំខានដល់សង្គមមែនឬ? ហើយតើវាជាយុត្តិធម៌ដែរឬទេ ពេលដែលរបបយួនចោទប្រកាន់សកម្មជនខ្មែរក្រោមថា «កេងបំណេញលើសេរីភាព និងលទ្ធិប្រជាធិបតេយ្យ» ហើយផ្តន្ទាទោសពួកគាត់ ដោយសារការចែករំលែកការពិតតាមបណ្តាញសង្គមនោះ?

បម្លើយគឺ «មិនមែនទេ» យ៉ាងច្បាស់លាស់ ។ សកម្មភាពទាំងនេះមិនមែនជាបទល្មើសឡើយ ផ្ទុយទៅវិញ វាជាសិទ្ធិជាមូលដ្ឋានរបស់មនុស្សដែលត្រូវបានការពារដោយច្បាប់អន្តរជាតិ ។ សហគមន៍

អន្តរជាតិត្រូវបានអំពាវនាវឱ្យបើកលទ្ធភាពសិទ្ធិសេរីភាពដល់ព្រះសង្ឃ និងសកម្មជនខ្មែរក្រោមទាំងអស់ដែលត្រូវបានឃុំខ្លួនដោយអយុត្តិធម៌ ។

របបអាណានិគមថ្មី ដែលបន្តត្រួតត្រាលើខ្មែរក្រោម ចាប់តាំងពីថ្ងៃទី ៤ ខែមិថុនា ឆ្នាំ ១៩៤៩ មកនេះ មានគោលបំណងលុបបំបាត់នូវអត្តសញ្ញាណរបស់យើង ។ ទេពកម្មរបស់យើងត្រូវបានប្លន់ឈ្មោះ ភាសារបស់យើងត្រូវបានរឹតត្បិត ហើយស្ថាប័នសាសនារបស់យើងត្រូវបានដាក់ក្រោមការគ្រប់គ្រង ។ គោលបំណងគឺធ្វើឱ្យយើងក្លាយជាប្រជាជនដែលគ្មានអតីតកាល ។

សព្វថ្ងៃនេះ មិនថាយើងរស់នៅលើមាតុភូមិកម្ពុជាក្រោម ឬនៅបរទេសដូចជាសហរដ្ឋអាមេរិកកាណាដា អឺរ៉ុប អូសេអានី ឬអាស៊ី ក៏ដោយខ្មែរក្រោមនៅតែរក្សាគោលជំហរដ៏រឹងមាំ ។ ដរាបណាយើងនៅតែមានវត្តមាន យើងនៅតែបន្តនិយាយការពិត និងរួបរួមគ្នាតស៊ូដោយសន្តិវិធី ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់យើងជានិច្ច ។

ក្នុងនាមជាពលរដ្ឋខ្មែរក្រោមដ៏មានមោទនភាព ការពង្រឹងអំណាចចាប់ផ្តើមពីការកំណត់នូវអត្តសញ្ញាណខ្លួនឯង ។ កុំអនុញ្ញាតឱ្យអ្នកដទៃកំណត់ថាអ្នកជានរណា ។ នៅពេលដែលអ្នកនិយាយភាសា សរសេរអក្សរ និងស្លៀកពាក់សម្លៀកបំពាក់បៃបប្រពៃណីជាតិរបស់អ្នកព្រមទាំងហ៊ានកំណត់អត្តសញ្ញាណខ្លួនឯងថាជា «ជនជាតិដើម» នោះគឺជាសកម្មភាពនៃការតស៊ូ ។ យើងក៏ត្រូវអនុវត្តនូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង»របស់យើង ព្រមទាំងសិទ្ធិកំណត់នូវស្ថានភាពនយោបាយ សិទ្ធិកំណត់អនាគតសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់យើងផងដែរ ។ សិទ្ធិទាំងនេះរួមមានការគ្រប់គ្រងដីធ្លី ការការពារបរិស្ថានពីសារធាតុគីមីពុល និងការប្រែប្រួលអាកាសធាតុ ដែលកំពុងគំរាមកំហែងដល់អត្ថិភាពនៃមាតុភូមិរបស់យើង ។ ថ្ងៃនេះយើងចេញសេចក្តីអំពាវនាវជាសកល ។ យើងអំពាវនាវដល់ **អ.ស.ប.** និងសហគមន៍អន្តរជាតិ ទាមទារឱ្យរបបអាណានិគមយួនត្រូវទទួលខុសត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជាសមាជិកក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ សមភាពពិតប្រាកដរវាងជនជាតិមិនអាចមានឡើយ ខណៈដែលសកម្មជនជនជាតិដើមត្រូវធ្វើទារុណកម្មក្នុងការឃុំខ្លួនមុនសវនាការ ហើយការកាត់ក្តីត្រូវបានធ្វើឡើងដោយបិទទ្វារ និងគ្មានមេធាវីការពារក្តីឡើយ ។

អនាគតរបស់យើងស្ថិតនៅក្នុងដៃយុវជនទាំងអស់គ្នា ដែលជាអ្នកបន្តអ្នកបំភ្លឺភ្លើងគប់សេរីភាពនៃជាតិយើង ឱ្យបានភ្លឺសុសសាយទូទាំងដែនដីកម្ពុជាក្រោម ។ យើងត្រូវរៀន និងចងចាំនូវមេរៀនប្រវត្តិសាស្ត្រពីអតីតកាល ហើយរួមគ្នាក្រោកឈរអនុវត្តនូវសិទ្ធិជាមូលដ្ឋានរបស់ខ្លួនតាពេលបច្ចុប្បន្ន ដើម្បីបានទូវ «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ដ៏ត្រចះត្រចង់នៅលើទឹកដីកំណើតរបស់ខ្លួន នាពេលអនាគត ។ យើងត្រូវចាំថា សិទ្ធិរបស់យើង មិនមែនរដ្ឋ ឬរបបអាណានិគមជាអ្នកកំណត់ ឬផ្តល់ឱ្យនោះទេ ។ មនុស្សគ្រប់រូបមានសិទ្ធិមកពីកំណើត ។

កាលពី ៧៧ ឆ្នាំមុន ដែនដីកម្ពុជាក្រោមរបស់យើងត្រូវបានផ្ទេរពីអាណានិគមមួយទៅអាណានិគមមួយទៀតប៉ុន្តែអត្តសញ្ញាណ សេចក្តីថ្លៃថ្នូរ ព្លជសាសន៍ និងស្មារតីរបស់យើង មិនដែលត្រូវបានផ្ទេរទៅជាមួយនោះឡើយ ។

ថ្ងៃនេះ យើងសូមគោរពនូវវីរភាពនៃបុព្វបុរសរបស់យើងគ្រប់រូបដែលបានបូជាជីវិត ក្នុងបុព្វហេតុក្សាការពារជាតិ និងសាសនានៅដែនដីកម្ពុជាក្រោម ។ យើងជាថ្នាក់ដឹកនាំសមាជិក សមាជិកា និងអ្នកគាំទ្រ **ស.ខ.ក.** ព្រមទាំងបងប្អូនជនរួមជាតិ រួមទាំងមិត្តអន្តរជាតិគ្រប់រូប គ្រប់ស្ថាប័ន ដែលជាអ្នកដែលស្រឡាញ់ លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស និងយុត្តិធម៌ តែងតែឈរយ៉ាងរឹងមាំជានិច្ចជាមួយនឹងព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមគ្រប់រូប ដែលកំពុងតែត្រូវរបបអាណានិគមយួនឃុំខ្លួន ទាំងអយុត្តិធម៌ ហើយយើងនៅ តែបន្តទាមទារជានិច្ច ដើម្បីបងប្អូនមានសេរីភាព និងបានជួបជុំគ្រួសារវិញ ។ យើងនឹងបន្តធ្វើការតស៊ូមតិនៅលើឆាកអន្តរជាតិជានិច្ច ដើម្បីការពារនូវសិទ្ធិជាមូលដ្ឋានរបស់បងប្អូនគ្រប់រូប ឱ្យទទួលបាននូវសិទ្ធិក្នុងការរស់រានមានជីវិតប្រកបដោយសេចក្តីថ្លៃថ្នូរ សន្តិភាព និងសេរីភាពពេញលេញនៅលើទឹកដីកេរដំណែលរបស់ខ្លួន ។

សូមអរគុណ និងអរព្រះគុណ

ជីវប្បវត្តិសង្ខេប
ព្រឹទ្ធាចារ្យ ចៅ រៀប
អតីតប្រធានសភាព្រឹទ្ធាចារ្យ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម

ក្នុងមហាសន្និបាតពិភពលោកលើកទី ១២ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម កាលពីថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០២៦ អង្គមហាសន្និបាតទាំងមូលបានទស្សនា និងស្តាប់ ព្រះតេជព្រះគុណ ថាច់ ធា (ចិត្តសន្ធោ) អានឆ្វរប្រវត្តិសង្ខេបរបស់លោកព្រឹទ្ធាចារ្យ ចៅ រៀប ដែលបានធ្វើពលិកម្មទាំងកម្លាំងកាយចិត្តក្នុងការបម្រើជាតិ និងចលនាតស៊ូខ្មែរកម្ពុជាក្រោម ។ នៅដែនដីកម្ពុជាក្រោម លោកបានចូលរួមក្នុងចលនាតស៊ូតាំងពីឆ្នាំ ១៩៦០ បម្រើក្នុងកងទ័ពសហរដ្ឋអាមេរិក និងបានឆ្លងកាត់ការប្រយុទ្ធ ជាប់ពន្ធនាគារ និងទុក្ខលំបាកជាច្រើន មុនពេលមករស់នៅសហរដ្ឋអាមេរិក ។ ចាប់ពីឆ្នាំ ២០០៤ ដល់ ២០២៦ លោកបានបម្រើការជាប្រធានសភាព្រឹទ្ធាចារ្យ នៃ ស.ខ.ក. ចំនួន ៥ អាណត្តិ និងបានចូលរួមវេទិកាអន្តរជាតិជាច្រើន ដើម្បីលើកកម្ពស់សិទ្ធិ និងសេចក្តីប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរក្រោម ។ នៅឱកាសបញ្ចប់អាណត្តិ និងចូលនិវត្ត អង្គមហាសន្និបាតបានសម្តែងការគោរព និងកោតសរសើរចំពោះគុណសម្បត្តិ ការលះបង់ និងគំរូវីរភាពរបស់លោក ។

ខាងក្រោមនេះជាប្រវត្តិសង្ខេបរបស់លោកព្រឹទ្ធាចារ្យ ចៅ រៀប ដែលបានរៀបរៀង ដោយ លោក ថាច់ ប្រ៊ីជា គឿន ដូចតទៅ៖

លោក **ចៅ រៀប** ជាព្រឹទ្ធបុរសគំរូមួយរូបនៅក្នុងចំណោមថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ។ លោកជាមនុស្សម្នាក់ដែលមានគុណធម៌ ភក្តីភាព និងស្នាតស្នំបំផុត ទាំងចំពោះសង្គមគ្រួសារ និងជាតិរបស់ខ្លួនយ៉ាងជ្រាលជ្រៅក្រៃលែង ។ ពេលមកដល់ទឹកដីសហរដ្ឋអាមេរិក លោកតែងតែលះបង់ទាំងកម្លាំងកាយ ពេលវេលា ប្រាជ្ញាស្មារតី និងថវិកា ចូលរួមគ្រប់សកម្មភាពជាមួយនឹង **ស.ខ.ក.** ឥតងាករេប្រកបដោយភាពស្មោះត្រង់ ដែលជាបំណែកពលិកម្មដ៏ធំធេងមួយមិនអាចកាត់ថ្លៃបាន ក្នុងការជំរុញ សហព័ន្ធខ្មែរកម្ពុជាក្រោម ឱ្យមានភាពលេចធ្លោ និងតស៊ូមតិមានប្រសិទ្ធភាពនៅលើឆាកអន្តរជាតិ ដើម្បីការពារនូវសិទ្ធិសេរីភាពជាមូលដ្ឋានរបស់ពលរដ្ឋនៅកម្ពុជាក្រោម ។ មុនពេល ទទួលតំណែងជាប្រធាន គណៈកម្មការរៀបចំការបោះឆ្នោត នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម (**គ.ប.ស**) នាពេលនេះ លោក មានឋានទីជា "**ប្រធានសភាព្រឹទ្ធាចារ្យ**" នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម តាំងពីឆ្នាំ ២០០៤ រហូតដល់បច្ចុប្បន្ន នាពេលនេះ ។

តើលោកព្រឹទ្ធាចារ្យ ចៅ រៀប មានកំណើតកើតជាមកពីណា? នៅក្នុងឱកាសដែលលោកព្រឹទ្ធាចារ្យបញ្ចប់អាណត្តិ និងសុំចូលនិវត្តពីតំណែងជា គណៈកម្មការនាយក នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម អង្គមហាសន្និបាត សូមផ្តល់ "**ប័ណ្ណសរសើរ**" និងអានឆ្វរប្រវត្តិសង្ខេបរបស់លោកព្រឹទ្ធាចារ្យ **ចៅ រៀប** បែកជូនអ្នកចូលរួមទាំងអស់បាន



ព្រឹទ្ធាចារ្យ ចៅ រៀប ជាអតីតប្រធានសភាព្រឹទ្ធាចារ្យ
នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ។ រូបថត៖ ថាច់ ប្រ៊ីជា គឿន

ជ្រោបជ្រៃបតទៅ:

លោក បៅ រៀប ប្រសូតនៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ១៩៤១ នៅ**ភូមិទម្ពរ ឃុំទម្ពរ ស្រុកស្វាយទង ខេត្តមាត់ជ្រូក ដែនដីកម្ពុជាក្រោម** ។ មិនមែនមកដល់សហរដ្ឋអាមេរិកហើយ ទើបលោកធ្វើការតស៊ូដើម្បីពលរដ្ឋនៅដែនដីកម្ពុជាក្រោមទេ្បី គឺនៅឆ្នាំ ១៩៦០ លោកបានចូលបម្រើក្នុងបលនាតស៊ូខ្មែរកម្ពុជាក្រោម ក្នុងកងពលលេខ ១០៦ ក្នុងហ៊ុនៈជាមេបញ្ជាការកាំភ្លើងត្បាល់ ដើម្បីរំដោះជាតិចេញពីនឹមអាណានិគមយួន ។

ក្នុងសម័យសង្គ្រាមវៀតណាម លោកបានចូលបម្រើក្នុងកងទ័ពសហរដ្ឋអាមេរិក និងមានឋានន្តរសក្តិជាបន្តបន្ទាប់ពីអនុសេនីយត្រី (សក្តិ ១) រហូតដល់អនុសេនីយឯក (សក្តិ ៣) ក្នុងឆ្នាំ ១៩៧២ ។ នៅក្នុងឆាកប្រយុទ្ធឡុងភឺ នាឆ្នាំ ១៩៦៩ លោកត្រូវរបួសធ្ងន់ត្រង់ថ្គាមដោយគ្រាប់បែក B-40 ។ ពេលត្រូវរបួស លោកត្រូវគេយកទៅព្យាបាលរបួសនៅលើនាវាបម្បាំងលេខ ៧ នៃកងទ័ពជើងទឹកសហរដ្ឋអាមេរិកប្រចាំ ការនៅសមុទ្រប៉ាស៊ីហ្វិកអស់ ៦ ខែ ។ ដោយមានគុណសម្បត្តិនៅក្នុងការតស៊ូ លោកបានទទួលមេដាយសំរឹទ្ធ Bronze Star Medal ដែលមានអក្សរ "V" ពីកងទ័ពសហរដ្ឋអាមេរិក បំពោះវីរភាពក្នុងសមរភូមិ និងមេដាយកិត្តិយសជាប្រើនទៀត ។

ក្រោយឆ្នាំ ១៩៧៥ លោកត្រូវរបបយួនកុម្មុយនិស្តចាប់ដាក់គុក និងធ្វើទារុណកម្មអស់រយៈពេល ៧ ឆ្នាំ និងបានដោះលែងវិញ នៅឆ្នាំ ១៩៨២ ធ្វើឱ្យលោកងងឹតភ្នែកអស់ ៦០ ភាគរយ ។ បេញពីឥណ្ឌានគារបាន ៧ ខែ អ្នកស្រី **នាង គឹម ជន** ជាភរិយារបស់លោក បានទទួលអនិច្ចកម្មដោយជំងឺ ក្នុងជន្មាយុ ៤០ ឆ្នាំ ធ្វើឱ្យរូបលោកក្លាយជាបុរសពោះម៉ាយចិត្តស្មោះ ទទួលបន្ទុកជាមេគ្រួសាររហូតមកដល់សព្វថ្ងៃ ។


ឆ្នាំ ១៩៩៤ លោកបានបណ្តើរកូនៗចំនួន ៤ នាក់ បេញពីមាតុភូមិកម្ពុជាក្រោម មករស់នៅទីក្រុង Tacoma រដ្ឋ Washington សហរដ្ឋអាមេរិក ហើយក្លាយជាអ្នកទទួលបន្ទុកឃុំគ្រងកូនបៅ និងបង្កើតទៅជាសង្គមគ្រួសារដ៏ល្អមួយនៅលើទឹកដីថ្មីនេះ ។

ពេលគ្រួសារផ្ទុះសម្បែង និងកូនបៅមានលំនឹងហើយ លោកក៏បានចូលរួមដំណើរបេសកកម្មជាមួយនឹង សហព័ន្ធខ្មែរកម្ពុជាក្រោម ឥតងាករេ ហើយបានទទួលតំណែងជាអនុប្រធាន និងក្រោយមកជាប្រធាន**សភាព្រឹទ្ធាចារ្យ** នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម បំនួន ៤ អាណត្តិជាប់គ្នា គឺ ពី ឆ្នាំ ២០០៤ ដល់ ២០២៦ ។

ក្នុងហ៊ុនៈជា គណៈកម្មការនាយក នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម លោកបានចូលរួមមហាសន្និបាតអង្គការសហប្រជាជាតិ (UNPFII) បំនួន ៤ លើក និងសន្និសីទអន្តរជាតិជាប្រើន ដើម្បីស្វែងរក «សិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង» ជូនពលរដ្ឋនៅកម្ពុជាក្រោម ។

ប្រវត្តិពិស្តាររបស់ លោកព្រឹទ្ធាចារ្យ **បៅ រៀប** មានចារពិស្តារនៅក្នុងសៀវភៅអាមេរិក «Lost Crusade» រៀបរៀងដោយ លោក Peter Scott និង សៀវភៅ **«ជីវប្បវត្តិ បៅ រៀប»** ដែលរៀបរៀងដោយ លោក **ថាប់ ប្រឹជា គឿន** កាលពីឆ្នាំ ២០២០ ។

នៅក្នុងឱកាសលោកបញ្ចប់អាណត្តិ និងចូលនិវត្តនេះ យើងខ្ញុំជាថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោមគ្រប់រូប សូមបងចាំនូវគំរូវីរភាពរបស់លោកព្រឹទ្ធាចារ្យ និងប្តេជ្ញារួមគ្នាបន្តវេនធ្វើដំណើរតស៊ូប្រកបដោយគុណធម៌ សីលធម៌ ភក្តីភាព វីរភាព និងស្អាតស្អំ តាមគំរូរបស់ លោកព្រឹទ្ធាចារ្យ និងថ្នាក់ដឹកនាំសហព័ន្ធខ្មែរកម្ពុជាក្រោម ដទៃទៀត ដែលមានគុណធម៌ និងហ៊ានប្រឈមមុខបំពោះរាល់ឧបសគ្គនានា ក្នុងការរក្សាការពារនូវបលនាតស៊ូ **ស.ខ.ក.** ឱ្យបានគង់វង្សរហូតមកដល់ សព្វថ្ងៃ ។



ប្រវត្តិ ទិដ្ឋភាព និងព្រឹត្តិការណ៍សំខាន់ៗ នៃទឹកដីខេត្តឃ្លាំង កម្ពុជាក្រោម

ឃ្លាំង ជាខេត្តដ៏សំខាន់មួយរបស់អាណាចក្រខ្មែរពីអតីតកាល និងសព្វថ្ងៃ នៅក្នុងដែនដីកម្ពុជាក្រោម ដែលកំពុងតែបិតនៅក្រោមការត្រួតត្រា និងគ្រប់គ្រងដោយប្រទេសវៀតណាម ហើយត្រូវរដ្ឋាភិបាលវៀតណាមប្តូរឈ្មោះទៅជាខេត្ត «សុកត្រាំង» វិញ ។ ខេត្តនេះត្រូវបានយួនរំលោភយកនៅឆ្នាំ ១៨៤០ តំណាលគ្នាជាមួយ និងខេត្ត៣ទៀតគឺខេត្ត «ព្រះត្រពាំង» ខេត្ត «ពលលាវ» និងខេត្ត «ទឹកខ្មៅ» ។

១- ប្រវត្តិខ្លះៗនៃខេត្តឃ្លាំង:

តាមការស្រាវជ្រាវក្នុងឯកសារជាប្រើនបានបញ្ជាក់ថា **ខេត្តឃ្លាំង** ហាក់ដូចជាមិនមានឈ្មោះថា "**ឃ្លាំង**" ពីមុនមកទេ ។ នោះជាស្រុក "**បាសាក់**" ហើយអង្គភាពស្រុកពីមុន មិនមែនតួចដូចអង្គភាពរដ្ឋបាលស្រុក នាពេលបច្ចុប្បន្ននេះដែរ ប៉ុន្តែមានវិសាលភាពស្មើនឹងតំបន់ គឺធំជាងខេត្តទៅទៀត ។ យើងសូមលើកប្រវត្តិស្រុក "**បាសាក់**" ឬ ខេត្តឃ្លាំង ចាប់ពីត្រឹមសម័យអង្គរមក រ៉ាយរ៉ាបដោយសង្ខេបដូចតទៅ:

នៅក្នុងរជ្ជកាល **ព្រះបាទស្ថរិយាវរ្ម័នទី ២** ក្នុងអម្លង គ. ស. ១១១៣ ដល់ ១១៥០ ស្រុក "**បាសាក់**" ជាតំបន់កណ្តាលមួយដែលត្រួតត្រាដោយ **ពញាតេជោ** និងត្រួតត្រាលើតំបន់បំនួន ៤ គឺ ១ - តំបន់ពាមបន្ទាយមាស និងតំបន់ "**ទ្រាំងតើយខាងត្បូង**" គឺខេត្ត**មាត់ជ្រូក** បច្ចុប្បន្ន ។ ២ - តំបន់ទីប្រជុំជនឃ្លាំងបច្ចុប្បន្ន ៣–បន្ទាយ**ព្រៃនគរ** ដែលត្រួតត្រាដោយ **ពញាឱិន** ហេតុដូច្នេះ ហើយទើបនៅម្តុំជុំវិញទីក្រុង**ព្រៃនគរ** យួនដាក់ឈ្មោះថាខេត្ត "**យ៉ាឱិញ**" ។ ៤- និងតំបន់មួយទៀតនៅ**ពាមដូនណៃ** ស្ថិតនៅក្នុង**ខេត្តពាមបង្កា ស្រុកការត្រឹ** ដែលពីមុនយួនហៅថា **បៀនហ្វា** និងបច្ចុប្បន្នហៅថា **ខេត្តដុងណាយ** ។

តើពាក្យថា ឃ្លាំង កើតឡើងនៅពេលណា?

បើតាមឯកសារជាប្រើនហាក់បានបញ្ជាក់ឲ្យយើងសន្និដ្ឋានបានថា ពាក្យថា **ឃ្លាំង** នេះទំនងកើតឡើងក្នុងអំឡុង គ. ស. ១៥២៨ ក្នុងរជ្ជកាល**ព្រះអង្គច័ន្ទ**ទ្រង់យាងគ្រងរាជ្យ ដោយព្រះអង្គបានតែងតាំងពញាតមានងារជា **ស្តេទ្ធិភូបាលពញាតាត** លោកបានកសាងឃ្លាំងមួយយ៉ាងធំ ដើម្បីផ្ទុកស្រូវសម្រាប់ចែកជូនដល់ប្រជាពលរដ្ឋនៅពេលមានអាសន្នអត់ក្រ ។ ចាប់ពីពេលនោះហើយទើបតំបន់នោះមានឈ្មោះថា "**ឃ្លាំង**" ជំនួសពាក្យ "**បាសាក់**" រហូតដល់សព្វថ្ងៃនេះ ។



ក្រុមសមាគមសិក្សាវិទ្យាល័យខេមរជាតិនៅដែនកូសាំងស៊ីន បិតនៅក្នុងខេត្តឃ្លាំង ឆ្នាំ ១៩៣៧ ។

២- ស្ថានភាពរួមនៃខេត្តឃ្លាំង:

ឃ្លាំងគឺជាខេត្តមួយដែលមានខ្មែរក្រោមរស់នៅយ៉ាងច្រើន នៃទឹកដីកម្ពុជាក្រោម ។ ដើមឡើយខេត្តនេះបែកចេញជា ៧ ស្រុកគឺ **ស្រុកបាយដៅ** (មីស្ងៀង) **ស្រុកព្រៃកគយ** (លិតហ្គយធឿង) **ស្រុកអណ្តូងទឹក** (ឡុងភូ) **ស្រុកឡាប់** (គេសាត់) **ស្រុកកំពង់ធំ** (មីទូវ) **ស្រុកដាំណាំ** (មិនប្បាស់ឈ្មោះជាភាសាខ្មែរ) និង ស្រុក**ខ្នាបប្រាំងបម្រេះ** (ឋាញ់ទ្រី) ។ លុះដល់ឆ្នាំ ១៩៧៥ ពេលដែលកងទ័ពកុម្មុយនិស្តយួន ឈ្នះសង្គ្រាមលើយួនខាងត្បូងនោះ គេបានកាត់ស្រុកមួយពីខេត្តពលលាវគឺស្រុក "**ក្រាយញ**" មកបញ្ចូលជាមួយ**ខេត្តឃ្លាំង** និងបានបង្កើតស្រុកថ្មីបំនួន ២ ទៀតគឺ**ស្រុកកោះទុង** (គូឡាវិយុង) និងស្រុកមួយទៀតឈ្មោះ ប្ងូវ ឋាញ់ ដោយកាត់យកភូមិឃុំខ្លះពី**ស្រុកឡាប់ ស្រុកបាយដៅ** និង**ស្រុកអណ្តូងទឹក**ជាដើមប្រមូលផ្តុំគ្នា ឯទីប្រជុំជនខេត្តឃ្លាំងគេបានបង្កើតទៅជាអង្គភាពរដ្ឋបាលមួយទៀត ស្មើនឹងស្រុកដែរគឺ "**ក្រុង**

ឃ្លាំង" ។ សរុបទៅនៅក្នុងខេត្តឃ្លាំងមានអង្គភាព រដ្ឋបាលស្មើនឹងស្រុកចំនួន ១១ ។ ចំណែកស្រុកដែលមានខ្មែរកម្ពុជាក្រោម រស់នៅយ៉ាងច្រើនកុះករមានចំនួន ៧ ស្រុកគឺ **ស្រុកជ្រោយញ ស្រុកបាយនៅ ស្រុកអណ្តូងទឹក ស្រុកខ្សាច់ ស្រុកកំពង់ធំ ស្រុកឫវ៉ាញ់** និងស្រុក**ព្រៃកគយ** ។ សូមបញ្ជាក់ដែរថា **ស្រុកព្រៃគយ** ដែលពីមុនមានឈ្មោះថា ជាភាសាវៀតណាមថា "**លិតហួយលឿង**" តែបច្ចុប្បន្នគេបានបញ្ចូលភូមិឃុំខ្លះពី**ស្រុកបាយនៅ** មកក្នុង**ស្រុកព្រៃកគយ**នេះដែរហើយផ្លាស់ឈ្មោះពី "**លិតហួយលឿង**" មកជាស្រុកត្រឹងដេវិញ ។ ខេត្តឃ្លាំងមានវត្តព្រះពុទ្ធសាសនាខ្មែរបំនួន ៤២ វត្ត ។ និងមានប្រជាជនខ្មែរប្រមាណជា ៦០០.០០០ (៦សែន) នាក់ ។

៣-បម្រែបម្រួលនៃភូមិសាស្ត្រខេត្តឃ្លាំង៖

នៅក្នុងអំឡុងឆ្នាំ ១៩៧៧ ពេលដែលវៀតណាមទាំងពីរបញ្ចូលទៅជាវៀតណាមតែមួយ ហើយមានការកែប្រែភូមិសាស្ត្ររដ្ឋបាលនោះខេត្តឃ្លាំង ត្រូវបានបញ្ចូលរួមជាមួយនឹង **ខេត្តព្រៃកប្បស្សី** ហើយដាក់ឈ្មោះជាខេត្ត "**ហ្វវ៉ាយ៉ាង**" ដែលមានន័យជាខ្មែរថា**ខេត្តបាសាក់** ដូចពីមុនដែរ ។ ប៉ុន្តែបច្ចុប្បន្នខេត្តឃ្លាំងត្រូវបានបំបែកចេញពី **ខេត្តព្រៃកប្បស្សី** ហើយយកឈ្មោះជាខេត្ត "**សុកត្រាំង**" គឺ**ឃ្លាំង**ដូចពីមុនវិញ និងនៅសម័យ ង៉ោ ឌីញ យៀម និង "ង្វៀន វ៉ាន់ ធីវ ក្នុងអំឡុងឆ្នាំ ១៩៥០ ប្លាយដល់ឆ្នាំ ១៩៧៥ ខេត្តឃ្លាំងត្រូវបានប្តូរឈ្មោះពី **ស្រុក ត្រាំង** មកជាខេត្តបាស្យៀន (Ba Xuyen) ។

៤-សោកនាដកម្មដែលខ្មែរក្រោមខេត្តឃ្លាំងធ្លាប់ទទួលរងៈ

សោកនាដកម្មដែលខ្មែរក្រោមខេត្តឃ្លាំងក៏ដូចជាខេត្តដទៃទៀតទទួលរងតែងតែមានស្នើរគ្រប់កាល:ទេស: ប៉ុន្តែសោកនាដកម្មរបស់ខ្មែរក្រោមខេត្តឃ្លាំង ដែលយើងលើកឡើងនៅពេលនេះជាសោកនាកម្មដ៏ធំធេងដែលពួកគេបានទទួលតែប៉ុណ្ណោះ ។ សោកនាដកម្មដ៏ធំធេងទាំងនោះយ៉ាងហោចណាស់ក៏មាន ៤ លើកដែរគឺៈ

១-ក្នុងអំឡុងឆ្នាំ ១៨៥៩ មានសង្គ្រាមយ៉ាងស៊ីសាច់ហុតឈាមគ្នារវាងកងទ័ពយួនគឹងខ្មែរក្រោមនៅតំបន់មហាទប់ **បុងបល់ង្គ អម្ពយា** ក្រោមការដឹកនាំរបស់លោក **សេនា ស្នស** ដែលក្នុងសង្គ្រាមនោះទ័ពខ្មែរក្រោមបានសម្លាប់ឧត្តមសេនីយ៍មេបញ្ជាការកងទ័ពយួនម្នាក់ឈ្មោះ "**ង្វាញ់ ស៊ឹម**" ។ តែលោកសេនាស្នសក៏ត្រូវបាមម្នាក់បន្ទំខ្លួនជាទ័ពខ្មែរហើយបានដាក់ថ្នាំបំពុលសេនាស្នសស្លាប់ទៅ ។ ឯសព **សេនាស្នស្ត** ត្រូវបានខ្មែរក្រោមយកមកបូជានៅក្បែរព្រែកមួយ ដែលសព្វថ្ងៃមានឈ្មោះថា**ភូមិដៃតាស្នស្ត** នៅចម្ងាយ ១០ គីឡូម៉ែត្រពីទីក្រុងឃ្លាំង ។

២-នៅឆ្នាំ ១៩៦៨ ក្នុងឱកាសបុណ្យចូលឆ្នាំវៀករបស់បិនឆ្នាំ ១៩៦៨ ដែលគេនិយមហៅ "**តេតម៉ូវ៉ឺង**" (Tet Mau Than) កងទ័ពរបស់យួនខាងត្បូងនិងយួនខាងជើងឬយួនវៀតកុងបានដាក់សមរភូមិយ៉ាងក្តៅគគុកក្នុងតំបន់ខ្មែរស់នៅធ្វើឱ្យឆេះផ្ទះសម្បែងនិងវត្តអារាមខ្មែរយ៉ាងច្រើនពិសេសក្នុងស្រុកព្រៃកគយស្រុកបាយនៅ និងស្រុកកំពង់ធំ ។ ក្នុងសង្គ្រាមនេះព្រះតេជព្រះគុណ (សេក គឹម សេង) បៅអធិការវត្តបឹងខ្យងក្នុងស្រុកកំពង់ធំត្រូវរងគ្រាប់រំសេវ រហូតដល់សុគតផងដែរ ។

៣-ក្នុងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦ ខ្មែរក្រោមក្នុងស្រុកជ្រោយញ និងស្រុកព្រៃកគយ ត្រូវអាជ្ញាធរយួនកុម្មុយនិស្តចាប់ដាក់ពន្ធនាគារជាច្រើនរយនាក់ ក្រោយពីធ្វើការតស៊ូទាមទារសិទ្ធិសេរីភាពជូនខ្មែរក្រោមតែត្រូវបរាជ័យ ។

៤- ឆ្នាំ ២០០៧ ក្រុមសមណសិស្សសាលាពុទ្ធិកសិក្សាបំពេញវិជ្ជាបាលីភាគខាងត្បូង (ណាមបោ) នៅក្នុងក្រុងឃ្លាំង បានក្រោកឡើងធ្វើបាតុកម្មទាមទារឱ្យរដ្ឋាបាលគោរពនូវសិទ្ធិសេរីជំនឿសាសនា របស់ប្រជាពលរដ្ឋខ្មែរក្រោម ។ នៅក្នុងការធ្វើបាតុកម្មនោះ សមណសិស្សខ្មែរកម្ពុជាក្រោមបំនួន ៥ ព្រះអង្គត្រូវបានអាជ្ញាធរយួនខេត្តឃ្លាំង ចាប់ផ្សឹកបញ្ជូនទៅតុលាការ ដោយតុលាការបានប្រកាសសាលក្រមផ្តន្ទាទោសឱ្យជាប់ពន្ធនាគារ ពី ២ ទៅ ៤ ឆ្នាំ និងសមណសិស្សមួយបំនួនទៀតក៏ត្រូវចាប់ខ្លួនដែរ ប៉ុន្តែឱ្យស្ថិតនៅក្រៅឃុំ ។

៥-មុខរបរចិញ្ចឹមជីវិតរបស់ខ្មែរក្រោមនៅខេត្តឃ្លាំង៖

ដោយខេត្តឃ្លាំងជាភូមិសាស្ត្រដ៏មានជីជាតិនិងអំណោយផលដូច្នេះមុខរបរចិញ្ចឹមជីវិតរបស់ខ្មែរក្រោមក្នុងខេត្តនេះក៏មានលក្ខណៈសម្បូរបែបជាបង្អែរ ក្រៅពីមុខរបរធ្វើស្រែ ខ្មែរក្រោមក៏នៅមានមុខរបរធ្វើបម្លាដាំដំណាំផ្សេងៗ ដូចជាឱឡឹក ត្រសក់ ពោត សណ្តែក ខ្ទឹមក្រហម ខ្ទឹមស ស្ពៃគ្រប់ប្រភេទមុខរបរនេសាទត្រីតាមទន្លេសមុទ្រចិញ្ចឹមបង្កា និងខ្លះជាអាជីវកររងដែរ ធ្វើឱ្យជីវភាពរបស់ពួកគេបានធូរធារក្នុងកម្រិតបង្អែរដែរ ។

៦-មន្ត្រី រដ្ឋការ និងនាយទាហានជាន់ខ្ពស់ខ្មែរក្រោមខេត្តឃ្លាំង

ក-ជំនាន់វៀតណាមសាធារណរដ្ឋ

តាមការពិនិត្យឃើញជាទូទៅគឺខេត្តឃ្លាំងមានឥស្សរជនឧយោបាយ និងនាយទាហានជាន់ខ្ពស់ក្នុងជួររដ្ឋាភិបាលយួនជាច្រើន ក្នុងចំណោមខ្មែរក្រោមនៅក្នុងខេត្តដទៃទៀត ដូចជាមន្ត្រីផ្នែកនយោបាយយ៉ាងហោចណាស់ក៏មាន ៣ រូបដែរគឺ លោក **គីម ទាន់** ជាសមាជិកព្រឹទ្ធសភា ឆ្នាំ ១៩៧២ ដល់ឆ្នាំ ១៩៧៥ ។ លោក **សឺន ធី** ធ្លាប់ជាសមាជិកសភាធម្មនុញ្ញ ក្នុងឆ្នាំ ១៩៦៦ ដល់ ឆ្នាំ ១៩៦៨ និងជាប់ជាតំណាងរាស្ត្រក្នុងមណ្ឌលខេត្តឃ្លាំងពីឆ្នាំ ១៩៧១ ដល់ឆ្នាំ ១៩៧៥ ។ លោក **តាំង បា ស្ងឹង** ជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រខ្មែរមណ្ឌលខេត្តឃ្លាំងពីឆ្នាំ ១៩៦៧ ដល់ឆ្នាំ ១៩៧១ ។ និងលោក **សឺន អៀង** ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ពង្រីកជីវភាពប្រជាជនវៀតណាម កំណើតខ្មែរ ពីឆ្នាំ ១៩៧២ ដល់ឆ្នាំ ១៩៧៥ ។

បំណែកនាយទាហានជាន់ខ្ពស់ក្នុងសម័យវៀតណាមសាធារណរដ្ឋខ្មែរក្រោមខេត្តឃ្លាំងមាននាយទាហានជាន់ខ្ពស់ដែលមានឋានន្តរស័ក្តិដល់ថ្នាក់វរសេនីយ៍ឯកដែលជាឋានន្តរស័ក្តិខ្ពស់បំផុតសម្រាប់ខ្មែរក្រោមក្នុងជួរកងទ័ពវៀតណាមសាធារណរដ្ឋគឺ៖

១-លោកវរសេនីយ៍ឯក **គីម ទាន់** ស្រុកកំណើតនៅភូមិ **"កំពង់ធំ" "ស្រុកខ្សាច់"** ជាអគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍ពង្រីកជីវភាពប្រជាពលរដ្ឋវៀតណាមកំណើតខ្មែរ ។

២-លោកវរសេនីយ៍ឯក ត្រឹង ថាន់ ដៀង ស្រុកកំណើតនៅភូមិកំពង់ធំស្រុកខ្សាច់ជាមេបញ្ជាការរង នៃកងអង្គរក្សរបស់លោកប្រធានាធិបតីវៀតណាមខាងត្បូង **ង្វៀន វ៉ាន់ ធីវ** ។

៣-លោកវរសេនីយ៍ឯក **ជាវ សាវង្ស** ស្រុកកំណើតនៅភូមិ **"វត្តពេជ្រ"** ស្រុក **"ជ្រោយញ"** ជាមេបញ្ជាការរងយោធាប្រចាំ**ខេត្តពាម**បង្វារស្រុកត្រី (បៀនហ្វា) និងខេត្តទួលតាមោក (ប៊ិញយឿង) ។

ខ-សម័យវៀតណាមកុម្មុយនិស្ត

បំណែកក្នុងសម័យកុម្មុយនិស្តវៀតណាមវិញគេពិបាកកំណត់ថា តើមាននាយទាហានជាន់ខ្ពស់ជាខ្មែរក្រោមប៉ុន្មានរូប តែគេពិនិត្យឃើញមានខ្មែរក្រោមបង្វែរដែរ ដែលបានជាប់ឆ្នោតជាសមាជិករដ្ឋសភារបស់វៀតណាមបច្ចុប្បន្ន ដូចជា លោក **ហ៊ិញ កឿង** លោក **លី សេន** លោក **ទ្បឹម គឿង** លោកស្រី **សឺន ធី ហាយ** លោក **ថាប់ មិញ សុខ** ព្រះតេជព្រះគុណ **ថាប់ ហួន** ចៅអធិការ**វត្តទេពារាមព្រៃជាប់** ព្រះតេជព្រះគុណ **លី មិន ឌឹក** ចៅអធិការ**វត្តសំរោង** ជាដើម ។ ហើយ លោក **ហ៊ិញ កឿង** ធ្លាប់បានជាប់ឆ្នោតជាអនុប្រធានរដ្ឋសភាពីរអាណត្តិបន្តបន្ទាប់គ្នាមុនលោកទទួលមរណភាព ។



អគារពុទ្ធសាសនបណ្ឌិត្យរងនៅដែនកូសាំងស៊ីន ខេត្តឃ្លាំង ។

គ-នៅកម្ពុជា

នៅកម្ពុជាគេក៏បានឃើញខ្មែរក្រោមខេត្តឃ្លាំង មានអ្នកល្បីឈ្មោះស្នើរតែគ្រប់វិស័យដូចជាលោក **សឺន ឌៀប** ដែលមានស្រុកកំណើតនៅ**ភូមិពងទឹក ស្រុកខ្នុបប្រាំងបម្រេះ** ជាមន្ត្រីជាន់ខ្ពស់នៅក្នុងព្រះបរមរាជវាំងរហូតដល់បានទទួលគោរមងារជា**សម្តេចព្រះពោធិសាល** ពីព្រះមហាក្សត្រខ្មែរទៀតផង ។ ផ្នែកវិស័យអប់រំមានខ្មែរក្រោមខេត្តឃ្លាំងមួយរូបជាសាស្ត្រាចារ្យដ៏ល្បីក្នុងមជ្ឈដ្ឋានប្រជាពលរដ្ឋ ចាប់ពីសម័យសង្គមរាស្ត្រនិយមរហូតដល់សព្វថ្ងៃនេះនោះ គឺលោក **ត្រឹង ងា** ស្រុកកំណើតនៅ**ភូមិព្រៃជាប់ ស្រុកជ្រោយញ** ។ ក្នុងសម័យសាធារណរដ្ឋខ្មែរលោកមានឋានៈជានាយកវិជ្ជាស្ថានខ្មែរ - មន ផង ។ វិស័យយោធាយ៉ាងហោចណាស់មានខ្មែរក្រោមខេត្តឃ្លាំងថ្នាក់ឧត្តមសេនីយ៍ ៣ រូបដែរគឺ លោក **ថាប់ ចាន់** ស្រុកកំណើតនៅ**ខ្នុបប្រាំងបម្រេះ** ។ លោកឧត្តមសេនីយ៍ **ដៀង ដែល** មានស្រុកកំណើតនៅ**ភូមិពងទឹក** ស្រុកដូចគ្នា ។ និងលោកឧត្តមសេនីយ៍ **ទ្បឹម គេន** ស្រុកកំណើតនៅស្រុកអណ្តូងទឹក ។ ក្នុងសម័យរាជាណាចក្រកម្ពុជា បច្ចុប្បន្នមានលោក **ថាប់ សាង** ស្រុកកំណើតនៅភូមិសំរោង សង្កាត់លេខ ៤ ទីក្រុងឃ្លាំង ជាឧត្តមនាវី (ជើងទឹក) ផងដែរ ។

ក្នុងវិស័យនយោបាយ លោក **ថាប់ ចាន់** ធ្លាប់ជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ ក្នុងសម័យសង្គមរាស្ត្រនិយម ។ និងខ្មែរក្រោម ខេត្តឃ្លាំង ២ រូបទៀត ដែលបានជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រក្នុងសម័យរាជាណាចក្រទី ២ នេះគឺ លោក **ហៀន វណ្ណា រ័ត្ន** ហៅ **ឈួន** ស្រុកកំណើតនៅ**ភូមិព្រៃជាប់** និងលោក **ថាប់ សាង** ស្រុកកំណើតនៅ**ភូមិសំរោង** ។

ខ្មែរក្រោមខេត្តឃ្លាំងក៏មានឥស្សរជន ២ រូបផងដែរដែលជាសមាជិកគណៈរដ្ឋមន្ត្រីគឺលោក **ហៀន វណ្ណារ័ត្ន** ជារដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា និង លោក **ទៀ បេន** ស្រុកកំណើតនៅ**ភូមិបឹងខ្ញែ ឃុំស្វាយជ្រុំ** ជារដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា ។ ខ្មែរក្រោមខេត្តឃ្លាំងយ៉ាងហោចណាស់ក៏មានតារាចម្រៀង ១ រូបដ៏ល្បីឈ្មោះតាំងពីទសវត្សឆ្នាំ ៦០ និង ៧០ ដែលជាម្ចាស់បទបាងហ្គាវ៉ាន់ស្វូឡ្ស ដំបូងគេបង្អស់ គឺអ្នកស្រី **ឈុន វណ្ណា** មិនច្បាស់ស្រុកកំណើត និងតារាកំប្លែងមួយរូបដ៏មានប្រជាប្រិយភាពគឺលោក **ប៉ែន សេង** ហៅ **ស៊ុយ** ក៏មិនច្បាស់ស្រុកកំណើតដែរ ។

ផ្នែកតែងនិពន្ធនិងសារព័ត៌មាន៖

ផ្នែកតែងនិពន្ធវិញក្រៅពីលោក **ត្រឹង ងា** ដែលជាអ្នកនិពន្ធប្រវត្តិសាស្ត្រកម្ពុជាដ៏ល្បី តាំងពីសម័យសង្គមរាស្ត្រនិយមនោះមក ដល់បច្ចុប្បន្នក៏លេចចេញនូវអ្នកនិពន្ធពីប្រវត្តិទឹកដីកម្ពុជាក្រោម បំនួន ៣ រូបទៀតដែរគឺ៖

១- លោក **ត្រឹង ធាតប៊ុត** ស្រុកកំណើតនៅ**ភូមិព្រៃកពិន្ទង** ស្រុក**កំពង់រំ** អតីតមន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃ លោកបានិពន្ធសៀវភៅមួយចំនួនជាលក្ខណៈប្រវត្តិនៃទឹកដីកម្ពុជាក្រោម ដូចជា សៀវភៅ **"កម្ពុជាក្រោមអំណាចគ្មានខ្មែរក្រោម"** ជាដើម ។

២- លោក **ទៀ បេន** ស្រុកកំណើតនៅឃុំស្វាយជ្រុំស្រុកបាយដៅ លោកបានិពន្ធសៀវភៅដែលមានចំណងជើងថា **"រឿងរ៉ាវនៃទឹកដីកម្ពុជាក្រោមឬអតីតកូសាំងស៊ីន"** លោក **ទៀ បេន** ក៏ជាចាងហ្វាងទស្សនាវដ្តី **នន្ទ្រទេវី** និងសារព័ត៌មានខ្មែរមេគង្គផងដែរ ។

៣-លោក **តាំង សារៈ** ស្រុកកំណើតនៅ**ភូមិព្រៃជាប់ ស្រុកជ្រោយញ** លោកបានិពន្ធរឿងប្រលោមលោកដែលមានចំណងជើងថា **"វាសនាបុប្ផាខ្មែរក្រោម"** និងសៀវភៅដែលមានចំណងជើងថា **"ស្ថានភាពខ្មែរក្រោមនៅកម្ពុជាក្រោមនិងនៅកម្ពុជា"** ។ លោកក៏ជាអតីតនិពន្ធនាយក **កាសែត ឧត្តមគតិខ្មែរ កាសែត សង្គមយើង** វិទ្យុ **សំឡេងសន្តិភាព** និងវិទ្យុ**សំឡេងប្រជាធិបតេយ្យ** (VOD) និង សៀវភៅ **"ប្រវត្តិខេត្តទាំង ២១ នៃដែនដីកម្ពុជាក្រោម"** នេះផងដែរ ។

៧-មរណាបុគ្គលយ៉ាងសោកនាដកម្មរបស់ខ្មែរក្រោមខេត្តឃ្លាំង

ខ្មែរក្រោមខេត្តឃ្លាំងក៏មានបុគ្គល ដែលបានទទួលមរណាភាពក្នុងភាពសោកនាដកម្មគឺ ការស្លាប់ក្នុងទិដ្ឋភាពគួរឱ្យអណោចអធមដោយអំពើព្រៃផ្សៃបំផុតបំនួន ៦ រូបគឺ នៅវៀតណាមបំនួន ៥ រូប និងនៅកម្ពុជាបំនួន ១ រូបគឺ៖

នៅវៀតណាមបំនួន ៥ រូបគឺ៖

១.លោក **ឡឹម លី** ស្រុកកំណើតនៅភូមិតាសេក ឃុំស្វាត ស្រុកជ្រោយញ ប្រធានបទសនាខ្មែរសេរី ខេត្តឃ្លាំងត្រូវបានអាជ្ញាធរ ស្រុកជ្រោយញលួចធ្វើឃាតនៅក្នុងទសវត្សរ៍ឆ្នាំ ៥០ ។

២.ព្រះគេជព្រះគុណ **ត្រឹង ឃាន** បៅអធិការវត្តឃ្លាំង ត្រូវបានអាជ្ញាធរខេត្តឃ្លាំងលួចធ្វើឃាតនៅក្នុងទសវត្សឆ្នាំ ៥០ នេះដែរ ។

៣.ព្រះគេជព្រះគុណ **យឿង សិន** បៅអធិការវត្តតាទាវចាស់ ឃុំតាទាវ ស្រុកជ្រោយញត្រូវបានកងកម្លាំងវៀតកុងចាប់ទៅធ្វើឃាតដោយកាប់ និងដាវទម្លាក់ព្រៃកនៅក្នុងព្រៃក្នុងស្រុកជ្រោយញនៅឆ្នាំ ១៩៦៧ ។

៤. ព្រះមហា **សឺន ឋាន** ព្រះពហុស្សុត វត្តទេពារាមព្រៃជាប់ ឃុំទឹកសាប ស្រុកជ្រោយញ និងជាប្រធានគណៈធម្មាចារ្យខេត្តពលលាវ ត្រូវបានអាជ្ញាធរយួនខេត្តពលលាវ លួចធ្វើឃាតនៅភូមិទឹកបៃក ស្រុកពលលាវ នៅឆ្នាំ ១៩៧៣ ។

៥.លោក **លី ឆួន** ហៅ **ឧត្តម** ស្រុកកំណើតនៅភូមិព្រៃជាប់ ស្រុកជ្រោយញ អ្នកបើកបរជូនព្រះមហា សឺនឋាន ត្រូវអាជ្ញាធរខេត្តពលលាវ ធ្វើឃាតនៅថ្ងៃជាមួយព្រះមហា សឺនឋាន ។

-នៅកម្ពុជា ១ រូបគឺ លោកសាស្ត្រាចារ្យ **ឡើង វិន** ស្រុកកំណើតនៅភូមិព្រៃជាប់ ឃុំទឹកសាប ស្រុកជ្រោយញត្រូវបានក្រុមសិស្សសាលាដែលគាំទ្របលនាគស៊ីរបស់ខ្មែរក្រហមបានសម្លាប់ ដោយចាក់ទឹងកាំបិតជំពុះទុងនៅវិទ្យាល័យបុសខ្នុរ ស្រុកបម្ការលើ ខេត្តកំពង់ចាម នៅឆ្នាំ ១៩៧០ ។

៨-កិត្តិយសបុគ្គលខ្មែរក្រោមខេត្តឃ្លាំង៖

ទន្ទឹងនឹងខេត្តឃ្លាំងមានខ្មែរក្រោម ៦ រូប បានស្លាប់ក្នុងស្ថានភាពដ៏

គួរឱ្យខ្ពោចផ្សា និងឈឺចាប់គោះ ក៏មានខ្មែរក្រោមខេត្តឃ្លាំង ៤ រូបដែរ ត្រូវបានរដ្ឋាភិបាលយួន ២ ជំនាន់ គឺជំនាន់ **ង្វៀន វ៉ាន់ ធីវ** និងជំនាន់កុម្មុយនិស្ត ផ្តល់កិត្តិយសជូនជាអ្នកក្លាហាន និងជាបវរកញ្ញា ដូចជាៈ

១-ព្រះមហា **លឺន ឋាន** ត្រូវបានយួនកុម្មុយនិស្តបច្ចុប្បន្នផ្តល់កិត្តិយសជាវីរបុរសរបស់គេជាគ្រឿងបច្ចាមរណៈ ។

២-លោកស្រី **ថាប់ ធីឌិន** ត្រូវបានរដ្ឋាភិបាលវៀតណាមសាធារណរដ្ឋ (វៀតណាមខាងត្បូង) ចាត់ទុកជាស្ត្រីមានស្នាដៃក្នុងការថែរក្សាយុទ្ធជនរបួសក្នុងឆ្នាំ ១៩៧៣ ។

៣-លោក **ឡឹម តឿង** ស្រុកកំណើតនៅភូមិសំរោងទោល ស្រុកជ្រោយញ្ញ ត្រូវបានរដ្ឋាភិបាលនៃបក្សកុម្មុយនិស្តយួនបច្ចុប្បន្ន ប្រសិទ្ធិនាមថាជា អនុសេនីយ៍ត្រីក្លាហាន (Thieu Uy Anh Hung) ។

៤-កញ្ញា **ទ្រឿង ធី ម៉ៃ** ហៅ **រស្មី** មានស្រុកកំណើតនៅភូមិព្រៃជាប់ស្រុកជ្រោយញ្ញ ត្រូវបានអាជ្ញាធរខេត្តឃ្លាំងជ្រើសរើសជាបវរកញ្ញាឯករបស់វៀតណាមឱ្យចូលរួមប្រកួតជ្រើសរើសបវរកញ្ញាឯកបក្រវាឡកាលពីឆ្នាំ ២០១២ ។

៩-លក្ខណៈពិសេសៗរបស់ទឹកដីខេត្តឃ្លាំង

ទឹកដីខេត្តឃ្លាំងមានលក្ខណៈពិសេសៗ និងព្រឹត្តិការណ៍សំខាន់ៗទាក់ទងដល់ខ្មែរកម្ពុជាក្រោមជាប្រើនបំណុច ដែលយើងបានកត់ត្រាដូចតទៅៈ

១.ទឹកដីខេត្តឃ្លាំង ធ្លាប់បានថ្វាយព្រះរាជបដិសណ្ឋារកិច្ចបំពោះព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ កាលព្រះអង្គទ្រង់យាងជាព្រះរាជាធិបតីនៃពិធីសម្ពោធ ទីស្នាក់ការមិត្តសមាគមខ្មែរកម្ពុជាក្រោម កាលពីឆ្នាំ ១៩៣៧ ពេលដែលព្រះអង្គនៅជាព្រះអង្គម្ចាស់នៅឡើយ ។

២.ទឹកដីខេត្តឃ្លាំងក៏ធ្លាប់បានធ្វើបដិសណ្ឋារកិច្ចបំពោះប្រធានាធិបតីយួនខាងត្បូង ង្វៀន វ៉ាន់ ធីវ ដែលអញ្ជើញទៅប្រកាសបង្កើតអគ្គនាយកដ្ឋានអភិវឌ្ឍន៍ពង្រីកដីវិភាពប្រជាជនវៀតណាមកំណើតខ្មែរ នៅឆ្នាំ ១៩៦៩ ។

៣.ទឹកដីខេត្តនេះជាប្រភពនៃកំណើត ល្ខោនបាសាក់ខ្មែរ ។

៤.ខេត្តឃ្លាំងក៏ជាប្រភពនៃទំនៀមទម្លាប់ពិធីប្រណាំងទូករបស់ប្រជាពលរដ្ឋខ្មែរផងដែរ ។

៥. ជាទឹកដីដែលក្រសួងធម្មការនៃព្រះរាជាណាចក្រកម្ពុជាជាក់ទីស្នាក់ការពុទ្ធសាសនបណ្ឌិតខ្មែរ នៅជិនដឹកម្ពុជាក្រោម ។

៦.ជាទឹកន្លែងជាក់ទីស្នាក់ការមិត្តសមាគមខ្មែរកម្ពុជាក្រោមដំបូងបង្អស់នៅឆ្នាំ ១៩៣៧ ។

៧. ជាទឹកន្លែងប្រារព្ធពិធីបុណ្យអុំទូកប្រពៃណីដ៏ធំជាងគេនៅជិនដីកម្ពុជាក្រោមសព្វថ្ងៃនេះ ។

រៀបរៀងដោយ **តាំង សារៈ**



ព្រះវិហារវត្តឃ្លាំង ។ រូបថតៈ ភិក្ខុ ថាច់ តី

ប្រលោមលោកបែបមនោសញ្ចេតនា

រឿង វាសនាបុប្ផាខ្មែរក្រោម

និពន្ធដោយ

លោក តាំង សារៈ
ប្រធានកំបន់ នៃ សហព័ន្ធខ្មែរកម្ពុជាក្រោម ប្រចាំប្រទេសកម្ពុជា



ភគ ១
ដួបគ្រាដំបូង

ដួប អ្នងដំបូងនៅហាងបាយ ឃើញភ័ក្ត្រឆោមឆាយល្អគួយគន់
គ្រា ដៃលបងដួបសែនបៃដន្យ បងតែងគួយគន់មិនជិនណាយ ។
ដំ បូងគ្រាន់តែនឹកអាណិត ក្រោយមកប្រតិព័ទ្ធមិនរសាយ
បូង សំរួងសួមដួបស្រស់ឆោមឆាយ តែយើងពីរកាយសែនឆ្ងាយគ្នា ។

វិបុលគឺជាអតីតនិស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រមួយរូប ដៃលទើបតែប្រឡងចេញពីមហាវិទ្យាល័យនេះ នាបុងឆ្នាំ ១៩៦៩ គឺមុនពេលដៃលលោកឧត្តមសេនីយ៍ លន់-ណុល ធ្វើរដ្ឋប្រហារ សម្តេចព្រះ នរោត្តម សីហនុ តែប៉ុន្មានខែប៉ុណ្ណោះ ។

ក្រោយពីប្រឡងចេញរួចហើយ វិបុលរកការងារមិនទាន់បានធ្វើផង គាប់ជួនជាពេលនោះ ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងសភាពជ្រួលច្របល់ ដោយសង្គ្រាមរវាងកងទ័ពរដ្ឋាភិបាលលោក លន់ ណុល និងកងទ័ពឧទ្ទាម ដៃលមានពីរអង្គភាព គឺអង្គភាពខ្មែរក្រហម និងអង្គភាពវៀតកុង និងវៀតណាមខាងជើង ។

នាពេលនោះ វិបុលក៏សម្រេចចិត្តចូលបំរើក្នុងជួរកងទ័ព នៃកងយោធពលខេមរជាតិ (FANK) របស់លោក លន់-ណុល ក្នុងឋានៈជាពេទ្យ ទាហានមួយរូបតាមសេចក្តីអំពាវនាវរបស់ប្រទេសជាតិ ។

គេពុំបានដឹងថា ឪពុកម្តាយរបស់វិបុលមានជាប់ឈាមជ័រជាមួយនិងខ្មែរកម្ពុជាក្រោមដៃរឬអត់នោះទេ?

ប៉ុន្តែបំពោះ វិបុល វិញមានដើមកំណើតនៅខេត្តបាត់ដំបង ។ និស្ស័យរបស់ វិបុល ចូលចិត្តរាប់អាន និងចូលចិត្តសិក្សាស្រាវជ្រាវអំពីប្រវត្តិភូមិសាស្ត្រ និងព្រឹត្តិការណ៍ផ្សេងៗ នៅដៃនដីកម្ពុជាក្រោមណាស់ ។

ស្របពេលដៃលវិបុលចូលបំរើការនៅក្នុងអង្គភាពពេទ្យទាហាន ក្នុងសម័យ លន់-ណុល (សាធារណរដ្ឋខ្មែរ) ហើយពេលនោះទាហានម៉ៃហ្វក របស់ឯកឧត្តម សឺន ង៉ុក ថាញ់ ដៃលសុទ្ធតែជាខ្មែរកម្ពុជាក្រោមត្រូវបញ្ជូនមកស្រុកខ្មែរ ដើម្បីដួយប្រយុទ្ធទល់ជាមួយកងទ័ពយួនយៀកកុងយៀកណាមខាងជើងផងនោះ ធ្វើឱ្យ វិបុល បានស្គាល់ និងបានដឹងនូវព្រឹត្តិការណ៍ផ្សេងៗនៅកម្ពុជាក្រោម កាន់តែច្បាស់ និងធ្វើឱ្យគេកាន់តែបង់ស្គាល់នូវទឹកដីកម្ពុជាក្រោមកាន់តែខ្លាំងឡើង ។

ទន្ទឹមនោះដៃរ វិបុល មានមិត្តភ័ក្តិយ៉ាងជិតជិតមួយរូបជាខ្មែរមកពីកម្ពុជាក្រោម ឈ្មោះ សឺន សំណាង មានដើមកំណើតនៅខេត្ត

ព្រះត្រពាំង បច្ចុប្បន្ន ជាភ្នាក់ងារយកព័ត៌មានជូនសារព័ត៌មាន "ទុក្ខខ្មែរកម្ពុជាក្រោម" ។

លោក សឺន សំណាង បានចាកចេញពីស្រុកកំណើត តាំងពីឆ្នាំ ១៩៦០ គឺ តាំងពីតរុណវ័យមកម្ល៉េះ ដោយមកស្នាក់នៅក្នុងកុដិរបស់ព្រះតេជព្រះគុណ ព្រះបាឡាត់ កែវ នាវត្តខ្ពស់ណាលោម ។

មានវេលាល្ងាចថ្ងៃមួយ វិបុល និងសំណាងបានបបួលគ្នាទៅពិសារភេសជ្ជៈនៅក្នុងហាងតូចមួយ ។ ក្នុងពេលពិភាក្សាលេងពីនេះពីនោះ វិបុល ក៏គេចាប់ផ្តើមប្រយោគទៅកាន់សំណាងថាៈ

វិបុលៈ សំណាង! គ្នាដូចជាចង់ស្គាល់ទឹកដីកម្ពុជាក្រោមបាន ម្តងតើត្រូវធ្វើដំណើរដោយវិធីណា សម្លាញ់ឯងជួយបង្ហាញផ្លូវគ្នាផងមើល!

សំណាងគេអង្គុយសញ្ជឹងមួយភ្លែត ទើបគេងើបឡើង ហើយឆ្លើយទៅវិបុលវិញថាៈ

អូ! គ្នាឆក់ឃើញហើយសម្លាញ់ ពេលនេះរដ្ឋសភាជាតិកំពុងរៀបចំ ជាគណៈប្រតិភូរបស់រដ្ឋសភាមួយ ដែលដឹកនាំដោយលោក ជាញ់ សាង[1] ដើម្បីបុះទៅធ្វើទស្សនកិច្ច និងសាកសួរសុខទុក្ខបងប្អូនខ្មែរនៅដែនដីកម្ពុជាក្រោមនៅខែខាងមុខនេះ ។

បំណែកសារព័ត៌មាន «ទុក្ខខ្មែរកម្ពុជាក្រោម» ក៏ត្រូវបានគណៈប្រតិភូនេះអញ្ជើញសមាជិកចំនួន៣រូបបបួលរួមដំណើរ ក្នុងនាមជាអ្នកយកព័ត៌មានផងដែរ ។ ប៉ុន្តែពេលនេះ លោកចាងហ្វាងទើបតែជ្រើសរើសបានរូបខ្ញុំម្នាក់ ជាមួយនឹងលោកប៉ុណ្ណោះ ។ ដូច្នេះចាំខ្ញុំទៅជម្រាបគាត់ឲ្យបញ្ចូលឈ្មោះសម្លាញ់ឯងម្នាក់ទៀត ប្លាស់ជាគាត់មិនបដិសេធទេ ព្រោះលោកចាងហ្វាង និងវិបុលឯងក៏ធ្លាប់ស្គាល់គ្នាជិតដិតដែរ មិនថាអញ្ចឹងហឺ?

ពេលនោះ វិបុល គេសើចសប្បាយក្នុងក្តីសង្ឃឹមថានឹងបានស្គាល់ទឹកដីកម្ពុជាក្រោម បានយល់អ្វីៗដែលគេធ្លាប់ស្រមៃឃើញក្នុងដួងចិត្តរបស់គេ ។

ថ្ងៃកំណត់នៃការធ្វើទស្សនកិច្ចរបស់សមាជិករដ្ឋសភា នៃសាធារណរដ្ឋខ្មែរទៅកាន់ដែនដីកម្ពុជាក្រោមបានមកដល់ ដោយមានលោក ជាញ់ សាង ជាតំណាងរាស្ត្រមានដើមកំណើតនៅខេត្តក្រមួនស ជាអ្នកដឹកនាំ និងមានសមាជិកគណៈប្រតិភូសរុប ២០ រូប ដែលសមាជិកខ្លះមានដើមកំណើតនៅកម្ពុជា និងខ្លះមានដើមកំណើតនៅកម្ពុជាក្រោម ដោយបម្រុះគ្នាក្នុងនោះក៏មានវិបុល និង សំណាង ផងដែរ ។

គណៈប្រតិភូនេះបានអញ្ជើញទៅធ្វើទស្សនកិច្ច សួរសុខទុក្ខបងប្អូនខ្មែរកម្ពុជាក្រោមក្នុងខេត្តមួយចំនួនជាអាទិ៍ គឺខេត្តព្រះត្រពាំង ខេត្តក្រមួនស និងខេត្តឃ្លាំង ជាដើម ។

អាស្រ័យដោយរូបគេ (វិបុល) បង់ស្គាល់បង់ដឹងឱ្យបានប្រើនអំពីទឹកដី និងប្រជារាស្ត្រខ្មែរនៅដែនដីកម្ពុជាក្រោមនោះ គេតែងតែសុំការអនុញ្ញាតពីលោកប្រធានគណៈប្រតិភូ ដើម្បីបុះទៅខេត្តផ្សេងៗទៀត ដែលមានខ្មែរក្រោមរស់នៅ ហើយដែលគណៈប្រតិភូគ្មានគម្រោងបុះទៅទីនោះ ។

ដូចជាថ្ងៃមួយ ពេលដែលគណៈប្រតិភូបញ្ចប់ទស្សនកិច្ចចំនួនមួយថ្ងៃនៅក្នុងខេត្តឃ្លាំង (វត្តផ្អោរការ ឃុំកំពង់ធំ ស្រុកឱ្យាប់) ហើយត្រូវវិលត្រឡប់មកសម្រាកនៅទីក្រុងព្រៃនគរបំនួន ២ ថ្ងៃ ដើម្បីជួបសម្តែងការគួរសម និងសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីអ្នកមុខអ្នកការនៃយួន ខាងត្បូងនោះ វិបុល និងសំណាង គេបានសុំការអនុញ្ញាតពីលោក ជាញ់ សាង ដើម្បីទៅទស្សនានៅខេត្តពលលាវ ដែលមានចម្ងាយ ៥០ គីឡូ ម៉ែត្រពីទីប្រជុំជនខេត្តឃ្លាំង ។ ក្រោយពីបានទទួលការអនុញ្ញាតពីលោក ប្រធានហើយ ពួកគេក៏បានធ្វើដំណើរតាមរថយន្តឈ្នួលមួយគ្រឿង បានទៅដល់ទីរួមខេត្តពលលាវនៅវេលាម៉ោង ១១ ថ្ងៃត្រង់ ។

វិបុល និង សំណាង បានចូលទៅដល់ហាងលក់បាយមួយ ដើម្បីទទួលទានអាហារថ្ងៃត្រង់ មុននឹងបន្តដំណើរទៅកាន់ភូមិសាស្ត្រមួយចំនួនទៀត ដែលជាទីកន្លែងយួនបានសម្លាប់ខ្មែរក្រោម កាលពីឆ្នាំ ១៩៤៥ ដូចជា កោះមួតស្រែអំបិល (យ៉ាវ៉ាយ) និងហ្វូផុងជាដើម ដែលស្ថិតនៅចម្ងាយ ប្រហែលជា ៥០ គីឡូម៉ែត្រ ពីទីប្រជុំជនខេត្តពលលាវ និងបន្តដំណើរទៅកាន់ខេត្តទឹកឡៅទៀត ។

ពេលចូលក្នុងហាងបាយ ដោយ វិបុល គឺជាខ្មែរដែលមានដើមកំណើតនៅកម្ពុជាកណ្តាល ដូច្នេះ អ្នកកម្ពោះយើងមិនចេះភាសាវៀតណាមទេ ។

ឯចំណែកកម្ពោះ សំណាង វិញ ប្លឹបើគេមានដើមកំណើតនៅកម្ពុជាក្រោមមែន ប៉ុន្តែដោយគាត់បានចាកចេញពីស្រុកកំណើត

មករស់នៅក្នុងប្រទេសកម្ពុជាតាំងពីក្មេងមកនោះ ដូច្នេះភាសាវៀត-ណាមរបស់អ្នកកម្លោះ យើងក៏មិនឮកែដែរ ។

ដោយឃើញអ្នកកម្លោះទាំង ២ និយាយភាសាវៀតណាមបែបបិះបើសយ៉ាងនេះ ទើបម្ចាស់ហាងបានតម្រូវឱ្យនារីខ្មែរកម្ពុជាក្រោមម្នាក់ក្នុងវ័យប្រហែលជា ១៨ ឬ ១៩ ឆ្នាំ មានឫកពាររម្យទម មានសម្រស់ស្រស់ស្អាត និងមានសម្លេងពីរោះ ប្រកបដោយសំដីទន់ភ្លន់មកសួរនាំភ្ញៀវ ។

ក្រមុំកម្ពុជាក្រោម៖ លោកមាពិសារអី? (២) ។

ដោយគ្រាន់តែឃើញភក្ត្រាដ៏ស្រស់ប្រិមប្រិយ នៃបុប្ផាមួយទងដែលកំពុងរីកនៅលើទឹកដីដ៏កំសត់នោះ ធ្វើឱ្យវិបុលហាក់ដូចជាមានអារម្មណ៍បម្លែកនៅក្នុងចិត្តភ្លាម ។ ប៉ុន្តែអ្នកនិពន្ធមិនបានដឹងថាអារម្មណ៍របស់គេពុះកញ្ជ្រោលដល់ថ្នាក់ណា ហើយក្នុងផ្លូវណានោះឡើយ ។ ពេលនេះអ្នកនិពន្ធ អាចជំរាបមិត្តអ្នកអាន និងជនរួមជាតិបានត្រឹមតែពាក្យថា៖ "គេមានអារម្មណ៍បម្លែកនៅក្នុងបេះដូចរបស់គេតែប៉ុណ្ណោះ" ។

ពេលនោះដោយ វិបុល បានឮសូរនារីតូចតន់ ដ៏ស្រស់សោភានិយាយភាសាខ្មែរ (តាមសំនៀងខ្មែរខេត្តពលលាវ) ផងនិងជាឱកាសផ្តើម អនុស្សាវរីយ៍ផងនោះ គេលែងត្រូវការឱ្យសំណាងជួយគេដូចជាពេលមុនៗ ទៀតហើយ គឺពេលនេះ គេប្រញាប់សួរទៅនាងក្រមុំតូចតន់នោះភ្លាមថា៖

វិបុល៖ មានម្ហូបអីខ្លះអាម៉ុម? (អាម៉ុមក៏ជាពាក្យខ្មែរកម្ពុជាកណ្តាល និយមហៅក្មេងស្រីដែលមានអាយុតិចជាងខ្លួនដែរ) ។

ក្រមុំកម្ពុជាក្រោម៖ ចា! លោកមា មានម្ហូបប្រើនមុខណាស់ ជាពិសេសប្រខៀបៀន, ប្រហុកអោបជាដើមក៏មាន ។

ពេលឮសូរនារីខ្មែរកម្ពុជាក្រោមប្រាប់មុខម្ហូប ប្រខៀបៀន និងប្រហុកអោប ធ្វើឱ្យវិបុលគេមានការងឿងឆ្ងល់យ៉ាងខ្លាំង បែរមកសួរសំណាងថា៖

-សម្លាញ់! ប្រខៀបៀន និងប្រហុកអោបនោះ ជាម្ហូបអ្វីទៅ? ហើយមានរសជាតិយ៉ាងណាដែរ?

សំណាង៖ ត្រីប្រខៀបៀន ជាត្រីទឹកប្រៃម៉្យាងយ៉ាងពិសេស និងមានរសជាតិឆ្ងាញ់ពិសារលើសត្រីនានាទាំងអស់នៅកម្ពុជាក្រោម ។ ឯប្រហុកអោប ក៏ជាប្រហុកដ៏កម្រមានទៅដែនដីកម្ពុជាក្រោមដែរ ។ ហើយម្ហូបទាំងពីរមុខនេះនៅកម្ពុជាមិនដែលមានទេ សម្លាញ់ឯងសាកល្បងម្តងទៅ!

វិបុល គេងាកទៅសម្លឹងភ័ក្ត្រដ៏ស្រស់ស្រទន់របស់នារីខ្មែរកម្ពុជាក្រោមរូបនោះ រួចពោលទៅកាន់នាងថា៖

-សូមនាងជាក់ប្រខៀបៀនមួយមុខ ប្រហុកអោបមួយមុខ និងសម្លរទឹកមួយមុខផងណា!

ក្រមុំកម្ពុជាក្រោម៖ ចា!

ដោយឃើញវិបុលបេះតែលួចសម្លឹង និងញញឹមញញែមទៅរកនារីកម្ពុជាក្រោមញយៗនោះ សំណាងគេព្យាយាមពញ្ជាក់វិបុលដោយយកដៃកេះភ្លៅវិបុល ធ្វើឱ្យវិបុលភ្ញាក់ព្រើត រួចហើយសំណាងគេនិយាយទៅកាន់វិបុលថា៖

សំណាង៖ វិបុល អ៊ីក៏សម្លឹងមុខនាងមិនដាក់ភ្នែកម្ល៉េះ ស្រឡាញ់នាងឬ?

វិបុល៖ សម្លាញ់ឯងនិយាយអីអញ្ចឹងទៅទៀ ។

សំណាង៖ បើបានជាជ្រុលស្រឡាញ់នាងហើយ គួរតែភ្ជាប់និស្ស័យ ឬសាងអនុស្សាវរីយ៍ជាមួយនារីខ្មែរកម្ពុជាក្រោមមួយរូបទៅអី?

វិបុល៖ គ្នាក៏មានគំនិតដូចសម្លាញ់ឯងនិយាយនេះដែរ ប៉ុន្តែគ្នាគិតឃើញថានឹងមិនបានសម្រេចដូចបំណងទេ ព្រោះយើងនៅឆ្ងាយពីគ្នាណាស់ ដូច្នេះការកសាងអនុស្សាវរីយ៍ជាមួយនាង ប្រសិនបើនាងជ្រុលជា ស្រឡាញ់ខ្ញុំហើយ ហើយយើងត្រឡប់ទៅកម្ពុជាវិញ មិនធ្វើឱ្យនាងតូចចិត្តទេឬ?

សំណាង៖ ប៉ុន្តែបើដែនដីនេះវិលមែនសោះ គ្នាជឿថាគង់តមានថ្ងៃជួបនាងទេ ដូចជាពាក្យចាស់លោកថា "បើពិតជាគ្រូរព្រេងមែនលែងអីនឹងជួប" ។

កំពុងតែជជែកគ្នា កញ្ញាតូចទន់បានយកតែទឹកកកមកជូន ពេលនោះវិបុលបានឃាត់នាង ដោយផ្តើមសំណួរទៅកាន់នាងថា៖

វិបុល៖ អត់ទោសអាម៉ុមជាខ្មែរកម្ពុជាក្រោមឬ?

ក្រមុំកម្ពុជាក្រោម៖ ចាស់! ខ្ញុំខ្មែរ (៣) ។

វិបុល៖ នាងឈ្មោះអ្វីដែរ?

ក្រមុំកម្ពុជាក្រោម: ចាស់! ខ្ញុំឈ្មោះ បុប្ផា ។

វិបុល: ស្រុកកំណើតនៅឯណា?

ក្រមុំកម្ពុជាក្រោម: នៅព្រៃជាប់ (៤) ។

វិបុល: ឆ្ងាយពីពលលាវនេះប៉ុន្មានដែរ?

ក្រមុំកម្ពុជាក្រោម: ចាស់! ប្រាំដណ្តប់គីឡូ (១៥ គម) សូមទោសលោកមាខ្ញុំរវល់ទៅធ្វើការសិន ។

ដោយប្រញាប់បន្តដំណើរទៅទៀតនោះ វិបុល និងសំណាង បានហៅម្ចាស់ហាងមកទូទាត់លុយ ។ ម្ចាស់ហាងនៅតែបញ្ជាឱ្យ បុប្ផា (ក្រមុំកម្ពុជាក្រោម) មកទទួលលុយពីភ្ញៀវទៀត ។

វិបុល: អស់ប៉ុន្មាន បុប្ផា? (ព្រោះគេបានស្គាល់ឈ្មោះនាងរួចហើយ) ។

បុប្ផា: ចាស់! អស់ប្រាំពាន់ដុងលោកមា

វិបុលគេហួតកាបូបចេញពីហោប៉ៅ និងហួតយកលុយចំនួនមួយម៉ឺនប្រាំពាន់ដុងហុចទៅឱ្យបុប្ផា ដោយពោលពាក្យទៅកាន់នាងថា:

-ប្រាំពាន់នេះថ្លៃបាយ ឯមួយម៉ឺនទៀតខ្ញុំជូនបុប្ផា ទុកគ្រាន់បាយវាយ តាមសេចក្តីត្រូវការ ។

បុប្ផាទទួលលុយពីវិបុល ដោយសម្តែងទឹកមុខភ្ញាក់ផ្អើល និងមានចម្ងល់ក្នុងចិត្ត ទីបំផុតនាងក៏សួរទៅវិបុលថា:

-ហេតុម្តេចក៏លោកមាជូនលុយខ្ញុំអីក៏ច្រើនម្លេះ?

វិបុលឆ្លើយតបទៅនាងវិញថា:

-សូមបុប្ផាទទួលយកទៅប្រើប្រាស់តាមតម្រូវការចុះ ដោយមិនបាច់គិតគូរអ្វីច្រើនពេកទេ ។

បុប្ផា: ចាស់! អរគុណហើយលោកមា

ក្រោយពីកម្លោះទាំងពីរ បានចាកចេញពីហាងបាយនោះមិនបាន ប៉ុន្មានផងភាពសប្បាយរីករាយ និងប្រាក់ចំនួនមួយម៉ឺនដុងដែលបុប្ផាខ្មែរ ក្រោមទើបតែទទួលបានពីកម្លោះភ្នំពេញនោះ បានក្លាយទៅជាទុក្ខសោកក្រៀមក្រំមួយរំពេច ។

សូមបញ្ជាក់ថា បុប្ផាដែលនៅបម្រើគេក្នុងហាងបាយនេះបានទទួល ប្រាក់ខែតែ ១៤០០០ ដុងប៉ុណ្ណោះក្នុងមួយខែ ។

មុនឆ្ងងបន្តរឿងរ៉ាវរបស់វិបុល និង សំណាងតទៅទៀតនោះ សូម មិត្តអ្នកអាន បង្វែរអារម្មណ៍មកតាមដានអំពីស្ថានភាពនៅក្នុងគ្រួសាររបស់ បុប្ផាម្តងវិញ ។

បុប្ផាជាកូនស្រីទោលរបស់លោក សម្ប្បណិ និងមីង សយ នៅភូមិព្រៃជាប់ ឃុំទឹកសាប ស្រុកជ្រោយញ ខេត្តពលលាវ។

អតីតភាពរបស់ពូសម្ប្បណ៍គឺជាទាហានជើងចាស់មួយរូបមានហ៊ាន: ជាអស្តង់សេហ្វ ជំនាន់បារាំង ។ ក្រោយពីធ្លាក់ខ្លួនពីការមក គាត់ក៏ត្រូវបានបញ្ចេញពីអង្គភាព ហើយវិលត្រឡប់មកស្រុកកំណើតវិញ ប្រកបមុខរបរធ្វើស្រែជាមួយនិងទឹកដីដ៏តិចតួច គឺ ៥ កុងដែលជាកេររបស់មីងសយ ។ ប៉ុន្តែអាស្រ័យដោយពូសម្ប្បណ៍មានអាជីពធ្វើតែទាហាន មិនស្ទាវប៊ុនប្រសប់ក្នុងការងារធ្វើស្រែបំការនេះផង និងដោយធ្លាប់មានបរិតជាអ្នកប្ចលចិត្តផឹកស៊ីគ្មានគិតពីពេលវេលានោះផង មួយថ្ងៃៗគាត់គិតតែពីផឹកស្រាស្រវឹងរៀងរាល់ថ្ងៃ មិនស្ទាវបានធ្វើការរកស៊ីអ្វីឡើយ ។

បំណែកមីង សយ ក៏មានជំងឺជាប្រើនៅក្នុងខ្លួន - អាស្រ័យដោយលោកប្តីរបស់គាត់ចេះតែធ្វើបាបផ្លូវចិត្តផង និងធ្វើបាបផ្លូវកាយផង ដូចជាការវាយដំប្រំធាក់ទៅលើរាងកាយរបស់គាត់ ដែលធ្វើឱ្យគាត់មិនស្ទាវមានកម្លាំងកំហែងក្នុងការរកស៊ីដើម្បីទប់ទល់ក្នុងជីវភាពគ្រួសារ ទីបំផុតដីស្រែដែលមានចំនួនតិចតួចនោះត្រូវលក់បង្ហើយតែម្តង ។ ហើយគ្រួសារត្រូវស្ថិតនៅក្នុងចំណោមគ្រួសារដ៏ក្រីក្របំផុតនៅក្នុងភូមិនេះ ដែលតម្រូវឱ្យវ៉ាសនានាងបុប្ផាត្រូវទៅរកស៊ីឈ្នួលគេ ដើម្បីយកលុយកាក់បន្តិចបន្តួចមកទប់ទល់ជីវភាពក្នុងគ្រួសារ ។

ថ្ងៃមួយ នៅក្នុងផ្ទះពូសម្ប្បណិ មានការផឹកស៊ីមួយដែលមានមនុស្សប៊ីបួននាក់រួមទាំងពូសម្ប្បណ៍ជាម្ចាស់ផ្ទះផង ។

បំណែកឯនៅលើគ្រែនាបឫស្សី ក្រាលកន្ទេលនបកញ្ជាស់ឯណោះវិញ មីងសយ កំពុងតែសម្រាន្តដកដង្ហើមហាត់គឃ្យរ ដោយជំងឺខ្យាយបេះដូងកំពុងរើ ។

រីឯនៅលើកន្ទេលនប (កន្ទេលចបូត) ឃាំងកញ្ជាស់ដែលក្រាល ផ្ទាល់ដីឯណោះវិញ ក្រុមប្រឹក្សាទាំងបី-បួននាក់កំពុងស្រែកអាឡូអាឡា ដោយពុលស្រាយ៉ាងសម្បើមដៃ គ្មានបានគិតកោតរអែង ឬអាណិតអាសូរ ដល់អ្នកមានជំងឺ ឬក៏មិនទុកឱ្យអ្នកជំងឺបានសម្រាន្តដោយស្រួលឡើយ ។ ពេលនោះ ពូសម្ប្បណិ ដោយកំពុងស្រវឹងដោកទន់បបូរមាត់ហើយនោះបានស្រែកដំទាលទារស្រាពីប្រពន្ធដែលកំពុងដេកដកដង្ហើមហាត់គឃ្យរនោះថា:

-នែ! ម៉ែបុប្ផាទៅទិញស្រាឱ្យប៉ាលីត្រទៀតមើល៍!

មីងសយៈ ឱ៎អើយ ខុំគ្មានលុយឯណាទៀតទេ ទើបតែទៅទិញថ្នាំបណ្តាក់ (ជើ) គេ អម្បាញ់មិញនេះ រង់ចាំបីបួនថ្ងៃទៀត បុប្ផាមកពីពលលាវ ទើបមានលុយសងគេ ។ ឱ៎ឯងក៏ល្មមឈប់ដែរហើយ ។

គ្រាន់តែឮមីង សយ ឆ្លើយតបទៅឮសម្បុណ៌ មិនទាន់ទាំងចប់ប្រយោគផង ជនប្រមឹកមួយរូបបានបន្ថែសំដីក្នុងភាពទន់ជ្រាយ ដោយស្រែរឹងជោគស្លាប នោះឯង

យើ! តាប្ង ហ្នឹងប្រពន្ធ ក៏ម៉ែវ៉ើយ បើប្រពន្ធអញវិញណា អញមិនទុក អោយឆ្លើយប៉ប៉ែះដូចនេះទេវ៉ើយ ហើយបើហ៊ានឆ្លើយ អញវ៉ៃទាល់តែងាប់អញប្រាប់ ។

(នៅមានត)

សម្រង់ភាសាខ្មែរនិយមប្រើនៅដែនដីកម្ពុជាក្រោម

ក



កញ្ចែ (ន) មើលពាក្យ កញ្ចែ ក្នុងវិបនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ។ សូមបញ្ជាក់ថាខ្មែរនៅកម្ពុជាក្រោម (ខ្មែរក្រោម) មិនដែលប្រើពាក្យ ស៊ីផ្លែទេ គឺប្រើតែពាក្យផ្លុំកញ្ចែ ។ ឧ. ឡានផ្លុំកញ្ចែសុំបើកផ្លូវ ។

កញ្ឆាញ (ន) ឧបករណ៍បំពងសំឡេង(អ្នប៉ាល័រ)

កន (ន) ពួក, ក្រុម ។ ម.ព. កន ក្នុងវិបនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត ។ ខ្មែរក្រោមមិនសូវប្រើពាក្យ ពួក ឬ ក្រុមនេះជាទូទៅទេ តែប្រើជាទៅតាមពាក្យ កន នេះឯង ។ ឧ. កនឯង កនអញ់ កនយើង ។

កន្តុម (ន) ឧបករណ៍សម្រាប់បាំងខ្យល់កុំឱ្យរលត់ភ្លើងបង្កៀង ឬភ្លើងទៀនពាក្យនេះនិយមប្រើនៅខេត្តព្រះត្រពាំង ។

កន្ធប (ន) ក្រណាត់សម្រាប់ទ្រាប់គូទទារក (កូនង៉ែ) ។ ឧ. កន្ធបអាបម៍កូន ។

កន្ធប ២ (ន) ជាពាក្យហៅសំដៅទៅលើជនជាតិវៀតណាម ។ ឧ. ឃ្លួនកន្ធប ឬអាកន្ធបជាដើម ។

កន្ទំរំ (គុ) ដែលក្រាស់ ដែលខ្ពស់ ។ ឧ. ព្រៃកន្ទំរំ (ប្រើសសម្រាប់តែព្រៃប៉ុណ្ណោះ) ។

កន្ត្រាក (ន) កន្ត្រក ។ (ខេត្តព្រះត្រពាំង) ។

កន្ទិប-កន្ទ្រិប (ន) ប៉ាន់តែ ។ ពាក្យនេះអាចខ្មែរក្រោមហៅក្លាយពីភាសាវៀតណាមថា ប៊ិនទិត (Binh Tich) ។

កន្ទេលនប (ន) កន្ទេលបច្ចុត ។ ពិតមែន តែកន្ទេលនេះគ្បាញពីបច្ចុត ប៉ុន្តែខ្មែរក្រោមបែរជាហៅថាកន្ទេលនបទៅវិញ ព្រោះកន្ទេលនេះអាចធ្វើជា "នប" បាន ។ សូមរងចាំអានពាក្យថា "នប" នៅ ទំព័រខាងមុខ ។

កន្ទែងពុកពុយ (ន) កន្ទែងពោះគោ ។ (ខេត្តព្រះត្រពាំង) ។

កន្ទែងព្រួយ (ន) មើលពាក្យ "កន្ទែងពុកពុយ (ខេត្តឃ្លាំងពលលាវទឹកខ្មៅ...) ។

ក្រក់ (ន) ក្រញ៉ ។ ឧ. ត្បាក់មួយក្រក់-ខោកមួយក្រក់ ។

ក្រមួនស (ន) ជាខេត្តខ្មែរមួយនៅជើងដីកម្ពុជាក្រោម (ខេត្តក្រមួនស) ខេត្តនេះក្លាយមកពីពាក្យ ក្រមួនសុទ្ធ ត្រូវនឹងភាសាបិនថា "បេនឡា" ដែលត្រូវយួនរំលោភយកនៅឆ្នាំ ១៧១៥ ។ ក្នុងសម័យអាណានិគមបារាំងគ្រប់គ្រងកម្ពុជាក្រោម (កូសាំងស៊ីន) គេបានប្តូរឈ្មោះទៅជារ៉ាចយ៉ា (Rach Gia) និងសម័យ ង៉ោ ឌិញ យឹម គេបានប្តូរឈ្មោះទៅជា គៀនយ៉ាង (Kien Giang) បច្ចុប្បន្នគេបានបញ្ចូលខេត្តនេះទៅក្នុងខេត្តបារាង្ច ដែលវៀតណាមហៅ អានយ៉ាង (An Giang) ។

កន្លះគ្រាប់ (គុ) ដែលមានរិតបៃបមិនគ្រប់ទឹក (ទ្បឹកី) ។ ខ្មែរក្រោមនិយមប្រើភ្ជាប់ជាមួយពាក្យទ្បឹកី ។ ឧ. អាមួយនេះដូចជាទ្បឹកីកន្លះគ្រាប់ ។

ក្រលៀម (ន) ឧបករណ៍កសិកម្មម៉ាំងនៅជើងដីកម្ពុជាក្រោម ដែលមានផ្នែកោងធ្វើអំពីដែកដូចផ្នែកណ្តៀវ ប៉ុន្តែមានដងត្រង់ខ្លី ប្រវែង តឹក ដូចដងកាំបិត សម្រាប់កាត់ ឬប្រូតស្មៅ ឬប្រូតស្រូវ ។ នៅតំបន់ខ្លះហៅថា "ឃ្លៀម"ទៅវិញ ។

ក្រហមតែត (គុ.វិ) ក្រហមណាស់ ក្រហមលើសពីធម្មតា ។

ក្រហមទែង (គុ.វិ) ម.ព. ក្រហមតែត ។

ក្រហមទុំ (គុ.វិ) = ម .ព. ក្រហមតែត ។

ក្រហមប៉ាំង (គុ.វិ) ម.ព. ក្រហមតែត ។

ក្រហមញាំង (គុ.វិ) ម.ព. ក្រហមតែត ។

ក្រហ្មប (ន) វត្តម្ប៉ាងមានរាងសណ្ឋានដូចក្រឡមានទំហំធំជាងក្រឡ ។ ជាឧបករណ៍ សម្រាប់ប្រកប្រហុក ទឹកត្រី និងផ្អក ។ ឧ. ប្រហុកមួយក្រហ្មប ។ (ខេត្តព្រះត្រពាំង ។

កាប៉ុន (ន) បានដែក ។ (ខេត្តក្រមួនស) ។

កាប ១ (គុ) មើលវិបនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ។

កាប ២ (គុ) ជាវេរិបនស័ព្ទ នឹងពាក្យ "ណាស់" ។ ឧ. ប្រើនកាប សកាប ខ្មៅកាប ។

ការ (ន) ក្រវិល ។ មើលវិបនានុក្រមសម្តេច ព្រះសង្ឃរាជ ជួន ណាត

ក្ងនម៉ែ (ន) ឈ្មោះម្ហូរមួយប្រភេទ ដែលយកបាយមកផ្ទាប់ឱ្យរលួយ កើតជាមេ មានរូបរាងតូចដូចស្រមើល ។ ពេលបរិភោគ គេយកទៅកិនផ្សំគ្រឿងមានដូចជាជីបារាំង ជីសំពៅ អំបិល ទឹកត្រី ឬប្រហុក រួចយកទៅចំហុយ សម្រាប់ជ្រលក់នឹងបន្លែ ឬសាច់ផ្សេងៗដូចជាខ្យង ក្តាម សាច់គោ ពោះគោ ពោះក្របី ។ល។ (ម្ហូរក្ងនម៉ែ) ។

ក្តាមចោត (ន) ជាក្តាមមួយប្រភេទមានខ្លួនធំបំផុតប៉ុន្តែមេដៃ មានដង្កៀបម្ខាងធំជាងខ្លួន ដង្កៀបម្ខាងទៀតប៉ុនដើងធម្មតា ប្រើនរស់នៅតំបន់ទឹកប្រៃ ។ (ខេត្តព្រះត្រពាំង) ។

(នៅមានត)



ក្រាំងមាសកត់ត្រា

«ក្រាំងមាសកត់ត្រា» ជាសៀវភៅកត់ត្រានាម និងឈ្មោះរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកា និងអ្នកគាំទ្រ សហព័ន្ធខ្មែរកម្ពុជាក្រោម ទូទាំងពិភពលោក ដែលបានឧបត្ថម្ភបរិវិកាប្រមាណ **៣៧០.០០០** ដុល្លារសហរដ្ឋអាមេរិក សម្រាប់ទិញ និងជួសជុល ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម ព្រមទាំងកសាងរូបសំណាក ឧកញ៉ា សឺន គុយ នៅរដ្ឋធានី Washington D.C., សហរដ្ឋអាមេរិក ។

ក្រៅពីនេះ **«ក្រាំងមាសកត់ត្រា»** ក៏បានកត់ត្រាបំនួនបរិវិកាដែល ស.ខ.ក. បានទទួលពីសប្បុរសជន និងបំនួនបរិវិកាដែលបានបំណាយទៅលើ ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម យ៉ាងលម្អិតផងដែរ ។

ព័ត៌មានលម្អិតអំពី ទីស្នាក់ការ សហព័ន្ធខ្មែរកម្ពុជាក្រោម និងការកសាងរូបសំណាក ឧកញ៉ា សឺន គុយ មាននៅក្នុង **«ក្រាំងមាសកត់ត្រា»** ។

អ្នកការពារសន្តិភាពកម្ពុជាក្រោម



ព្រះសង្ឃ និងពលរដ្ឋខ្មែរក្រោមទាំង ១៩ រូប ដែលត្រូវរបបអាណានិគមយួន ចាប់ផ្សឹក និងដាក់ពន្ធនាគារ ដោយគ្រាន់តែអនុវត្តសិទ្ធិជាមូលដ្ឋានរបស់ខ្លួនជាជនជាតិដើម នៃដែនដីកម្ពុជាក្រោម ។